ទស្សនាវដ្តីមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ប៊ូ ម៉េង អ្នកទោសគុកទួលស្លែងដែលនៅមានជីវិត
- សញ្ញានៃអំពើប្រល័យពូជសាសន៍

[illegible]

លេខ៩៨ ខែ កុម្ភៈ ឆ្នាំ២០០៨

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៨ ខែកុម្ភៈ ឆ្នាំ២០០៣


## មាតិកា


◆ សំបុត្រៈ ចំពោះអ្នកស្លាប់ដោយបុព្វហេតុសេរីភាព.................. ១

**ផ្នែកឯកសារ**

◆ ៣គោនក្នុង១ហិកតា........................................................ ២

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស.......................................... ៤

◆ ទូរលេខ ៣៨ៈបងជាទីគោរពស្នេហា ..................................៥

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១.......... ៧

◆ ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម........................................... ៨

◆ កិច្ចសន្ទនារវាង គេង ស៊ាវ ភីង និង អៀង សារី.............. ១៤

◆ កិច្ចសន្ទនារវាង ហ្វា គួ ហ្វេង និង អៀង សារី................. ១៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មិនទាន់បានទទួលយុត្តិធម៌................................................១៩

◆ ភូមិកន្ទែងរមាស សំណល់បដិវត្តន៍....................................២៣

◆ រឿងរ៉ាវរបស់ យាយគាវ នៅក្នុងសម័យខ្មែរក្រហម ............២៧

◆ ជនជាតិចិននៅកម្ពុជា.................................................... ២៩

◆ បូ ម៉េងៈ អ្នកទោសគុកទួលស្លែងដែលនៅមានជីវិត.............. ៣៦

**ផ្នែកច្បាប់**

◆ គំរូយុត្តិធម៌អន្តរជាតិមានន័យដូចម្តេច ................................៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ សង្គ្រាមនៃអំពើប្រល័យពូជសាសន៍ ................................៤១

◆ សុន្ទរកថារបស់ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដា ស្តេហ្វានី ប៉ែក...៤៨

◆ ឆ្លើយតបទៅនឹងអត្ថបទ «ភ្នាក់ងារផ្តាច់ព្រលឹង».......................៥៣

**ទំព័រស្វែងរកគ្រួសារ**

◆ អតីតកាលដែលកប់បាត់ទៅក្នុងពេលវេលា......................... ៥៤

◆ ម្តាយខ្ញុំប្រាប់អំពីការពិត................................................. ៥៩




បូ ម៉េង

អ្នកទោសគុកទួលស្លែង ដែលនៅមានជីវិត


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ:*** អឿ រតនា, ប៉ាង ពីរ៉ែន, យិន នាន, វ៉ាន់ថាន់ ពៅដារ៉ា, ឡុង ដានី, ច័ន្ទ សម្បត្តិ, ហ៊ុយ វណ្ណៈ, ទិត្យ ណារ៉ាន់គីរី, ស្តេហ្វានី ប៉ែក, ចន ឆរឆឺអារី, ភីតផ័រ ម៉ាឃៀវ ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** លី សុផល, សើ សាយ្យាណា ***ជំនួយការនិពន្ធនាយក:*** សាន់ កល្យាណ ***និពន្ធនាយករង:*** ស្វ ប៊ុនស៊ូ ***អ្នកបកប្រែ:*** អេង កុកថាយ ***និពន្ធនាយកទូទៅ:*** ឆាំង យុ ***ក្រាហ្វិកកុំព្យូទ័រ:*** ស៊ឹម សុភ័ក្ត្រ ***គ្រប់គ្រងការចែកផ្សាយ:*** មាស ប៊ុនថាន

*សំបុត្រៈ*

# ចំពោះអ្នកដែលស្លាប់ដោយបុព្វហេតុសេរីភាព

នៅឆ្នាំ១៩៧០ ក្នុងពេលដែលកងទ័ពអាមេរិកមកបោះទីតាំងនៅប្រទេសកម្ពុជា ខ្ញុំទើបតែមានអាយុ៩ឆ្នាំ ។ កាលនោះខ្ញុំស្គាល់កងទ័ពអាមេរិកតាមរយៈទង់ជាតិរបស់សហរដ្ឋអាមេរិក និងរថយន្តហ្ស៊ីបម៉ាក អាឌឺ (A2) ដែលទាហានទាំងនោះប្រើប្រាស់តែប៉ុណ្ណោះ ។ ខ្ញុំបានឃើញទាហានអាមេរិកជិះរថយន្តហ្ស៊ីបដោយមានបំពាក់ទង់ជាតិអាមេរិកជាមួយផង ហើយទិដ្ឋភាពនេះបានក្លាយទៅជានិមិត្តរូបផ្ទាល់ខ្លួនរបស់ខ្ញុំ ។




៣០ឆ្នាំក្រោយមក ទោះបីខ្ញុំមិនមែនជាកុមារកម្ពុជាម្នាក់នៅក្នុងសម័យសង្គ្រាមទៀតក៏ដោយ ក៏ខ្ញុំនៅតែមើលឃើញសហរដ្ឋអាមេរិកក្នុងសភាពដូចគ្នា ។ ទង់ជាតិនេះបានក្លាយទៅជាវត្ថុជាទីគោរពរបស់ខ្ញុំ ហើយព្រោះតែអ្វីដែលវាតំណាងឲ្យ ហើយខ្ញុំក៏បានក្លាយទៅជាពលរដ្ឋម្នាក់រស់នៅសហរដ្ឋអាមេរិក ។ ទង់ជាតិផ្តល់មកឲ្យខ្ញុំនូវសេចក្តីក្លាហាន និងកម្លាំងចិត្តក្នុងការព្យាយាមដណ្តើមយកសេរីភាពនិងយុត្តិធម៌សម្រាប់មនុស្សជាតិ ។ ចំណែករថយន្តហ្ស៊ីបវិញ ជានិមិត្តរូបនៃឯករាជ្យភាព! ។ សប្បុរសធម៌របស់រដ្ឋាភិបាលនិងប្រជាជនអាមេរិកដែលមានមកលើការងារកំពុងធ្វើរបស់យើងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់រូបខ្ញុំផ្ទាល់ គឺជារថយន្តហ្ស៊ីបដែលកំពុងចតនៅលើចិញ្ចើមថ្នល់ ។ ទង់ជាតិនិងរថយន្តជួយផ្តល់មកឲ្យខ្ញុំនូវភាពមានះដើម្បីរស់រានមានជីវិតឆ្លងកាត់សម័យខ្មែរក្រហម ហើយបច្ចុប្បន្នវត្ថុទាំងពីរនេះជួយផ្តល់កម្លាំងចិត្តឲ្យខ្ញុំព្យាយាមស្វែងរកសេរីភាពនិងយុត្តិធម៌ ។

ក្នុងខណៈដែលសម្ព័ន្ធជាតិនៃគ្រួសាររបស់ទាហានអាមេរិកាំងដែលបាត់ខ្លួនក្នុងពេលសង្គ្រាមបានផ្តល់ការដឹងគុណមកឲ្យរូបខ្ញុំ ធ្វើឲ្យខ្ញុំនឹកទៅដល់ឪពុករបស់ខ្ញុំដែលបានស្លាប់នៅក្នុងសម័យសង្គ្រាម ។ ឪពុកជាច្រើននាក់បានស្លាប់នៅក្នុងសមរភូមិប្រយុទ្ធជាមួយខ្មែរក្រហម ហើយបានបន្សល់ទុកនូវសំណួរជាច្រើនដែលប្រពន្ធនិងកូនៗមិនអាចឆ្លើយបាន ។ ជារៀងរាល់ថ្ងៃ ប្រពន្ធនិងកូនរបស់ជនរងគ្រោះតែងតែឆ្ងល់ក្នុងចិត្តអំពីអ្វីដែលបានកើតឡើងចំពោះមនុស្សជាទីស្រលាញ់របស់ខ្លួន ហើយចង់ដឹងថាតើប្តីនិង ឪពុកដែលបានបាត់ខ្លួន ពិតជាត្រូវបានសម្លាប់ឬយ៉ាងណា? តើស្លាប់តាមវិធីណា? ឈឺចាប់ឬទេ? សំណួរដែលពិបាកនឹងទទួលយកបំផុតនោះគឺ តើប្តីនិងឪពុកដែលបានបាត់ខ្លួននោះពិតជាស្លាប់បាត់បង់ជីវិតឬក៏នៅរស់?

ខ្ញុំជឿជាក់ថាសមាជិករបស់សម្ព័ន្ធជាតិនៃគ្រួសាររបស់ទាហានអាមេរិកាំងដែលបាត់ខ្លួនក្នុងពេលសង្គ្រាម ពិតជាមានសំណួរនេះសួរទៅកាន់ខ្លួនឯងជារៀងរាល់ថ្ងៃ ។ បេសកកម្មមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជួយដល់ជនរងគ្រោះឲ្យមានការអស់ចិត្តក្នុងអារម្មណ៍ តាមរយៈការលាតត្រដាងនូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម ។

ដរាបណាអាថ៌កំបាំងដែលទាក់ទងទៅនឹងវាសនារបស់មិត្តភក្តិនិងញាតិសន្តានរបស់យើងនៅតែមិនទាន់បានទម្លាយដរាបនោះ យើងនៅតែព្យាយាមជួយឆ្លើយសំណួរទាំងនេះ ។

សង្គ្រាមបានផុតរលត់ពីទឹកដីនៃប្រទេសកម្ពុជាទៅហើយ ប៉ុន្តែពលិកម្មរបស់អ្នកដែលបានស្លាប់ដោយបុព្វហេតុសេរីភាពនឹងនៅតែត្រូវចងចាំនិងគោរពជានិច្ចដោយរូបខ្ញុំផ្ទាល់ និងដោយប្រជាជនកម្ពុជា ។

**ឆាំង យុ**

# ៣តោនក្នុង១ហិកតា

របបកម្ពុជាប្រជាធិបតេយ្យបានដំណើរការកសាងប្រទេស ដោយផ្អែកលើវិស័យកសិកម្មជាចម្បង នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្លួនពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន ឲ្យទៅរស់នៅតំបន់ជនបទឆ្ងាយៗ ដោយសំអាងហេតុផលពីរគឺ ទីមួយៈ ការពារបដិវត្តន៍កុំឲ្យខ្មាំងវាយពីក្រោយខ្នង និង ទីពីរៈ កម្ចាត់កម្មសិទ្ធិឯកជន ដោះស្រាយជីវភាពប្រជាជន (ឯកសារ D២១៦១៦) ។ បន្ទាប់មកខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការងារជាច្រើនម៉ោងក្នុងមួយថ្ងៃ ។ មនុស្សគ្រប់គ្នាមិនថាចាស់ ឬក្មេងបុរសឬស្ត្រី (លើកលែងតែកុមារដែលមានអាយុក្រោម៥ឆ្នាំ) សុទ្ធតែត្រូវធ្វើការងារដើម្បីប្តូរនឹងរបបអាហារពីរពេលជារៀងរាល់ថ្ងៃ ។ គ្មាននរណាម្នាក់អាចនៅទំនេរដោយបានទទួលរបបអាហារឡើយ ។

អង្គមហាសន្និបាតសេដ្ឋកិច្ចលើកទី១ទូទាំងប្រទេស របស់មជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា នាខែវិច្ឆិកា ឆ្នាំ១៩៧៥ (ដែលចុះផ្សាយនៅក្នុងឯកសារ «ទង់បដិវត្ត លេខពិសេស ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៥») បានសម្រេចជាឯកច្ឆ័ន្ទថាៈ សម្រាប់ឆ្នាំ១៩៧៦ ផលស្រូវទូទាំងប្រទេស គិតជាមធ្យមក្នុង១ហិកតាត្រូវធ្វើឲ្យបានស្រូវ៣តោន ទោះជាធ្វើស្រូវ១រដូវឬធ្វើ២រដូវក្តី ។ អង្គមហាសន្និបាតបានចាត់ទុកសេចក្តីសម្រេចចិត្តនេះជាសេចក្តីសម្រេចរបស់បក្សទាំងមូល ប្រជាជនទាំងមូល និងកងទ័ពបដិវត្តទាំងមូល ។

អង្គមហាសន្និបាតបានលើកឡើងថា «មានសមមិត្តយើងខ្លះចាត់ទុកសេចក្តីសម្រេចចិត្តនេះថាជាធម្មតា សម្រេចបានធូរមិនបាច់ខំទេ ។ ដាក់ជីរថែមខ្លះ រើសពូជឲ្យបានល្អ ម្ចាស់ការលើទឹកទៅ មុខជាបានឬបានលើសទៅទៀត» ។ អង្គមហាសន្និបាតបានវាយតម្លៃការពន្យល់ខាងលើថា «ទស្សនៈនេះគិតតែខាងបច្ចេកទេសជាសំខាន់ ទន់ខ្សោយ អន់ថយ មិនបដិវត្ត ភ្លើងប្រយុទ្ធមិនក្តៅ មិនឆាបឆេះសន្ធោសន្ធៅ ។ ទស្សនៈខុសឆ្គងនេះកើតមកពីគោលជំហរអភិរក្សនិយម មិនឃើញលក្ខណៈសង្គមថ្មី មិនឃើញកម្លាំងដ៏មហិមារបស់សហករណ៍ មិនឃើញស្មារតីប្រយុទ្ធថ្មៃប្រឌិតរបស់បងប្អូនកសិករ មិនឃើញតួនាទីដឹកនាំរបស់បក្ស» ។

អង្គមហាសន្និបាតបានពន្យល់ខ្លឹមសារនៃសេចក្តីសម្រេចរបស់បក្សថា «៣តោនក្នុង១ហិកតា មានន័យខាងទស្សនៈគោលជំហរ សតិអារម្មណ៍ និងការអនុវត្តជាក់ស្តែងធំទូលាយ ហើយជ្រាលជ្រៅ ។ ដូច្នេះ ការក្តាប់ ការជ្រួតជ្រាបនូវសេចក្តីសម្រេចចិត្តរបស់បក្ស មិនមែនក្តាប់តែតួលេខ ក្តាប់បច្ចេកទេសតែម្យ៉ាងនោះទេ ។ ត្រូវក្តាប់ន័យសារសំខាន់របស់វា ជាទស្សនៈជាគោលជំហរ ជាសតិអារម្មណ៍ និងចាត់តាំង ក្នុងឋានៈដឹកនាំប្រយុទ្ធវាយសំរុក ទាំងយុទ្ធវិធី ទាំងយុទ្ធសាស្ត្រ ។ ត្រូវចាត់ទុកសេចក្តីសម្រេច៣តោនក្នុង១ហិកតាថាជាភារកិច្ចមួយដែលមានសារសំខាន់ក្នុងការពង្រឹងរដ្ឋអំណាចបដិវត្ត និងផ្តាច់ការវណ្ណៈអធនរបស់បក្ស ក្នុងជំហានដំបូងនៃបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមនៅប្រទេសកម្ពុជា» ។

នៅក្នុងខ្លឹមសារនៃសេចក្តីសម្រេចចិត្តរបស់បក្សនៅក្នុងអង្គមហាសន្និបាតទូទាំងប្រទេសលើកទី១ កាលពីខែវិច្ឆិកា ឆ្នាំ១៩៧៥ «៣តោនក្នុង១ហិកតា» មានន័យជាក់ស្តែងជារូបិយដូចតទៅ÷

«១)មានន័យបន្តការតស៊ូប្រឆាំងចក្រពត្តិ ពិសេសចក្រពត្តិអាមេរិកនិងបរិវាររវា ដែលវានៅរក្សាជានិច្ចនូវបំណងអាក្រក់ជាយុទ្ធសាស្ត្រ បំផ្លាញបដិវត្តយើង បំផ្លាញការកសាងប្រទេសជាតិយើង ហើយយកកម្ពុជាយើងធ្វើជារណបវាទៀត ។ ៣តោនក្នុង១ហិកតាជាភារកិច្ចមួយសម្រាប់ពង្រឹងកិច្ចការពារប្រទេសរបស់យើងជាក់ស្តែង ។

២) មានន័យបន្តការតស៊ូវណ្ណៈឲ្យកាន់តែខ្លាំងក្លាថែមទៀតក្នុងដំណាក់កាលថ្មីនៃបដិវត្តសង្គមនិយម និងកសាងសង្គមនិយម ដោយបន្តកម្ទេចឲ្យសាបសូន្យជាស្ថាពរនូវវណ្ណៈនិងរបបសក្តិភូមិ

ម្ចាស់ដីនិងនាយទុន កុំឲ្យវាមានឱកាសងើបក្បាលមកធ្វើជាបង្អែកឲ្យចក្រពត្តិ ដណ្តើមយករដ្ឋអំណាចពីកម្មករកសិករយើងវិញបាន ។

៣) មានន័យពង្រឹងនិងពង្រីកមហាសាមគ្គីជាតិទាំងមូលក្នុងសង្គមកម្ពុជាសមូហភាពដែលគ្មានអ្នកមានគ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេនិងវណ្ណៈត្រូវគេជិះជាន់ សុខដុមរមនា បំពេញភារកិច្ចការពារប្រទេសនិងកសាងប្រទេស ផ្អែកលើកម្លាំងសម្ព័ន្ធភាពកម្មករកសិករ ក្រោមការដឹកនាំរបស់បក្ស ។

៤) មានន័យក្នុងការរៀបចំគ្រឹះជាដំបូងខាងកសិកម្ម ដើម្បីធ្វើជាបង្អែកក្នុងការកសាងសេដ្ឋកិច្ចរបស់បក្ស ក៏ដូចជាកសាងប្រទេសទាំងមូលលើគ្រប់ផ្នែក ។

៥) មានន័យក្នុងការពង្រឹងគោលជំហរឯករាជ្យម្ចាស់ការខ្លួនឧបត្ថម្ភខ្លួន ខ្លួនក្តាប់វាសនាជាតិខ្លួនដោយខ្លួនឯង ឲ្យកាន់តែរឹងប៉ឹងថែមទៀត ក្នុងដំណាក់កាលថ្មីនៃបដិវត្តសង្គមនិយម និងកសាងសង្គមនិយម ។ បញ្ហានេះយើងចាំបាច់ពង្រឹងជាបន្តបន្ទាប់ពង្រឹងគ្រប់ដំណាក់កាលនៃបដិវត្តន៍របស់យើង ។ ៣តោនក្នុង១ហិកតាជាសញ្ញាសម្គាល់ជាក់ស្តែងមួយបញ្ជាក់ឲ្យឃើញនូវភាពរឹងប៉ឹងនៃគោលជំហរឯករាជ្យម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនរបស់បក្សប្រជាជន និងកងទ័ពបដិវត្តយើង ។

៦) ៣តោនក្នុង១ហិកតាសម្រាប់ឆ្នាំ១៩៧៦មានន័យជាក់ស្តែងក្នុងការពង្រឹងនិងពង្រីកសហករណ៍ជាបន្តបន្ទាប់ ហើយសម្រាប់រៀបចំលក្ខណៈសម្បត្តិទៅអនាគត កសាងភូមិថ្មីរបស់កសិករ របស់សមូហភាពយើង ។ ដែលថាពង្រឹងពង្រីកសហករណ៍នេះគឺបានសេចក្តីថា កសាងសហករណ៍ទាំងគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។

៧) ៣តានក្នុង១ហិកតា ក្រោយពីទើបឈ្នះសង្គ្រាមឈ្លានពាន យ៉ាងសាហាវបំផុតមិនដល់២ឆ្នាំផង ហើយខំដោយខ្លួនឧបត្ថម្ភខ្លួនយ៉ាងនេះ វានឹងលើកកិត្យានុភាពរបស់បក្ស បដិវត្តន៍ប្រជាជន និងកងទ័ពបដិវត្តន៍របស់យើង យ៉ាងខ្ពស់ត្រដែតនៅលើឆាកអន្តរជាតិ ។ កិត្យានុភាពនេះមិនមែនកិត្យានុភាពខាងរស់នៅសម្បូរហូរហៀរប្រណិតភាពនោះទេ ព្រោះ៣តោនក្នុង១ហិកតា នៅមិនទាន់ធ្វើឲ្យប្រទេសយើងចេញផុតពីកសិកម្មឱនថយទៅកាន់កសិកម្មសម័យនៅឡើយទេ ។ តែកិត្យានុភាពនេះចង់និយាយពីកិត្យានុភាពខាងការប្រយុទ្ធស៊ូទ្រាំលំបាកវេទនាក្នុងការរៀបចំលក្ខណៈសម្បត្តិចាក់គ្រឹះកសាងសង្គមសមូហភាពរបស់យើង ដោយស្មារតីខ្លួនឧបត្ថម្ភខ្លួនក្រោមការដឹកនាំរបស់បក្ស ។

៨) ៣តោនក្នុង១ហិកតាសម្រាប់ឆ្នាំ១៩៧៦មានន័យសំខាន់ណាស់ចំពោះតួនាទីដឹកនាំរបស់បក្សយើង ។ បក្សយើងធ្លាប់មានថ្វីដៃមហាអស្ចារ្យក្នុងការដឹកនាំធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិប-តេយ្យ ដណ្តើមមហាជ័យជំនះយ៉ាងឆាប់រហ័សលោតផ្លោះ ។ ក្នុងដំណាក់កាលថ្មីនៃបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមនេះទៀត សេចក្តីសម្រេចចិត្តរបស់បក្សជាលើកដំបូងកំណត់៣តោនក្នុង១ហិកតាសម្រាប់ឆ្នាំ១៩៧៦ ជាសំឡេងអំពាវនាវយ៉ាងមានខ្លឹមសារធំទូលាយនិងជ្រាលជ្រៅបំផុតសម្រាប់បក្ខជននៃបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងនិងភ្លឺស្វាងទាំងអស់ សម្រាប់វណ្ណៈកម្មករកសិករទាំងអស់ សម្រាប់កងទ័ព បដិវត្តន៍ទាំងបីប្រភេទក្រោមការដឹកនាំរបស់បក្ស ដុតដំរាយ ប្រយុទ្ធសំរុកលើកទង់មហាសាមគ្គី-មហាឯកភាពផ្ទៃក្នុងសំរេចឲ្យបានផលស្រូវ៣តោនក្នុង១ហិកតាសម្រាប់ឆ្នាំ១៩៧៦ ។»

ក្រៅពីនេះ ផែនការសម្រាប់ឆ្នាំតទៅមុខទៀតដែលអង្គសន្និបាតបានដាក់ចេញគឺ÷

- ◆ ឆ្នាំ១៩៧៧ ធ្វើឲ្យបាន៤ឬ៥តោនក្នុង១ហិកតា
- ◆ ឆ្នាំ១៩៧៨ ធ្វើឲ្យបាន៦ឬ៧តោនក្នុង១ហិកតា

ផែនការការងារដែលកម្ពុជាប្រជាធិបតេយ្យបានដាក់ចេញតាមរយៈសន្និបាតទូទាំងប្រទេសលើកទី១នេះ បង្ហាញពីការធ្វើបដិវត្តន៍តាមជំហានមហាលោតផ្លោះមហាអស្ចារ្យ ។ គោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យនេះបានធ្វើឲ្យប្រជាជនកម្ពុជាជាច្រើននាក់ត្រូវស្លាប់ដោយអត់អាហារនិងធ្វើការបាក់កម្លាំង ក្នុងអំឡុងពេល៣ឆ្នាំនៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។

**សាន់ កល្យាណ**

# បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ២៦២ | ត្រឹង ធីប៉ែរ (ស្រី) | យួន | ចារកិច្ចយួន | និរតី | ១២-១០-៧៨ | ២៣-១០-៧៨ |
| ២៦៣ | ត្រឹង ធីដៀង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ២៣-១០-៧៨ |
| ២៦៤ | ង្វៀង ទឿងឡាយ | យួន | ប៊ីញញ៉ីធីវគី | ត្បូសាន | ១៧-១០-៧៨ | ២០-១០-៧៨ |
| ២៦៥ | លី ធីបៀត (ស្រី) | យួន | ចារកិច្ចយួន | កំពង់សោម | ២៥-៩-៧៨ | ២០-១០-៧៨ |
| ២៦៦ | ង្វៀង ថិតដុង | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ២០-១០-៧៨ |
| ២៦៧ | ត្រឹង យ៉ាំងទ្រៀង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ២០-១០-៧៨ |
| ២៦៨ | ឡេ សឺនយុង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៧-៩-៧៨ | ២០-១០-៧៨ |
| ២៦៩ | ឡេ យ៉ាំងវើ | យួន | ចារកិច្ចយួន | និរតី | ១២-១០-៧៨ | ២០-១០-៧៨ |
| ២៧០ | ង្វៀង ធីហ៊ា (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១០-៧៨ | ២០-១០-៧៨ |
| ២៧១ | ដាង យ៉ាំងបា | យួន | ចារកិច្ចយួន | និរតី | ៦-៩-៧៨ | ៣១-១០-៧៨ |
| ២៧២ | ត្រឹង វ៉ាន់ថាញ់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-៩-៧៨ | ៣១-១០-៧៨ |
| ២៧៣ | កាវ កឿន | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៧-៩-៧៨ | ៣១-១០-៧៨ |
| ២៧៤ | ដាង វ៉ាន់ដឿង | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៧-៩-៧៨ | ៣១-១០-៧៨ |
| ២៧៥ | ត្រឹង យ៉ាំងឡង់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៧-៩-៧៨ | ៣១-១០-៧៨ |
| ២៧៦ | វិន យ៉ាំងអ៊ី | យួន | ចារកិច្ចយួន | និរតី | ១២-១០-៧៨ | ៣១-១០-៧៨ |
| ២៧៧ | ឡេ យ៉ាំងកែវ | យួន | ចារកិច្ចយួន | និរតី | ១២-១០-៧៨ | ៣១-១០-៧៨ |
| ២៧៨ | ង្វៀង យ៉ាំងអាន់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១០-៧៨ | ៣១-១០-៧៨ |
| ២៧៩ | ង្វៀង យ៉ាំងយិន | យួន | ចារកិច្ចយួន | និរតី | ២៨-១០-៧៨ | ៣១-១០-៧៨ |
| ២៨០ | ត្រឹង យ៉ាំងហ៊ាក | យួន | ចារកិច្ចយួន | ស្វាយរៀង | ៣០-១០-៧៨ | ៣១-១០-៧៨ |
| ២៨១ | ឡេ ធីវើ (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ៣០-៨-៧៨ | ១៤-១០-៧៨ |
| ២៨២ | ដ៊ូ វ៉ាំងខាំង | យួន | ប៊ីញញី | ស្វាយរៀង | ២-៩-៧៨ | ១៤-១០-៧៨ |
| ២៨៣ | ឡេ ធីធ៊ី | យួន | ប៊ីញញី | ស្វាយរៀង | ៥-៩-៧៨ | ១៤-១០-៧៨ |
| ២៨៤ | ត្រឹង យ៉ាំងដេវ | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៨៥ | ង្វៀង វ៉ាន់សាវ | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៨៦ | ង្វៀង យ៉ាំងឌឹក | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៨៧ | ង្វៀង សាំងហាយ | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៨៨ | ដាម វ៉ាន់ទី | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៨៩ | ង្វៀង វ៉ាន់ទី | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៩០ | ង្វៀង កុងវៀង | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |

(នៅមានត)

ឯកសារបបកម្ពុជាប្រជាធិបតេយ្យ (ប្រភេទទូរសារ)

ទូរលេខៈ ៣៨

៨២៥ៈ ខ្ទង់

# បងជាធីគោរពស្នេហា

នៅថ្ងៃ ១០-២ យើងខ្ញុំបានទៅធ្វើការជាមួយសមមិត្ត សូដាន់ អនុរដ្ឋមន្ត្រីក្រសួងការបរទេស យើងខ្ញុំបានលើកយកមតិណែនាំរបស់បងមកជំរាបគេ គេស្តាប់យើងច្រើន។

យើងខ្ញុំនិយាយចប់ គេនិយាយតបមកវិញថា ធ្វើឲ្យគេកាន់តែយល់ពីទស្សនៈគោលជំហរកម្ពុជាមានចំពោះឡាវ។

រដ្ឋាភិបាលឡាវពេលណាក៏គេចាត់ទុកកម្ពុជាជាមិត្តរបស់ខ្លួន។ ហើយរដ្ឋាភិបាលយើងខ្ញុំមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង មិនជ្រៀតជ្រែកកិច្ចការប្រទេសដទៃ និងទំនាស់រវាងកម្ពុជា-វៀតណាមទេ ហើយក៏មិនមែនធ្វើជាអ្នកសំរុះសំរួលបញ្ហានេះដែរ មានតែរក្សាមិត្តភាពដែលមានមកហើយនោះឱយកាន់តែល្អថែមទៀត។ តែគេចង់ឲ្យកម្ពុជានឹងវៀតណាមជួបចរចាគ្នា ដើម្បីឲ្យមានសន្តិភាពឡើងវិញ ក្នុងគោលការណ៍ស្មើគ្នា ពីព្រោះកម្ពុជានិងយួនជាមិត្តរបស់គេ។

គេក៏បានឆ្លើយបញ្ជាក់សេចក្តីមករឿងដែលឱយគេដកកងទ័ពយួនចេញពីព្រំដែននោះថា ÷

បើតាមពិនិត្យរាល់មូលដ្ឋាន មិនឃើញកងទ័ពយួនបោះនៅព្រំដែនកម្ពុជា-ឡាវទេ គេថា រដ្ឋាភិបាលគេក៏មានសិទ្ធិអំណាចឱយបរទេសមកជួយការពារនូវទឹកដី និងជួយកសាងប្រទេសគេដែរ ប៉ុន្តែរដ្ឋាភិបាលគេក៏មិនអនុញ្ញាតឱយបរទេសណាមួយប្រើប្រាស់ទឹកដីខ្លួនទៅឈ្លានពានលើប្រទេសណាមួយទៀតជាដាច់ខាត។ ហើយនៅតាមព្រំដែនកម្ពុជា-ឡាវមិនដែលកើតរឿងអីនឹងគ្នាទេ តាំងពីធ្វើការតស៊ូជាមួយបារាំងក៏ដូចអាមេរិកដែរ ហើយមិនដែលបានជួបពិភាក្សាគ្នាទៀតផង ប្រជាជននឹងប្រជាជនក៏មានការទាក់ទងគ្នាបានល្អ។

តែមកដល់សព្វថ្ងៃ ប្រជាជនមានការលំបាកខ្វះនៅតាមព្រំដែននៃប្រទេស តែក៏ជារឿងតូចតាចមួយ ហើយយើងទាំងសងខាងត្រូវតែយល់គ្នា ហើយបើកើតមានបញ្ហាត្រូវតែដោះស្រាយជាមួយគ្នា ដើម្បីកុំឱយកើតមានបញ្ហាធំៗ បើការពារផាប់ក្រឡាពេកក៏រក្សាមិត្តភាពមិនបានយូរដែរ។

យើងខ្ញុំបានបញ្ជាក់វិញថា មិត្តឡាវគេយល់ពីទស្សនៈគោលជំហររបស់រដ្ឋាភិបាលកម្ពុជាយើងខ្ញុំដែលមានចំពោះប្រជាជននិងរដ្ឋាភិបាលឡាវ ហើយដែលយើងត្រូវតែខំរក្សាមិត្តភាពនេះឱយបានរឹងប៉ឹងកុំឱយវណ្ណៈនាយទុនណាបំបែកបាន។ ឯសេចក្តីប្រកាសរបស់រដ្ឋាភិបាលវៀតណាមទាំងមុនទាំងក្រោយស្នើឲ្យមានការចរចានោះ គឺជាឧបាយកល "ចោរស្រែកចាប់ចោរ" តែប៉ុណ្ណោះ ហើយក៏ដើម្បីបិទបាំងការបរាជ័យខាងនយោបាយខាងយោធារបស់វា ហើយត្រៀមរៀបចំវាយលុកថ្មីម្តងទៀតទៅលើកម្ពុជាយើងខ្ញុំ។

ដូច្នេះ យួនគ្មានស្មោះនឹងកម្ពុជាយើងខ្ញុំទេ គឺគេនៅតែបន្តវាយលុកចូលទឹកដីកម្ពុជាជាប់ជានិច្ច ក្នុងទិសដៅសហព័ន្ធឥណ្ឌូចិនរបស់ពួកគេ។

គេនិយាយថែមទៀតថា បើមានជនណាធ្វើសកម្មភាពរំលោភមកលើកម្ពុជា ត្រូវចាប់មុខឲ្យគេ ជាជនជាតិឡាវក្តី ឬជនជាតិបរទេសក្តី។

**កំណត់សំគាល់ៈ** ក្នុងជួបគ្នា អាកប្បកិរិយាគេមិនរាបសាប៉ុន្មានទេ ហើយគេមិនសូវជឿយើងថាមិនបានបង្កើតឱយមានបញ្ហាព្រំដែននោះទេ ទាំងលើកមុននិងលើកក្រោយ ពីព្រោះគេគ្មានហេតុផលអីបញ្ជាក់។ ដើម្បីយើងពេលវាយយួនឈ្លានពានសិន។

យើងខ្ញុំសូមស្នើមតិណែនាំរបស់បង នឹងស្នើមានវិធានការជាក់ស្តែងមួយចំនួនដូចខាងក្រោមនេះ ÷

១) ដើម្បីឱយកាន់តែយល់គ្នា ត្រូវមានហេតុផលច្បាស់លាស់ សកម្មភាពដែលចេញពីព្រំដែនឡាវ-កម្ពុជា ហើយឱយយើងខ្ញុំក្តាប់បានចេះដឹងផង ដើម្បីងាយស្រួលធ្វើការតវ៉ាជាមួយ

គេតាមដាក់ស្តែងរួមនឹងទីក្រុងរបស់យើងមានចំពោះគេ ។

(២) ដើម្បីឱ្យគេជ្រះស្រឡះ រដ្ឋាភិបាលទាំងពីរគួរផ្តៀតឱកាសជួបពិគ្រោះគ្នាដើម្បីសំរុះសំរួលបញ្ហាព្រំដែនដែលឡាវលើកនោះ ។

(៣) ដើម្បីពន្យារទំនាស់ឱ្យកាន់តែយូរទៅទៀតជាមួយឡាវគួរតែមានថ្នាក់ប្រតិភូរដ្ឋាភិបាល គណៈប្រតិភូរដ្ឋាភិបាល ឬអង្គការមហាជន ទៅទស្សនកិច្ចនៅឡាវ ។

(៤) យើងខ្ញុំនឹងស្នើជួបអ្នកដឹកនាំគេទៀត ដើម្បីនិយាយឱ្យគេយល់ពីទស្សនៈគោលជំហរយើងថែមទៀត ។

ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត

ថ្ងៃ ១១-២-៧៨

រដ្ឋ

ទទួលថ្ងៃ ១៣-២-៧៨ ម៉ោង ១៣:១០

ចម្លងជូនៈ អ៊ំ អ៊ំនួន បងវ៉ាន់ បងវន មន្ទីរ ឯកសារ

## ពន្យល់ពាក្យខ្មែរក្រហម

◆ **បដិវត្តន៍:** បដិសន្ធិនឹងការវិវត្ត ឬរំលំវណ្ណៈមួយកសាងវណ្ណៈមួយ ។

◆ **គោលនយោបាយ:** ទិសដៅដំណើរការបដិវត្តន៍ឬការវិវត្ត ។

◆ **មាគ៌ានយោបាយ:** សេចក្តីផ្តើមគំនិត ។

◆ **នយោបាយ:** សេចក្តីប្រៀបធៀបនឹងការវែកញែកបំភ្លឺផ្លូវដាក់ស្តែងមិនដាក់ស្តែង ។

◆ **មនោគមវិជ្ជា:** សេចក្តីជំនឿផ្សេងៗ ។

◆ **សេរីនិយម:** ធ្វើការអ្វីតាមទំនើងចិត្ត ។

◆ **ឯកចិត្តនិយម:** ធ្វើតែឯកឯង ។

◆ **អចេតនា:** គឺមិនបានប្រព្រឹត្ត ។

កំណត់ហេតុ (TSL N-97, N-11 លេខៈ១០)



អៀង សារី និង ខៀវ សំផន ជួបសំណេះសំណាលជាមួយគណៈប្រតិភូឡាវ

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៦៣០ | ញ៉ែម យុាំ | ពលទោ | កំពង់សោម | ៧-៥-៧៦ | ៤-៦-៧៦ |
| ៦៣១ | យិន គីមយង់ | កាប៉ូរ៉ាល់សេហ្ | ពោធិសាត់ | ១-១-៧៦ | ៤-៦-៧៦ |
| ៦៣២ | សឿង ទ្រឹង | ពលទោ | កំពង់សោម | ៧-៥-៧៦ | ៤-៦-៧៦ |
| ៦៣៣ | សេង សារឿន | សក្តិ១ | កំពង់សោម | ២៨-៥-៧៦ | ៤-៦-៧៦ |
| ៦៣៤ | ឈិត គីមឈាង ហៅ សារ៉ុម | ស្នងការប៉ូលិស | កំពង់ធំ | ៥-២-៧៦ | ៤-៦-៧៦ |
| ៦៣៥ | ប្រាង មួង | អនុក្រុម | ពោធិចិនតុង | ២៧-៤-៧៦ | ៤-៦-៧៦ |
| ៦៣៦ | ឈិត អ៊ីវ ហៅ ឆាត | ស្នងការប៉ូលិស | កំពង់ធំ | ១៩-២-៧៦ | ៥-៦-៧៦ |
| ៦៣៧ | អ៊ូច សារិន | មេក្រុម | កំពង់សោម | ៧-៥-៧៦ | ៦-៦-៧៦ |
| ៦៣៨ | ម៉ែន អុល | សេដ្ឋកិច្ចដោះលែង | តាខ្មៅ | ? | ៩-៦-៧៦ |
| ៦៣៩ | ប៉ាត ស៊ិន | ប្រជាជន | កំពង់ឆ្នាំង | ២២-២-៧៦ | ១០-៦-៧៦ |
| ៦៤០ | សែម ប៊ិន | យុទ្ធជន | កំពង់សោម | ១៦-៥-៧៦ | ១០-៦-៧៦ |
| ៦៤១ | អៀក លុន | ប្រជាជន | តំបន់២៥ | ២០-៣-៧៦ | ១០-៦-៧៦ |
| ៦៤២ | ម៉ាត់ អ៊ែល | ប្រជាជន | បាត់ដំបង | ១៣-២-៧៦ | ១០-៦-៧៦ |
| ៦៤៣ | ឈុន ហួយ | រត់រ៉ឺម៉កម៉ូតូ | កំពង់សោម | ៧-៥-៧៦ | ១០-៦-៧៦ |
| ៦៤៤ | សំរិត ចក់ | កម្មករបម្កាវដូង | កំពង់សោម | ៧-៥-៧៦ | ១០-៦-៧៦ |
| ៦៤៥ | ញូង សាម៉ុន | ប្រជាជន | តំបន់៣៣ | ៦-២-៧៦ | ១០-៦-៧៦ |
| ៦៤៦ | ប៊ុន ចាន់រដ្ឋាក | សុភាគារខ្មែរ | តំបន់១៥ | ២៩-៣-៧៦ | ១០-៦-៧៦ |
| ៦៤៧ | ប៊ុន សុង ហៅ សាន | ប្រធានមន្ទីរក-១៥ | បឹងត្របែក | ២៩-១២-៧៥ | ១០-៦-៧៦ |
| ៦៤៨ | រ៉េះ យូណុស | ចោរព្រៃ | តំបន់៣៧ | ២០-៥-៧៦ | ១០-៦-៧៦ |
| ៦៤៩ | ប៉ាវ ប៊ុនប្រេញ ហៅ សំ | ជំនួយវរសេនាធំ | កងពល៧០៣ | ១-៨-៧៥ | ១១-៦-៧៦ |
| ៦៥០ | យឹម យូវ៉ាង | វិស្វករ | បាត់ដំបង | ១-១-៧៦ | ១១-៦-៧៦ |
| ៦៥១ | នួ៊វ លាប | គ្រូបង្រៀន | កំពង់ចាម | ៥-១-៧៦ | ១១-៦-៧៦ |
| ៦៥២ | នូវ ផាត់ | ជំទប់លេខ៣ | តំបន់២៥ | ១២-៣-៧៦ | ១១-៦-៧៦ |
| ៦៥៣ | ខូវ សុងយុន | សាស្ត្រាចារ្យ | តំបន់២៥ | ២-២-៧៦ | ១១-៦-៧៦ |
| ៦៥៤ | គឹម ផាន | គ្រូបង្រៀន | តំបន់៣៣ | ២៥-២-៧៦ | ១១-៦-៧៦ |
| ៦៥៥ | ដូ ម៉េង | លក់ត្រីចំហុយ | ពោធិសាត់ | ២៦-២-៧៦ | ១១-៦-៧៦ |
| ៦៥៦ | ឡាច ហុង ហៅ ស្រ៊ី | រោងចក្រក្លាងអា | តំបន់៣៣ | ៣-៥-៧៦ | ១១-៦-៧៦ |
| ៦៥៧ | ម៉ក់ ហ៊ឹម ហៅ អួន | ប្រជាជនថ្មី | តំបន់២២ | ២-៨-៧៥ | ១១-៦-៧៦ |
| ៦៥៨ | លុន ហុក | និស្សិត | បែកចាន | ២-១០-៧៥ | ១១-៦-៧៦ |

(នៅមានត)

# ដំណើរឆ្លងកាត់តំបន់ខ្មែ






**(តចប់)**

អង្គការខ្មែរក្រហមចាត់ទុកការផ្សារពលកម្មជាជំហរទីមួយ គឺក្នុងគោលបំណង៖

១) ក្រុបខ័ណ្ឌនិងសមាជិករបស់គេគ្រប់ជាន់ថ្នាក់ត្រៀមខ្លួនចំពោះការពិបាកផ្សេងៗ ទៅថ្ងៃក្រោយ ឲ្យមានទម្លាប់ស្រឡាញ់ការផ្សារពលកម្មនេះ ដែលជាគោលការណ៍ដ៏សំខាន់ សម្រាប់ឈានទៅកសាងប្រជាជាតិសង្គមនិយម (une nation socialiste) ។

២) ឲ្យសមាជិកនិងក្រុបខ័ណ្ឌរបស់គេជិតស្និទ្ធនឹងប្រជាជន ស្គាល់សំណូមពរនិងទុក្ខធុរៈប្រជាជន ព្រមទាំងឆ្លៀតរៀនសូត្រពីប្រជាជន ។ នៅលើផ្នែកបច្ចេកទេសនៃការផ្សារ "ប្រជាជនជាប្រភពនៃចំណេះវិជ្ជាមិនចេះរីងស្ងួត" ។

៣) បណ្តុះផ្នត់ស្មារតីគោរពអង្គការវិន័យរបស់ពួកគេ របស់ក្រុម តាមលំនាំវិន័យសម្ភារនិយម (Discipline matérialiste) របស់ពួកកម្មកររោងចក្រ ។

◆ ឲ្យសមាជិកឬក្រុបខ័ណ្ឌម្នាក់ៗ"លត់ដំ"ខ្លួន ដើម្បីជម្រុះ "ធាតុ" មិនបដិវត្តន៍ មិនកម្មាជីព ដូចជា "ធាតុ" របស់បញ្ញវ័ន្តភាគច្រើនជាដើម ។ បើមិនបានជាប់ខ្លួននឹងពលកម្មទេ បុគ្គលនោះពុំចេះស្រឡាញ់ប្រជាជនទេ នៅតែមានសតិអារម្មណ៍ជិះជាន់ពលកម្មរបស់អ្នកដទៃ ដែលជាសតិអារម្មណ៍របស់ពួកប្រតិកិរិយា របស់សក្តិភូមិ របស់ពួកមូលធន ។

តាមទ្រឹស្តីសម្ភារនិយម មានតែពួកកម្មករកម្មាជីពទេដែលជាអ្នកកសាងពិភពលោក កសាងសង្គមនីមួយៗ ។ វណ្ណៈកម្មករនិងកម្មាជីពនេះមានចំនួនច្រើនជាងគេទាំងអស់នៅក្នុងសង្គមនីមួយៗ ។ ដូច្នេះ តាមលក្ខណៈប្រជាធិបតេយ្យ មិនគួរឡើយរដ្ឋអំណាចមិនបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់វណ្ណៈនេះ ។ នេះជាទស្សនៈរបស់ពួកម៉ាក្ស៊ីស-ឡេនីនិស្ត ។

៤) បណ្តុះស្មារតីសម្ភារនិយម ប្រាកដនិយម វិទ្យាសាស្ត្រនិយម តាមគន្លងម៉ាក្ស៊ីស-ឡេនីនិស្ត បំបាត់ទស្សនៈគំនិតនិយម (Idéalisme) ដែលបម្រើវណ្ណៈប្រតិកិរិយា វណ្ណៈជិះជាន់ (នេះជាទស្សនៈរបស់ពួកខ្មែរក្រហម) ។ ម្យ៉ាងទៀត ការផ្សារពលកម្មនេះជាឱសថមួយជួយបំបាត់សតិអារម្មណ៍ឬទស្សនៈចង្អៀតចង្អល់ផងដែរ (Etroitesse de vue) ។

### ការអប់រំនយោបាយ

ខ្មែរក្រហមមានការចាប់អារម្មណ៍ខ្លាំងណាស់ទៅលើការអប់រំនយោបាយ ។ កម្លាំងនយោបាយជាកម្លាំងទីមួយរបស់គេ កម្លាំងយោធាគ្រាន់តែជាឧបករណ៍នៃកម្លាំងនយោបាយ ។ សមាជិកខ្មែរក្រហមគ្រប់ក្រុបខ័ណ្ឌត្រូវទទួលការអប់រំនយោបាយជាចាំបាច់ ។ គេរៀនសូត្រនៅតាមសាលារៀននយោបាយនៅតាមមន្ទីរ ពេលធ្វើមីទីង ធ្វើសន្និបាត ពេលប្រជុំជីវភាពជាដើម ។

◆ ការអប់រំនៅតាមសាលារៀននយោបាយ អង្គការខ្មែរក្រហមសព្វថ្ងៃនៅខ្វះកម្មាភិបាល (ក្រុបខ័ណ្ឌ) ប្រកបដោយគុណសម្បត្តិនិងវប្បធម៌នយោបាយច្រើនណាស់ ។ លោក ហ៊ូ យន់ ខ្លួនឯងក៏បានសារភាពរឿងនេះនៅក្នុងមហាសន្និបាតបញ្ញវ័ន្តនៅចុងខែឧសភា ១៩៧២ ផងដែរ ។ កម្មាភិបាលម្នាក់ៗ មុននឹងទៅកាន់នាទីទទួលខុសត្រូវណាមួយ ត្រូវទទួល

ការហ្វឹកហ្វឺនអប់រំអស់ពេលដ៏យូរពីមួយឆ្នាំទៅបីឆ្នាំយ៉ាងតិច ហើយធ្លាប់ជាប់បម្រើចលនារបស់គេមកយូរហើយផង នៅ "យុវកក" (យុវជនកុម្មុយនិស្តកម្ពុជា) ឬនៅក្នុង "សនកប" (សមាគមនារីកម្ពុជាប្រជាធិបតេយ្យ) ។

កម្មាភិបាលម្នាក់ៗត្រូវមានសីលធម៌រស់នៅនិងសីលធម៌នយោបាយស្អាតស្អំ គឺៈ

១) ស្រឡាញ់ គោរព និងបម្រើប្រជាជន កម្មករ កសិករឲ្យអស់ពីចិត្តពីថ្លើម មិនប្រើអំណាចផ្តាច់ការទៅលើប្រជាជន មិនគំរាមកំហែងប្រជាជន ត្រូវសុភាពរាបសាទន់ភ្លន់ទៅរកប្រជាជនជានិច្ច ។

២) ស្មោះត្រង់និងការពារផលប្រយោជន៍ប្រជាជនជាដាច់ខាត មិនធ្វើអ្វីឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិប្រជាជន សូម្បីតែម្ជុលមួយផ្លែឬអង្ករមួយកំប៉ុងក៏ដោយ មិនគំរាមកំហែងយកទ្រព្យសម្បត្តិប្រជាជន ទោះជាតាមមធ្យោបាយក្តៅឬត្រជាក់ក៏ដោយ ។ មិនត្រូវស៊ីសំណូកសូកប៉ាន់ពីប្រជាជន ។

៣) បើធ្វើអ្វីខុសចំពោះប្រជាជន ត្រូវសុំទោសប្រជាជន ។

៤) និយាយស្តី ដេក ដើរ ឈរ អង្គុយ ស៊ីចុក លេងសើចដោយសុភាពរាបសាតាមប្រពៃណីប្រជាជន ។

៥) កុំប្រព្រឹត្តអំពើល្មើសចំពោះនារីភេទ ។

៦) កុំផឹកស៊ីអ្វីដែលមានលក្ខណៈពាលាអាវ៉ាសែមិនបដិវត្ត ។

៧) កុំលេងល្បែងស៊ីសងឲ្យសោះ ។

៨) កុំប៉ះពាល់លុយកាក់ទ្រព្យសម្បត្តិរួមរបស់ប្រជាជនរបស់អង្គការ ។

៩) ត្រូវមានកំហឹងឆាបឆេះចំពោះខ្មាំង ។

១០) ត្រូវធ្វើពលកម្មដូចប្រជាជន ។

១១) ត្រូវគោរពមតិរបស់សមូហភាពអង្គការជានិច្ច ។ មិនត្រូវធ្វើការតាមរបៀបផ្តាច់ការរបស់បុគ្គលម្នាក់ឡើយ ។

១២) ត្រូវធ្វើការទិតៀននិងស្វ័យទិតៀនឲ្យបានល្អជានិច្ចក្នុងអង្គការរណសិរ្សដោយស្មារតីស្មោះត្រង់ ចងកសាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងឲ្យបានរឹងប៉ឹងជាលំដាប់ មិនត្រូវវាយប្រហារគ្នាក្រៅអង្គការ ឬនិយាយចាក់ចុចដណ្តើមឥទ្ធិពលគ្នាឡើយ ។

១៣) ត្រូវមានស្មារតីភ្ញាក់រឭកធ្វើបដិវត្តន៍ដោយខ្លួនឯង មិនត្រូវពឹងផ្អែកលើអ្នកដទៃឬបរទេសឲ្យគេធ្វើជំនួសខ្លួនឡើយ ។ ត្រូវយល់ឲ្យច្បាស់ថា បដិវត្តន៍នេះជាបដិវត្តន៍របស់ប្រជាជនកម្ពុជា ត្រូវតែប្រជាជនកម្ពុជាធ្វើដោយខ្លួនឯង និងកាន់កាប់វាសនាប្រទេសជាតិដោយខ្លួនឯង មិនដេកពឹងពាក់បរទេសឲ្យគេធ្វើជំនួសទេ ។

១៤) ត្រូវមានស្មារតីម្ចាស់ការ ចេះដោះស្រាយគ្រប់បញ្ហាដែលទាក់ទងដល់ជីវភាពខាងស្មារតី ខាងសម្ភារៈ របស់ប្រជាជន ។

១៥) ត្រូវជឿជាក់ថា ការតស៊ូរបស់យើងមានការលំបាកមែន តែដាច់ខាតនឹងមានជ័យជម្នះ ។

នៅក្នុងសាលាអប់រំនយោបាយនេះ អង្គការខ្មែរក្រហមបានប្រើល្បិចដោយប៉ិនប្រសប់ ចេះលើកយកឯកសារនយោបាយនានាមកណែនាំអប់រំសម្របទៅតាមកំរិតគំនិតនយោបាយរបស់សមាជិកម្នាក់ៗ (គេនិយមនិយាយថា ការភ្ញាក់រឭកនយោបាយ) បានសេចក្តីថា ចំពោះសមាជិកណាដែលនៅជាប់ជំពាក់ចិត្តនឹងស្តេច សីហនុ (ក្របខ័ណ្ឌរណសិរ្ស) នៅឡើយ ហើយនៅខ្លាចរបបសង្គមនិយម គេច្រើនលើកយកតែឯកសារត្រឹមកម្រិតរណសិរ្សមកអប់រំ ឬមួយក៏គេទុកឲ្យសមាជិកប្រភេទនេះទទួលការណែនាំហ្វឹកហ្វឺននៅតាមមន្ទីរតែប៉ុណ្ណោះ ។ បន្តិចម្តងៗគេបំផុសមាគ៌ាឆ្ពោះទៅរកទ្រឹស្តីក្រហមតាមរយៈឯកសារផ្សេងៗមានជាអាទិ៍ឯកសារស្តីពីៈ

- ◆ ការបែងចែកវណ្ណៈនៅក្នុងសង្គមកម្ពុជា ។
- ◆ ការតស៊ូវណ្ណៈ ។
- ◆ ទស្សនៈមហាជន ។
- ◆ ការកសាងជីវភាពកម្មាជីព ។
- ◆ ទិតៀននិងស្វ័យទិតៀន *(Critique et autocritique)* ។
- ◆ មោទនភាពខុសនិងត្រូវ ។
- ◆ គុណសម្បត្តិរបស់កម្មាភិបាល ។ល ។

ចំពោះក្របខ័ណ្ឌពេញលក្ខណៈ កម្មាភិបាល(ស្នូល) ដែលជា "បក្សជននៃបក្សកុម្មុយនិស្តកម្ពុជា ***(Membre du parti communiste khmer)*** កម្រិតអប់រំរៀនសូត្រក៏កាន់តែមាន

ជម្រៅទៅទៀត ទៅរកផ្នត់សង្គមនិយម (*Pli socialiste*) ទៅរករបបកុម្មុយនិស្ត ហើយការអប់រំរៀនសូត្ររបស់ពួកប្រភេទនេះ ត្រូវទុកជាការលាក់បាំងមិនឲ្យសមាជិកប្រភេទវណសិរ្សប្រភេទសាមញ្ញដឹងឮឡើយ ។ គឺកម្មាភិបាលជាបក្ខជននេះហើយដែលអង្គការខ្មែរក្រហមចាត់ឲ្យទៅធ្វើជាស្នូលនៅតាមតំបន់នានា ជាប្រធានមន្ទីរ ជាស្នងការនយោបាយនៅក្នុងកងទ័ពគេ ។

នៅភូមិភាគពិសេសរបស់អង្គការខ្មែរក្រហម អ្នកដែលមានភារៈបង្រៀននិងអប់រំពួកក្របខ័ណ្ឌនយោបាយ មានលោក សៀង ប៉ោសែ, លោក រស់ ជាទ្វា, លោក សុក ធួក, លោក ជី គីម អាន ទើបនឹងស្លាប់នៅដើមខែមេសា (១៩៧២) និងមិត្តហង់ (ឈ្មោះបដិវត្តន៍) ។

នៅភូមិភាគនិរតីទិសមានលោក ជូ ជេត, លោក ភោគ ឆាយ លោក ធុច រិន ជាអ្នកបង្រៀន ។

### ការអប់រំនិងការរៀនសូត្រនៅតាមមន្ទីរ

នៅតាមមន្ទីរនីមួយៗ ប្រធាននិងអនុប្រធានជាអ្នកដឹកនាំរៀនសូត្រពិភាក្សាពីគោលការណ៍ផ្សេងៗដែលមានចែងនៅក្នុងឯកសារ ។ ឯកសារទាំងអស់ដែលគេយកមករៀនសូត្រ សុទ្ធតែតាក់តែងចេញពីគណៈកម្មាការកណ្តាលនៃបក្សកុម្មុយនិស្ត (មជ្ឈិម) របស់គេ ។ ការរៀនសូត្រនៅតាមមន្ទីរពុំបានធ្វើដោយទៀងទាត់ទេ ជួនគេរៀបចំធ្វើមួយខែម្តង ជួនពីរខែម្តង តាមពេលទំនេរ ។

ក្រៅពីការរៀនសូត្រនៅក្នុងឯកសារ គេចាត់ទុកការប្រជុំជីវភាព (ប្រជុំធ្វើទិតៀននិងស្វ័យទិតៀន) ដែលមានធ្វើរៀងរាល់ថ្ងៃអាទិត្យ ការអប់រំនយោបាយនិងការត្រួតពិនិត្យនូវការអនុវត្តន៍ទ្រឹស្តី-មាគ៌ានយោបាយមួយយ៉ាងវិសេសវិសាល ។ នៅក្នុងការប្រជុំទិតៀននិងស្វ័យទិតៀន គេច្រើនរិះគន់គ្នាទៅវិញទៅមក ពីធាតុ"បុគ្គលនិយម" ធាតុ"សេរីនិយម" ច្រើនជាងគេ ។ គេខិតខំបំបាត់ "ធាតុ" ទាំងនេះក៏ក្នុងគោលដៅ "ផ្សាំង" មនុស្សឲ្យទៅជាឧបករណ៍មួយសម្រាប់គោរពនិងអនុវត្តវិន័យរបស់អង្គការដោយគ្មានរអ៊ូរទាំ ដូចម៉ាស៊ីនសម្រាប់របបសង្គមនិយមនេះឯង ។ គេបណ្តុះផ្នត់គំនិតគោរពចន្ទាក់វិន័យ ចន្ទាក់ការងារ ចន្ទាក់ជីវភាព ស្របតាមវិន័យរបស់កម្មករដែលគេតែងលើកយកមកធ្វើជាគំរូ ។ គឺគេអនុវត្តទ្រឹស្តីកម្មាជីវូបនីយកម្ម ដោយយកទម្ងន់អំណាចបក្សមកគ្រប់គ្រងសង្កត់សង្កិនម្តងៗ ។ នេះគឺជាវគ្គដំបូងនៃ "អំណាចផ្តាច់ការវណ្ណៈកម្មាជីព" (*Phase primaire de la dictature prolétarienne*) ។

### ◆ ការអប់រំនយោបាយតាមរយៈមីទ្ទីង

យើងបានដឹងហើយថា មីទ្ទីងជាសាលាអប់រំនយោបាយមួយយ៉ាងសំខាន់នៃពួកប្រទេសសង្គមនិយម ។ មេដឹកនាំខ្មែរក្រហមយកចិត្តទុកដាក់នឹងរៀងធ្វើមីទ្ទីងនេះណាស់ ។ នៅគ្រប់ទីកន្លែង ទោះនៅតាមភូមិតូចតាចក៏ដោយ មេដឹកនាំខ្មែរក្រហមតែងឆក់យកបុណ្យទានសាមញ្ញរបស់អ្នកស្រុកមកធ្វើជាមីទ្ទីងតូចធំ ។ ពេលជុតរដូវប្រូតកាត់ គេណែនាំអ្នកស្រុកឲ្យធ្វើបុណ្យមីទ្ទីងមួយ ដើម្បីគេឆ្លៀតអប់រំនយោបាយផង ឆ្លៀតកម្ចាចិត្តអ្នកស្រុកឲ្យខិតខំ "សម្រុក" បង្កបង្កើនផលផង ។ ក្នុងពេលធ្វើមីទ្ទីងម្តងៗ តែងមានរាត្រីសិល្បៈជានិច្ច សម្រាប់ជាមធ្យោបាយឃោសនាអប់រំ បំផុសបំផុល "ហិង្សាបដិវត្តន៍" របស់គេឲ្យឆាបឆេះនឹង "ខ្មាំង" (គឺយើងខ្មែរគ្នាឯងនេះ!) ជានិច្ច ។ ក្រៅពីសុន្ទរកថារបស់ស្នូលគេមក គេរៀបចំឲ្យតំណាងអ្នកស្រុកប្រុសស្រីនៅតាមភូមិឡើងបញ្ចេញយោបល់ ដែលភាសារបស់គេហៅថា "ឡើងចាប់អារម្មណ៍" គាំទ្របដិវត្តន៍នឹងការតស៊ូរបស់គេ ។ សូមបញ្ជាក់ថា នៅតាមភូមិនានា គេមានចាត់ស្នូលរបស់គេឲ្យទៅអប់រំនយោបាយក្នុងមួយឆ្នាំម្តងឬពីរដងជានិច្ច ។ បុណ្យខ្មោចរបស់យុទ្ធជនខ្មែរក្រហម គេក៏បង្វែរឲ្យទៅជាមីទ្ទីងផងដែរ ។

កាលនៅថ្ងៃ ៣០ ខែកញ្ញា ឆ្នាំ១៩៧២ កន្លងទៅនេះ គេមានធ្វើមីទ្ទីងមួយយ៉ាងធំនៅភូមិភាគទាំងអស់ ដើម្បីរំឭកខួបនៃបក្សកុម្មុយនិស្តកម្ពុជាដែលគេបានអះអាងថាមានកំណើតតាំងពីឆ្នាំ១៩៥១មកម៉្លេះ ។ គេមានបោះផ្សាយប្រវត្តិតស៊ូ ២១ឆ្នាំរបស់គេផង ។ មុនថ្ងៃ ៣០ កញ្ញា ឆ្នាំ១៩៧២ អង្គការខ្មែរក្រហមបានលាក់បាំង មិនឲ្យចេញឈ្មោះបក្សកុម្មុយនិស្តរបស់គេសោះទេ ។ ឆ្នាំ១៩៧២ នេះជាឆ្នាំទីមួយដែលខ្មែរក្រហមបានបើកមុខ "យីហោ" របស់គេជាសាធារណៈ ។

*នៅលើបដាក្រហមព្រោងព្រាត គេចែងពាក្យស្លោកផ្សេងៗ បញ្ជាក់នូវតួនាទីដឹកនាំរបស់ "បក្ស" មានជាអាទិ៍ៈ*

*"មានតែបក្សកុម្មុយនិស្តកម្ពុជាទេដែលអាចដឹកនាំបដិវត្តន៍ទៅរកជ័យជំនះជាស្ថាពរបាន"*

*"បក្សកុម្មុយនិស្តកម្ពុជាប្រកាន់នាទីដឹកនាំបដិវត្តន៍កម្ពុជា"*

*ថ្ងៃ ៣០ កញ្ញា ១៩៧២ នៅវេលាម៉ោង ៧ ល្ងាច នៅខាងជើងភូមិតាំងខ្មៅ ក្រោមដំណក់ភ្លៀងស្រិចៗ ខក្បោសនស័ព្ទបានបំពងបញ្ជាខ្លាំងៗ ឲ្យមិត្តទាំងអស់ទម្លាក់ដៃអាវ បិទឡេវកដោះមួកប្រុងប្រៀបគោរព "ទង់បក្ស" ទស្សនិកជនគោរពតាមបញ្ជាដោយស្ងៀមស្ងាត់...។ បទភ្លេង "គោរពទង់បក្ស" ក៏បានបន្លឺឡើង វាំងននពណ៌ខៀវរបើកខាកឡើង លេចផ្ទាំងកំណាត់ពណ៌ក្រហមទំហំប្រមាណ ៤ម.២ [៤ម៉ែត្រ២តឹក] មានសញ្ញាកណ្តៀវនិងញញួរប្រទាក់គ្នានៅចំកណ្តាលផ្ទាំងក្រហម ។ ខ្ញុំងាកឆ្វេងស្តាំ ឃើញមិត្តជិតខាងក្តាប់ដៃគំនាប់ទង់យ៉ាងស្ងៀមស្ងាត់ ។ ខ្ញុំក៏ក្តាប់ដៃគំនាប់តាមគេដែរ ហើយងាកទៅខ្សឹបដាក់មិត្តខ្ញុំម្នាក់ដែលមានទស្សនៈនយោបាយដូចគ្នាជាភាសាបារាំងថាៈ "ដូចគេចាក់ចំបេះដូងខ្ញុំត្រូវមួយកាំបិត...ខ្ញុំមានអារម្មណ៍ហាក់ដូចរស់នៅក្នុងសហភាពសូវៀត" ។ មិត្តខ្ញុំធ្វើសញ្ញាឲ្យខ្ញុំនិយាយតិចៗកុំឲ្យគេឮ ។ បន្តិចក្រោយមក ឆ្លៀតពេលដែលអ្នកឯទៀតកំពុងចាប់អារម្មណ៍នឹងសុន្ទរកថារបស់អនុប្រធានភូមិភាគពិសេស យើងទាំងពីរនាក់ក៏កេះគ្នារំកិលខ្លួនបន្តិចម្តងៗចេញពីទីនោះ ទាំងជីងគោងស្រាលខ្លួន ព្រមទាំងអស់សង្ឃឹមថែមមួយគ្រួតទៀត ។ មិនដែលមានពេលណាដែលខ្ញុំអស់សង្ឃឹមនឹងរឿងជាតិដូចពេលនេះទេ...។*

## ការអប់រំនយោបាយតាមរយៈសន្និបាត

ពេលធ្វើសន្និបាតម្តងៗ មានសន្និបាតបញ្ញវន្តជាដើម វរជនខ្មែរក្រហមឬកម្មាភិបាលរបស់គេតែងនាំគ្នាពិភាក្សាពីបញ្ហាលំបាកឬការខ្វះខាតផ្សេងៗដែលគេបានជួបប្រទះក្នុងការអនុវត្តន៍មាគ៌ារបស់បក្ស ។ សន្និបាតរបស់គេមានលក្ខណៈចំហខ្លះសម្ងាត់ខ្លះ ។ នៅក្នុងសន្និបាតចំហ គេលើកបញ្ហានានាក្នុងក្របខ័ណ្ឌរណសិរ្សមកពិភាក្សា ។ គេលាក់បំបាំងមិននិយាយពី "បក្សកុម្មុយនិស្ត" ពីកម្មវិធីនយោបាយរបស់បក្ស ។

នៅក្នុងវង្វង់ "បក្ខជន" កុម្មុយនិស្ត ការពិភាក្សាផ្សេងៗ នៅក្នុងសន្និបាតមានលក្ខណៈជាសម្ងាត់ ព្រោះគេពិភាក្សាពីកម្មវិធីនយោបាយរបស់បក្សពិតប្រាកដ ពីយុទ្ធវិធីនិងវិធីសាស្ត្ររបស់បក្ស ។ ក្រៅពីបក្ខជនឬស្នូលសំខាន់ៗ គ្មានសមាជិកដទៃណាមានសិទ្ធិចូលរួមក្នុងមហាសន្និបាតនេះទេ ។

## ៥) របៀបចាត់ចែងរដ្ឋបាលភូមិ ឃុំ ស្រុក តំបន់ ភាគ

សព្វថ្ងៃនេះ ពួកខ្មែរក្រហមបានចែក ភូមិ ឃុំ ស្រុក ខេត្ត ភាគជា ភូមិ ឃុំ ស្រុក តំបន់ ភាគ ដូចគ្នា ។ ការបង្កើតតំបន់ភាគដែលស្របទៅនឹងខេត្តភាគរបស់យើងនៅពុំទាន់ច្បាស់លាស់នៅឡើយទេ តាមពិត តំបន់នីមួយៗរបស់ខ្មែរក្រហមមានទំហំប៉ុននឹងរបស់យើង ហើយភាគនីមួយៗស្របគ្នានឹងភូមិភាគរដ្ឋរបស់យើង *Régions administratives* ។

ភូមិ ឃុំ តំបន់ ភាគ នីមួយៗ ដឹកនាំដោយគណៈកម្មការភូមិ ឃុំ ស្រុក តំបន់ ភាគ ។ គេច្រើននិយាយដោយខ្លីថា គណៈភូមិ ឃុំ តំបន់ ។ គណៈកម្មការនីមួយៗមានសមាសភាពដូចតទៅៈ

◆ ប្រធាន

◆ អនុប្រធាន

◆ សមាជិក (ច្រើនឬតិច) ទទួលបន្ទុកខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ យោធា ។ល ។

ចំពោះឃុំ ស្រុក និង តំបន់ គេមានតែងតាំងស្នងការនយោបាយរបស់បក្សម្នាក់ដែលពួកគេនិយមហៅថា "លេខាបក្ស" (លេខាធិការរបស់បក្ស) ។ "លេខាបក្ស" នេះមានអំណាចធំជាងគេ ព្រោះជាតំណាងរបស់បក្សសម្រាប់តាមដានមើលសកម្មភាពរបស់គណៈកម្មការទាំងមូល ។ នៅតាមឃុំដែលប្រជាជននៅពុំទាន់យល់ពីរឿងបដិវត្តន៍របស់គេ គេតែងតាំងឲ្យមានស្នងការនយោបាយរបស់បក្សម្នាក់នៅអមគណៈកម្មាធិការ ។ ស្នងការនយោបាយ ឬ "លេខា" សុទ្ធតែជាបក្ខជន ជាសមាជិកពេញច្បាប់នៅក្នុងបក្ស ។ ចំណែកសមាជិកឯទៀតនៃគណៈកម្មការ (លើកលែងគណៈតំបន់និងភាគ) មានខ្លះមិនទាន់បានចូលជាសមាជិកនៃបក្សទេ គឺគ្រាន់តែជា "ជនបង្គោល" ឬជាអ្នកធ្លាប់គាំទ្របដិវត្តន៍របស់គេជាយូរមកហើយ និងធ្លាប់

ទទួលការអប់រំនយោបាយជ្រៅជ្រះពីពួកគេ ។ នៅមានប្រធាន ឬសមាជិកគណៈកម្មការរណសិរ្សភូមិឃុំខ្លះ នៅត្រឹមក្របខ័ណ្ឌរណសិរ្សនៅឡើយ គឺនៅយល់ថា គេធ្វើបដិវត្តន៍នេះដើម្បីប្រគល់អំណាចទៅឲ្យស្តេច សីហនុ វិញតែប៉ុណ្ណោះ ។ ចំពោះសមាជិកគណៈកម្មការប្រភេទនេះ អង្គការខ្មែរក្រហមឃ្លាំតាមដានមើលជានិច្ច ហើយគេខស្សាហ៍អប់រំនយោបាយបន្តិចម្តងៗ ដើម្បីទាក់ទាញឲ្យលោតផ្លោះមកដល់លំដាប់បដិវត្តន៍សង្គមនិយម ។

នៅចុងឆ្នាំ១៩៧០ រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧១ សមាជិកនៃគណៈកម្មការរណសិរ្សនៅតាមភូមិ ឃុំ ស្រុក នៅប្របូកប្របល់ខ្លាំងណាស់ ។ ពួកសីហនុនិយមបានទទួលតំណែងសំខាន់ៗជាច្រើននៅក្នុងអង្គការក្រោម គឺនៅក្នុងគណៈភូមិ ឃុំ ស្រុក និងតំបន់ខ្លះៗ ។ សមាជិកអស់នោះជ្រើសរើសឡើងទាំងបន្ទំដោយពួកយៀកកុង-យៀកណាមខាងជើង ម្ល៉ោះហើយច្រើនតែខ្វះការអប់រំខាងផ្នែកនយោបាយជ្រៅជ្រះ ។ ចំណែកនៅក្នុងអង្គការខាងលើ មានគណៈតំបន់ខ្លះ គណៈភាគខ្មែរក្រហម គេប្រកាន់នាទីដាច់មុខពីសមាជិក នៅក្នុងគណៈកម្មការដឹកនាំទាំងអស់សុទ្ធតែជាសមាជិកពេញច្បាប់របស់បក្ស ។ ដើម្បីឲ្យបានចូលជាសមាជិកពេញច្បាប់របស់បក្ស ម្នាក់ៗត្រូវចូលបម្រើចលនារបស់គេយ៉ាងតិចឲ្យបានពីរឬបីឆ្នាំ ហើយត្រូវបំពេញលក្ខខណ្ឌរបស់គេឲ្យបានគ្រប់សព្វផង ។

ពួកខ្មែរក្រហមបានប្រើយុទ្ធវិធីនយោបាយមួយក្នុងការលេបកម្លាំងរណសិរ្សរបស់ សីហនុ ។ ដំបូងគឺនៅឆ្នាំ១៩៧០ និងឆ្នាំ១៩៧១ នៅពេលដែលកម្លាំងកុម្មុយនិស្តយៀកកុង-យៀកណាមខាងជើងកំពុងវាតត្បាតលុកលុយវាតទីខ្លាំង ទ័ពកុម្មុយនិស្តបរទេសក៏បានយកទុនប្រជាប្រិយស្តេចសីហនុមកធ្វើជាឡប់ខ្លែដើម្បីរកកម្លាំងបង្អែកកម្លាំងគាំទ្រនៅក្នុងស្រទាប់ប្រជាជនដែលពួកវាត្រួតត្រា ។ ពេលនោះកម្លាំងខ្មែរក្រហម ទាំងកម្លាំងយោធានិងកម្លាំងនយោបាយ នៅទន់ខ្សោយខ្លាំងណាស់ ។ ទាំងយៀកកុង-យៀកណាមខាងជើង ទាំងពួកកុម្មុយនិស្តខ្មែរនាំគ្នាប្តូរយុទ្ធវិធីនយោបាយកៀងគរកម្លាំងសីហនុនិយម ព្រោះនៅតាមតំបន់ជនបទភាគច្រើន ទុនប្រជាប្រិយរបស់ សីហនុ នៅខ្លាំងនៅឡើយ ។ ប្រជាកសិករ ពាណិជ្ជករមួយចំនួនធំនៅគាំទ្រស្តេច សីហនុ ជាហេតុនាំឲ្យអ្នកដឹកនាំខ្មែរក្រហមទៅពួនក្រោមឡប់ខ្លែ "រណសិរ្សរួបរួមជាតិកម្ពុជា" ។ គណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្តខ្មែរបានប្រទាញ សីហនុ ឲ្យចូលអន្ទាក់របស់ខ្លួនតាមរយៈប៉េកាំង ។ បានដៃហើយ ពួកខ្មែរក្រហមក៏ប្រឹងចំហៀវខ្វាញ់ សីហនុ ឲ្យអស់ពីខ្លួន ។

សព្វថ្ងៃនេះ កម្លាំងរណសិរ្សរបស់ សីហនុ បានក្លាយទៅជាកម្លាំងនយោបាយរបស់បក្សកុម្មុយនិស្តខ្មែរទៅវិញហើយ ។ ពួកក្របខ័ណ្ឌខ្មែរក្រហម ទាំងក្របខ័ណ្ឌនយោបាយ ទាំងក្របខ័ណ្ឌយោធា បានចូលកាន់កាប់គ្រប់អង្គការតូចធំរបស់រណសិរ្សជំនួសពួកសីហនុនិយមអស់ហើយ ។ ពួកសីហនុនិយមទាំងអម្បាលម៉ានបានប្រែក្លាយទៅជាខ្មែរក្រហម ។ សព្វថ្ងៃនេះ ចាប់តាំងពីពួកខ្មែរក្រហមចាប់បើកមុខបង្ហាញដល់សាធារណជនមក ពួកក្របខ័ណ្ឌខ្មែរក្រហមចាប់ធ្វើការអប់រំទ្រឹស្តីសង្គមនិយមយ៉ាងសកម្ម ។

អំណឹះតទៅ នៅក្នុងបញ្ហាខ្មែរ ខ្មោចរាជានិយមក្តី ខ្មោចសីហនុនិយមក្តី អស់មានឥទ្ធិពលមកលងយើងតទៀតហើយ ។ កង់ប្រវត្តិសាស្ត្របានវិលទៅមុខគ្មានត្រឡប់ ។ មានតែកម្លាំងនយោបាយពីរទេដែលត្រូវប្រឈមមុខដាក់គ្នាទៅវិញទៅមក គឺរបបសាធារណរដ្ឋខ្មែរសេរី និង កម្លាំងកុម្មុយនិស្ត ។

នៅក្នុងចម្បាំងទប់ទល់នឹងកុម្មុយនិស្តឥណ្ឌូចិនសព្វថ្ងៃនេះ ប្រជាជាតិខ្មែរត្រូវការសើរើរៀបចំដំហរជាតិមួយថ្មីជាចាំបាច់ ដែលជាដំណាក់កាលទីពីរនៃបដិវត្តន៍១៨មីនា ដើម្បីយើងមានលទ្ធភាពខ្លួនឯងទប់ទល់នឹងកម្លាំងស្រូបនៃបដិវត្តន៍កុម្មុយនិស្តនៅភូមិភាគឥណ្ឌូចិននេះ ។ ដើម្បីជៀសវាងកុំឲ្យវាសនាខ្មែរក្លាយទៅជាវាសនានៃរដ្ឋប៉ូឡូញ គួរតែពួកឆ្វេងនិយមខ្មែរបោះបង់ចោលនូវគំនិតផ្សងព្រេងនិយមរបស់ខ្លួន បោះបង់ចោលនូវគំនិតរើរវាយក្នុងផ្លូវនយោបាយ ហើយមកជួយរៀបចំសង្គមជាតិឆ្ពោះទៅរកវឌ្ឍនធម៌និងសុភមង្គល តាមរបៀបខ្មែរក្នុងរង្វង់គ្រួសារខ្មែរគ្នាឯង ព្រោះមានតែរបបខ្មែរទេដែលតំណាងឆន្ទៈប្រជាជនខ្មែរពិតប្រាកដ ហើយរបបខ្មែរនោះឯង ក៏ជាសំយោគនៃរបបមូលធននិយមនិងរបបសង្គមនិយមស្រេចបាច់មកហើយផង ។ **ចប់**

**អ៊ុត សារិន**

# កិច្ចសន្ទនារវាង គេង វ៉ាង ពីង និង អៀង សារី (សមមិត្តវ៉ាន់) ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៩

*គេង វ៉ាវ ពីង:* ចំណុចស្នូលសំខាន់ជាងគេគឺប្រជាជាតិ និងស្នេហាជាតិ។ សាមគ្គីជាមួយមនុស្សកាន់តែច្រើនលើមូលដ្ឋានស្នេហាជាតិ។ ឥឡូវនេះមានចំណុចមួយច្បាស់ គឺមានមនុស្សមួយចំនួននៅខាងអាយ៉ង។ ចំពោះអ្នកទាំងនេះត្រូវមានន/ប [នយោបាយ] រស់រវើកណាស់។ កុំដេរគេងាយៗ ត្រូវទំអូសទាញគេ។

ដើម្បីអូសទាញមនុស្សមួយផ្នែកនេះ សុំគិតគូរម៉ត់ចត់អំពីការរួបរួមជារណសិរ្សឯកភាពជាមួយសម្តេច សីហនុ ធ្វើយ៉ាងនេះនឹងជះឥទ្ធិពលដល់មនុស្សមួយចំនួន (ចំនួននេះគឺច្រើនដែរ) នឹងរួបរួមជាមួយមនុស្សមួយចំនួននៅក្រៅប្រទេសដើម្បីឯកោ អង្គការអាយ៉ង។



ប៉ុន្តែក៏កុំធ្វេសប្រហែសចំពោះបុគ្គលរបស់ សីហនុ។ សីហនុ ទៅលើកនេះដើរត្តួ។ ការសំរេចចិត្តឱយគាត់ចេញទៅនេះត្រូវណាស់។ នៅប៉ារីសមានអង្គការមួយហៅខ្លួនថាជារដ្ឋាភិ-បាល...។ អង្គការនេះមានចេញប្រកាស ៥ខ÷ ក្នុងនេះមាន៤ខល្អ ប៉ុន្តែមានតែមួយខទេដែលមិនល្អ គឺប្រឆាំងនឹងរដ្ឋាភិបាល ប៉ុលពត ដែលវាថាជារដ្ឋា-ភិបាលផ្តាច់ការ។ ១.ខ និយាយពីសីហនុ ២.ខ និយាយបញ្ជាបណ្តេញយួនចេញពីកម្ពុជា។ កម្លាំងនេះនៅអាមេរិកក៏បាននៅប្រទេសដទៃទៀតក៏បាន ដូចនៅថៃ។

បើយើងធ្វើការបានល្អ មូលដ្ឋាន អ/ក [អង្គការ] អាយ៉ងនឹងកាន់តែខ្សោយ ហើយរណសិរ្សរបស់បណ្តាស/ម[សមមិត្ត] កាន់តែពង្រីក។ ហើយលើឆាកអន្តរជាតិចំណោញណាស់ ព្រោះ

អ្នកនេះធ្វើសកម្មភាពមានប្រសិទ្ធភាពជាងបណ្តា...មកក្រៅធ្វើសកម្មភាព ។

ក្នុងសេចក្តីថ្លែងការណ៍អម្បាញ់មិញ ខ្ញុំបានបន្ថែមពាក្យ ប្រជាជាតិ ប្រជាធិបតេយ្យ និងស្នេហាជាតិ ។ ត្រូវបញ្ចាំងវាក្នុងការដាក់ស្តែង ។

សមមិត្តវ៉ាន់ៈ ឥឡូវយើងខ្ញុំផ្អាកពាក្យស្លោកប/វ [បដិវត្តន៍] សង្គមនិយម កសាងសង្គមនិយម ហើយប្រមូលលើពាក្យស្លោកប្រជាធិបតេយ្យនិងស្នេហាជាតិសាមគ្គីប្រជាជនកាន់តែច្រើន ។

គេង ស៊ាវ ភីងៈ ឥឡូវនេះ អាកប្បកិរិយា សីហនុ ល្អ ។ នៅប៉េកាំង គាត់បានបញ្ចេញពាក្យសម្តីមិនពេញចិត្តខ្លះ ដែលមានមូលហេតុសមហេតុសមផលខ្លះដែរ ។ គាត់ទំទប់ទល់ខ្លួនឯង ។ ហើយគាត់សំដែងការមិនពេញចិត្តខ្លះនេះគឺនាំឲ្យគេជឿគាត់ទៅវិញ ។ រហូតដល់ឥឡូវគាត់ទទួលស្គាល់ថា គាត់បានទទួលការផ្តាំផ្ញើពីរដ្ឋមន្ត្រីទី១ ប៉ុល ពត និងឧបនាយករដ្ឋមន្ត្រី អៀង សារី ទៅធ្វើសកម្មភាពនៅក្រៅប្រទេស ។ សុន្ទរកថាគាត់នៅអង្គការសហប្រជាជាតិល្អណាស់ រឹងប៉ឹង ម៉ឺងម៉ាត់ ។ ពេលដែលអ្នកកាសែតសួរគាត់ថា បក្សកុម្មុយនិស្តកម្ពុជាមានសម្លាប់មនុស្សទេ? គាត់ថា គាត់មិនដែលឃើញទេ ហើយជីវភាពប្រជាជនរីករាយ ។ ដូច្នេះឥឡូវត្រូវគិតគូរសភាពការណ៍ទូទៅ បើធ្វើតែម្នាក់ឯង ឯការទៅរួបរួមសាមគ្គីជាមួយ...ដូច្នេះនៅពេលវេលាសមរម្យគឺនៅពេលឆាប់ៗនេះ តាមរយៈការពិភាក្សាសុំគិតគូរឲ្យ សីហនុ ធ្វើជាប្រមុខរដ្ឋ ស/ម ប៉ុល ពត ជារដ្ឋមន្ត្រីទី១ កាន់កាប់ខាងកិច្ចការពារប្រទេស នឹងជាមេបញ្ជាការទូទៅ ។

សីហនុ កាន់ថានៈជាប្រមុខរដ្ឋ ធ្វើសកម្មភាពលើឆាកអន្តរជាតិ ស្នាក់នៅប៉េកាំង ហើយក្នុងរដ្ឋាភិបាលនេះ អាចយកពួកនៅក្រៅប្រទេសធ្វើសកម្មភាពនៅក្រៅប្រទេស ពីព្រោះពួកនេះនៅក្នុងប្រទេសឱយធ្វើសង្គ្រាមឈ្លបទៅមិនរួចទេ ។ ដល់ស/មត្រឡប់ទៅក្នុងប្រទេសវិញ សុំឲ្យមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាគិតគូរបញ្ហានេះឲ្យបានម៉ត់ចត់ ។

បើស/មឃើញថាមិនល្អក៏យើងខ្ញុំនឹងធ្វើការខ្លះដែរ ។ ស/ម មិនប្រាប់គាត់ ។ មិនទៀងថាគាត់ទទួលទេ ។ បើបោះជំហាននេះ ក្នុងមតិអន្តរជាតិនឹងបង្កើតការប្រែប្រួល ។ ការតស៊ូលើឆាកអន្តរជាតិមានមុខមាត់ថ្មីស្រឡាង ។ បើធ្វើដូច្នេះនឹងបង្កបង្កើតលក្ខណៈសម្បត្តិមានផលប្រយោជន៍ណាស់ចំពោះការតស៊ូក្នុងប្រទេស ។

នេះជាសេចក្តីសំរេចយុទ្ធសាស្ត្រធំណាស់ ។ ឥឡូវនេះ កម្លាំងសាមគ្គីកាន់តែធំកាន់តែល្អ ចំណេញសភាពការណ៍ពិសេសក្នុងស/កលំបាកសព្វថ្ងៃនេះ ។

ឯសេចក្តីស្នើរបស់សមមិត្តទាំងប៉ុន្មានអត់បញ្ហាអីទេ÷

១) ស្ថានីយ៍វិទ្យុផ្សាយសំឡេងៈ

យើងរៀបចំរួចហើយ ។ មានតែចំណុចមួយចង់ជំរាប ស/ម ។ មុនមកនេះ មតិអន្តរជាតិមិនចូលចិត្តស្តាប់ការផ្សាយរបស់ស/មទេ ។ វិទ្យុផ្សាយសំឡេងបក្សថៃនិងបក្សម៉ាឡេស៊ីក៏គេមិនចូលចិត្តស្តាប់ដែរ ។ គេចំអកឲ្យវិញ ព្រោះឃ្លាតចាកពីការពិតជាក់ស្តែង ។ ឥឡូវនេះ សុំកុំឲ្យលេចធ្លោបក្សកុម្មុយនិស្តកម្ពុជា ត្រូវឲ្យលេចស្នេហាជាតិនិយម ប្រជាជាតិនិយម ត្រង់នេះសំខាន់ជាងគេ ។ ក្រៅពីនេះ បញ្ហាវិទ្យុដោះស្រាយហើយ ។

២) បញ្ហាលុយកាក់

យើងខ្ញុំនឹងផ្តល់យ៉ាងដូចម្តេច? ផ្ញើនៅបាងកក? នៅត្រីយ៉ង់សាក់ ឬដាក់ក្នុងធនាគារថៃ? យកពេលណាក៏បាន ។ ផ្ញើទុក៥លានដុល្លារក៏បាន ហើយយកពេលណាក៏បាន ។ ផ្ញើក្នុងធនាគារថៃក៏បាន ស្ថានទូតចិនក៏បាន ស្ថានទូតកម្ពុជានៅថៃក៏បាន ។

បងវ៉ាន់ៈ យកស្ថានទូតចិនប្រចាំក្រុងបាងកក ។

គេង ស៊ាវ ភីងៈ អាចប្រើពីឥឡូវទៅ ។ ប្រើអស់ចាំគិតទៀត ។

៣) ខាងការទាក់ទងរវាងស/មនិងយើងខ្ញុំតាមវិទ្យុ យើងខ្ញុំក៏ត្រូវការណាស់ដែរ ។

គីង ពាវៈ យើងខ្ញុំចង់តាំងវិទ្យុនៅជិតព្រំដែននៅខាង... ។

មានវិទ្យុមួយទៀតចល័ត ពីព្រោះមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាចល័ត ។ ដូច្នេះ តាំងវិទ្យុចល័តតាមមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាមួយទៀតតាំងនៅព្រំប្រទល់ បើនៅលើទឹកដីថៃកាន់តែស្រួលថែមទៀត ។

គីង ពាវៈ បើត្រីយ៉ង់សាក់មិនព្រម សុំទាក់ទងជាមួយស្ថានទូតចិន ។

# កិច្ចសន្ទនារវាង ហ្វា គួ ហ្វេង និង អៀង សារី (សមមិត្តវ៉ាន់) ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៩

*ប្រធានហ្វាៈ* ប៉ុន្តែសព្វថ្ងៃសភាពការណ៍មានការប្រែប្រួលខ្លះ ។ យើងខ្ញុំខិតខំធ្វើយ៉ាងណាអូសទាញសម្តេច សីហនុ ។

*បងវ៉ាន់ៈ* មុនគាត់ចេញមក យើងខ្ញុំបានជំរាបតាមរយៈស/មទូត ស៊ុន ហោ មកប្រធានហ្វា ថា សីហនុ ស្នេហាជាតិ ប៉ុន្តែជំហរគាត់មិនដឹង ចាំទាល់តែស/មចិនជួយការងារសតិអារម្មណ៍គាត់ជាប់ ។ យើងខ្ញុំបានពិភាក្សាគ្នាថា បើយក សីហនុ ទៅព្រៃគាត់ទៅមិនរួចទេ ស្លាប់អត់បានការ ។ បើនៅភ្នំពេញ យួននឹងសូវៀតយកទៅប្រើ ។ ដូច្នេះមានតែយកមកក្រៅ ។ យើងខ្ញុំឃើញថា យើងខ្ញុំការពារភ្នំពេញមិនបានទេ ត្រូវរៀបចំដើម្បីតស៊ូឈ្លប ប៉ុន្តែពេលវេលាខ្លីពេក ។ ថ្ងៃអាយួនយកបានផ្លូវលេខ៧ហើយ ។ តាមខ្ទេសនាម ស/ម ហ្វាង ហ្វា ស/មចិនបានប្រឹងប្រែងណាស់ ។ គាត់វិវត្តយ៉ាងណា យើងក៏បានប្រឹងប្រែងអស់ប៉ុណ្ណឹងដែរ ។

*ប្រធានហ្វាៈ* ក្នុងឋានៈជាស/ម ខ្ញុំសុំមានមតិ ។

បញ្ហានៅត្រង់ពេលទទួលជ័យជំនះហើយ សីហនុ ត្រឡប់ទៅវិញ ស/មអត់បានប្រព្រឹត្តសមរម្យចំពោះគាត់ នាំឲ្យគាត់ខឹង ។ គាត់យល់ឃើញថា គាត់បានតស៊ូប្រយុទ្ធជាមួយស/មប្រឆាំង អា/ប [អាមេរិកនិងបរិវារ] រួមផ្សំការតស៊ូរបស់គាត់លើឆាកអន្តរជាតិជាមួយការតស៊ូរបស់បណ្តាស/ម នៅក្នុងព្រៃ ហើយក្រោយជ/ជ[ជ័យជំនះ] ស/ម មិនបានចាត់ចែងសមរម្យ ។ គាត់និយាយក្នុងសន្និសីទកាសែតថា ៣ឆ្នាំនោះគាត់ត្រូវឃុំឃាំង សុំជួបកូនស្រីគាត់ក៏មិនបាន សុំជួបសម្តេច ប៉ែន នុត ក៏មិនបាន មើលកាសែតក៏មិនបាន ទាក់ទងគេនៅក្រៅក៏មិនបាន ។ ពេលដែលគាត់និយាយ គាត់ទប់មនោសញ្ចេតនាគាត់មិនបានទេ ។ ម្យ៉ាងទៀត អ្នកកាសែតចេះតែឆ្កឹះគាត់ ។ នៅអង្គការសហប្រជាជាតិ រយៈមុននេះការសំដែងរបស់គាត់ល្អ ។ សុន្ទរកថារបស់គាត់នៅក្រុមប្រឹក្សាសន្តិសុខល្អ ។

ហេតុអ្វីបានជា សីហនុ ប្រមូលកម្លាំងភៀសខ្លួន? មើលទៅគឺមកពី៣ឆ្នាំក្រោយជ័យជំនះ គាត់មិនពេញចិត្ត ។ គាត់មានមតិ ។

គួរឲ្យយើងដកពិសោធន៍ដឹងមេរៀន ។ លំនាំសព្វថ្ងៃរបស់យើងគឺខិតខំអូសទាញគាត់ ។ ថ្ងៃក្រោយ បើ សីហនុ បញ្ចេញពាក្យសម្តីគ្មានប្រយោជន៍មិនចំណេញដល់អ្នកដឹកនាំកម្ពុជា ក៏សុំស/មត្រៀមស្មារតីទុកជាមុន យកសភាពការណ៍ទៅជាសំខាន់ ព្រោះខាងសត្រូវស្ថិតនៅចំពោះមុខយើង ។ ឆ្អេចចកនៅមុខកុំរវល់នឹងកញ្ជ្រោង ។ បើគាត់បញ្ចេញសំដីយ៉ាងណាក៏កុំខឹងនឹងគាត់ ។ ធ្វើយ៉ាងណាអូសទាញគាត់ឱយទៅជាអ្នកស្នេហាជាតិ កុំប្រានគាត់ឲ្យគាត់បដិបក្ខជាមួយបក្សកុម្មុយនិស្តកម្ពុជា ។ ឥឡូវយើងខំអូសទាញគាត់ឱយតែនៅមានសង្ឃឹម ទោះតិចតួចយ៉ាងណាក៏យើងខិតខំ ។ ធ្វើដូច្នេះចំណេញណាស់ដល់ការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា ។ ខ្ញុំលើកមកនេះសុំទុកជាជំនួយពិចារណារបស់ស/មក/ជ [សមមិត្តកម្ពុជា] ។ បើអូសទាញគាត់បានមកវិញ គឺធ្វើតាមការស្នើរបស់ស/ម ត.ស.ភីង (តេង ស៊ាវ ភីង) ឱយឋានៈ គាត់សមរម្យសាមគ្គីគ្នាតស៊ូប្រឆាំងវ/ណ [វៀតណាម] ។

ចំពោះ សីហនុ សមមិត្ត ហ្វាង ហ្វា បានជំរាបម្តងហើយ ។ គួរយើងខំអូសទាញគាត់ ។ គាត់ប្រែប្រួលយ៉ាងណា គួរយើងគិតគូរ...អាក្រក់បំផុត អូសទាញគាត់មិនបាន ។ បើគាត់មានបញ្ចេញមតិអីមិនល្អចំពោះអ្នកដឹកនាំកម្ពុជា ក៏កុំគិតគូរអី កុំព្រមឲ្យទៅជាបដិបក្ខទាំងស្រុង ។ ក្នុងស/ក [សភាពការណ៍] តស៊ូបន្ត សីហនុ ក៏នឹងមានការប្រែប្រួលដែរ ។

ថៃក៏គួរអូសទាញគេដែរ ។ ថៃក៏មានការមិនពេញចិត្តជាមួយបណ្តាស/ម ។ គេចង់ឲ្យស.មបញ្ជូនទូតឱយបានឆាប់ៗ ប៉ុន្តែមិត្តមិនបានធ្វើតាម ។ ទាក់ទងនឹងបក្សកុម្មុយនិស្តថៃ ដូចដែលសមមិត្ត ត.ស.ភីង [តេង ស៊ាវភីង] បានសន្ទនាជាមួយ

សាមហើយដែរ ។ មិនមែនយើងមិនគាំទ្រការតស៊ូរបស់គេទេ ប៉ុន្តែត្រូវគិតគូរសភាពការណ៍រួម ។ ប្រសិនបើកម្ពុជាមិននឹងនរទេ បក្សថៃក៏ឈរមិននឹងនរដែរ ។ ត្រូវយកចិត្តទុកដាក់ដល់នយោបាយ និងយុទ្ធវិធី ។ និយាយរួម ថៃមិនចង់ឱយវៀតណាមក្តាប់ប្រទេសកម្ពុជាទាំងមូលទេ បើវៀតណាមកាន់កាប់ទាំងមូល គឺព្រំប្រទល់ជាប់គ្នា ។ ម្យ៉ាងវិញទៀត យើងក៏ត្រូវដឹងដែរថា ថៃខ្លាចកម្លាំងសន្ធត់របស់សហភាពសូវៀតនិងវៀតណាមដែរ ។ ហេតុនេះ ចំពោះអំពើប្រព្រឹត្តរបស់ថៃ ក៏គួរយើងអធ្យាស្រ័យគេ ។ ក្នុងដំណើរយួនវាយឈ្លានពានកម្ពុជា អាកប្បកិរិយារួមរបស់ថៃគឺល្អ ។ ប៉ុន្តែក្នុងបញ្ហាជួយកម្ពុជា ថៃមិនហ៊ានធ្វើដោយចំហដូចចិនទេ ។ ឱយតែគេនឹងធ្វើការដែលចំណេញដល់កម្ពុជា ទោះជាអញ្ចឹងក៏យើងរក្សាសម្ងាត់ដែរ ។ ដូច្នេះដឹកជញ្ជូនតាមថៃ យើងគួររក្សាការសម្ងាត់ ដើម្បីក្នុងរយៈយូរបន្តរឱយថៃធ្វើតទៅទៀតនេះ ។

# របាយការណ៍របស់សមមិត្ត សាន ផ្ញើជូន អៀង សារី (សមមិត្ត វ៉ាន់)
# អំពីសកម្មភាពការទូតនៅអង្គការសហប្រជាជាតិ

*គោរពជូនបងវ៉ាន់*

*អំពីសីហនុៈ ទឹកចិត្តរបស់ សីហនុ ធ្លាក់ចុះនៅពេលដែលភ្នំពេញត្រូវខ្មាំងយួនវាយយកបាន ។ ម៉ូនិក បាននិយាយថា តាំងពីថ្ងៃមុនចេញពីប៉េកាំងមកញូវយ៉ក សីហនុ មិនចង់មក អ.ស.ប [អង្គការសហប្រជាជាតិ] ទេ ក្នុងសតិអារម្មណ៍ សីហនុ គ្មានជំនឿថាយើងអាចឈ្នះយួនបានទេ ។ នៅថ្ងៃសុក្រ ពេលល្ងាចថ្ងៃទី១២ គាត់ជប់លៀង ឌុងមាន និង Elizabeth Becker ។ យើងខ្ញុំមិនបានចូលរួមទេ តែបានដឹងតាមរយៈ Sechen នៅក្នុងវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលនិយាយថាៈ*

*១) យើងខ្ញុំ (ខ្មែរក្រហម) ដែលចេះតែប្រកាសថាឈ្នះយួននោះ គ្រាន់តែជាការកម្សាទេ ។*

*២) មិនមែនខ្មែរស្អប់យួនទេ គឺខ្លាចយួន ។*

*៣) គាត់ស្នើចរចាសម្រុះសម្រួលជាមួយយួន ។*

*គាត់និយាយនេះ២៤ម៉ោងមុនគាត់ចេញទៅអាមេរិក សុំសិទ្ធិជ្រកកោននយោបាយ នៅម៉ោង២ៈ៣០នាទីព្រឹកថ្ងៃអាទិត្យទី១៤ ។ ជាមួយ ម៉ូនិក គាត់បានរៀបចំហិបរួចជាមុនហើយ ។ សីហនុ សង្ឃឹមលើមហាអំណាច ។ តំណាងសហរដ្ឋអាមេរិកនៅ(អង្គការសហប្រជាជាតិ) ឈ្មោះ Young បាននិយាយប្រាប់គាត់ថា សម្តេចគួរតែមានតំណែងធំ ។ គាត់ឱបជើងអាមេរិកខ្លាំងណាស់ ។ បុគ្គលិកប្រាប់ខ្ញុំថា បារាំងមិនអស់សង្ឃឹមថាថ្ងៃណាមួយ សីហនុ ត្រឡប់ទៅកាន់អំណាចវិញនៅកម្ពុជា ។ ជារួម អ្នកការទូតលោកខាងលិចទាំងអស់ ព្រមទាំងទូតអូស្ត្រាលីនិងនូវែលសេឡង់ បានមកគោរពសរសើរ សីហនុ យ៉ាងខ្លាំង ។*

*ព្រមជាមួយនេះ ពួកខាងលិច ទាំងរដ្ឋាភិបាល ទាំងកាសែត វាយយើងខ្លាំងអំពីសិទ្ធិមនុស្ស អូសទាញ សីហនុ ពីយើង ។ នៅប៉េកាំង សីហនុ ទប់ទល់បានខ្លះ តែមកដល់ញូវយ៉ក គាត់យល់ស្របជាមួយពួកវាទាំងស្រុង ។*

*ពួកអាក្បត់ លន់ ណុល ក៏គាំទ្រ សីហនុដែរ ។ សីហនុ សង្ឃឹម...ទៅលើពួកនេះមួយកំរិតធំ ។ យើងខ្ញុំយល់ថា មូលហេតុទាំងនោះហើយដែលនាំ សីហនុ សំរេចឈប់ធ្វើជាតំណាងរដ្ឋាភិបាលយើង ដោយធ្វើធ្វើសកម្មភាពជាបុគ្គលវិញ ។ ដាច់ពីយើងគឺដាច់ពីប្រជាជន ។ ដូច្នេះមួយរយៈទៅ គាត់អស់ឥទ្ធិពលដែរហើយ ។ គាត់នឹងដាច់ពីសភាពការណ៍ជាក់ស្តែង ហើយអស់ប្រសិទ្ធភាព ហើយខ្មាំងជាមហាអំណាចក៏ឈប់ប្រើគាត់ ។*

*ក្នុងបញ្ហានេះ យើងមានជាយុទ្ធវិធី តែ សីហនុ ខាតជាយុទ្ធសាស្ត្រ ។ ឥឡូវសភាពការណ៍កាន់តែច្បាស់និងចំហដែរ ។ ពីម្សិល សីហនុ ជួប Cyrus Vance ហើយបានប្រកាសថាគាត់ឈប់តំណាងរដ្ឋាភិបាលយើងហើយ ។ គាត់នឹងតស៊ូប្រឆាំងយួនជាបុគ្គលសេរី ។*

*ដូច្នេះយើងខ្ញុំយល់ថា ភារកិច្ចយើងខ្ញុំជាមួយគាត់គឺអស់ហើយ ។ យើងខ្ញុំក៏បានខំធ្វើយ៉ាងណាឱយជាប់នឹងគាត់ តែគាត់*

*មិនទទួល ។ តាមយើងខ្ញុំប៉ាន់ប្រមាណ ដល់គាត់ចេញពីពេទ្យវិញ គាត់មិនស្នើឱ្យយើងខ្ញុំនៅជាមួយគាត់ទេ តែបើគាត់ស្នើវិញ យើងខ្ញុំយល់ថាអាចយើងនៅជាមួយគាត់មួយរយៈពេលទៀត ។ ផ្ទើនេះគឺតាមមាគ៌ារណសិរ្សយើង ស្នើបក្សណែនាំអំពីបញ្ហានេះ ។*

*បើសិន សីហនុ មិនស្នើឱ្យយើងខ្ញុំនៅជាមួយគាត់ទេ យើងខ្ញុំនឹងត្រឡប់ទៅប៉េកាំងវិញនៅចុងខែនេះ ។*

*ព្រឹកនេះ ខ្ញុំបានជួបទូតប៉ែលហ្សិក ។ ក្នុងការពិភាក្សាគ្នា គេបានសួរអំពី សីហនុ ពីព្រោះគេបានមើលការសែតពីព្រឹក ។ គេថា សីហនុ ជាអ្នកជាតិនិយមស្គាល់គេច្រើន ហើយអ្នកខ្លះទៀតចូលចិត្ត... ។*

*ពាក្យនេះបង្ហាញឲ្យឃើញថា គេវាយតម្លៃ សីហនុ ដោយមានកំរិត ។ យើងខ្ញុំបន្តជួបតំណាងប្រទេសមិនចូលបក្សសម្ព័ន្ធ និងប្រទេសខាងលិចតទៅទៀត ។ យើងខ្ញុំជួបគណៈប្រតិភូប្រទេសអាស៊ានទាំងអស់ ហើយសិង្ហបុរីគ្រាន់បើ ច្បាស់លាស់ជាងគេ ។*

*ដោយការគោរពភាពបដិវត្តយ៉ាងកក់ក្តៅបំផុត*

*១៩-១-៧៩, សាន*

*ដំណឹងចុងក្រោយៈ សីហនុ នឹងចេញពីពេទ្យថ្ងៃស្អែកឬខានស្អែក ។*

# លិខិតរបស់ ចិន មូ ហ្វា ផ្ញើជូន អៀង សារី

*សមមិត្ត អៀង សារី ឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ*

*ខ្ញុំមានកិត្តិយសជម្រាបជូនក្នុងនាមនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ដល់សមមិត្តថា តាមសំនូមពរនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនយល់ព្រមផ្តល់ដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនូវជំនួយដោយឥតសំណងរូបិយប័ណ្ណ៥លានដុល្លារ ដើម្បីគាំទ្រដាច់ខាតដល់ប្រជាជនកម្ពុជា ឱ្យដណ្តើមបានជ័យជំនះទាំងស្រុងក្នុងសង្គ្រាមការពារប្រទេសជាតិប្រឆាំងវៀតណាម ហើយនិងពង្រឹងពង្រីកថែមមួយកំរិតទៀតនូវមិត្តភាពបដិវត្តនិងយុទ្ធសាមគ្គីភាពរវាងប្រជាជនទាំងពីរ ចិន-កម្ពុជា ។*

*បើសិនជាសមមិត្តយល់ព្រមខ្លឹមសារខាងលើនេះ សូមសមមិត្តឆ្លើយដោយលាយលក្ខណ៍អក្សរដើម្បីទទួលស្គាល់ ។*

*សូមសមមិត្តទទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។*

*ចិន មូ ហ្វា*

*ឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន*

***លិខិតឆ្លើយតបរបស់ អៀង សារី***

*ជូនចំពោះ សមមិត្ត ចិន មូហ្វា*

*ឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន*

*សមមិត្តជាទីគោរព*

*ក្នុងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានកិត្តិយសជំរាបជូនសមមិត្តថា ខ្ញុំព្រមទទួលនូវជំនួយឥតសំណងជារូបិយប័ណ្ណគិតជាទឹកប្រាក់ចំនួនប្រាំលានដុល្លារអាមេរិក ដែលផ្តល់ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដើម្បីជាការគាំទ្រដាច់ខាតចំពោះការប្រយុទ្ធប្រឆាំងរបស់ប្រជាជនកម្ពុជាទល់នឹងការឈ្លានពានរបស់វៀតណាម ព្រមទាំងពង្រឹងនិងពង្រីកមិត្តភាពបដិវត្តនិងយុទ្ធសាមគ្គីភាពរវាងប្រជាជនទាំងពីរ ចិននិងកម្ពុជា ។*

*ជួសមុខឱ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយចេញពីដួងចិត្ត ហើយសូមឱ្យមិត្តភាពបដិវត្តនិងយុទ្ធសាមគ្គីភាពរវាងប្រជាជនកម្ពុជានិងប្រជាជនចិនស្ថិតស្ថេរជាអមតៈ ។*

*សូមទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ*

*ប៉េកាំង ថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៧៩*

*អៀង សារី*

*ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស*

*រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ*

**ឯកសារលេខ D ២៣៧២៨**

# មិនទាន់បានទទួលយុត្តិធម៌

លោកយាយ ឡឹង យី រស់នៅតែម្នាក់ឯង នៅភូមិប្រឡាយរំដេង ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ យាយ យី កើតឆ្នាំថោះ (ត្រូវនឹងឆ្នាំ១៩១៥) គិតរហូតមកដល់បច្ចុប្បន្ន យាយមានជន្មាយុ៨៩ឆ្នាំហើយ ។ យាយមានខ្នងកោង ស្បែកស៊ិតជ្រីវជ្រួញគ្របដណ្តប់រាងកាយស្គមស្គាំង ធ្មេញបាក់ទាំងអស់ បបូរមាត់ឡើងក្រហមដោយសារជាតិកំបោរដែលយាយពិសាម្លូ ។ ប្តីនិងកូនៗទាំងអស់របស់យាយបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្តីរបស់យាយនិងកូនប្រុសម្នាក់បានស្លាប់ដោយអត់អាហារ ។ កូនស្រីច្បងនិងក្រុមគ្រួសារត្រូវខ្មែរក្រហមសម្លាប់ដោយសារធ្លាប់ធ្វើការបម្រើរបបចាស់ ។ កូនប្រុសម្នាក់ទៀតត្រូវឈ្លបខ្មែរក្រហមសម្លាប់ដោយសារតែលួចអាហារមកបំពេញក្រពះ ។ ចំណែកកូនប្រុសម្នាក់ទៀតយាយមិនចាំថាស្លាប់ដោយរបៀបណាទេ ។

យាយ យី មានទឹកមុខស្លូតបូត រួសរាយរាក់ទាក់ចំពោះមនុស្សគ្រប់គ្នា មិនថាអ្នកភូមិឬអ្នកដំណើរមកពីឆ្ងាយ ។ នៅពេលដែលខ្ញុំចូលទៅដល់ផ្ទះរបស់យាយ ដោយដើរឆ្លងស្ពានដែលសង់កាត់ពីលើអូរតូចមួយ ខ្ញុំឃើញយាយកំពុងតែបោសសំរាមនៅទីធ្លា ។ ក្រឡេកឃើញមានភ្ញៀវមករក យាយទម្លាក់អំបោសពីដៃ ហើយងើបមកស្វាគមន៍ សួរសុខទុក្ខ និងអញ្ជើញឲ្យឡើងអង្គុយលេងលើផ្ទះ ។ ផ្ទះរបស់យាយសង់អំពីឈើ ប្រក់ក្បឿង មានទីធ្លាស្រឡះជុំវិញ និងមានពាងទឹកប្រាំតម្រៀបជាជួរនៅខាងមុខ ។ យាយប្រាប់ថា “ពាងនេះ ចៅទួតជាអ្នកដងទឹកដាក់



លោកយាយ ឡឹង យី

ឲ្យ ។ បើខែវស្សាត្រូវទឹកភ្លៀងដាក់ ។ យូរខែណាស់ទម្រាំយាយប្រើអស់ទឹកទាំងប្រាំពាងនេះ» ។ ជុំវិញផ្ទះមានដើមអំពិលធំៗ ដើមដូង ដើមត្នោត ដើមត្របែក និងគុម្ពប្ញស្សី ដែលចោលម្លប់ត្រឈឹងត្រឈៃ ។ យាយដាំដើមកន្ទុំងបាយសជាច្រើននៅខាងមុខផ្ទះសម្រាប់ចងជាអំបោសលក់យកកម្រៃ ។

យាយ យី មានដើមកំណើតនៅស្រុកកំពង់ត្រាច ខេត្តកំពត ។ ឪពុករបស់យាយឈ្មោះ ឡឹង គឺជាជំទប់ឃុំមួយនៅក្នុងស្រុកកំពង់ត្រាច (កាលជំនាន់នោះអ្នកស្រុកនិយមហៅជំទប់ឃុំថា លោកមេស្រុក) ។ គាត់បានស្លាប់តាំងពីយាយទើបតែមានអាយុ៥ឆ្នាំម្ល៉េះ ។ យាយនិយាយថា «*ឪពុករបស់យាយស្លាប់ដោយរាជការដាក់ទោស ប៉ុន្តែរឿងពិតគឺគាត់ពុំបានធ្វើខុសទេ ក្មួយរបស់គាត់ជាអ្នករៀបគម្រោងការទម្លាក់កំហុសមកលើគាត់*» ។ ម្តាយរបស់យាយឈ្មោះ ណាំ ជាជនជាតិខ្មែរកាត់ចិនហៃណាំ ។ ជីដូនជីតាខាងម្តាយរបស់យាយឈ្មោះ កុងតាំ និង យាយពួច ។ ក្រោយពីឪពុករបស់យាយស្លាប់ទៅ ម្តាយរបស់យាយក៏រៀបការប្តីថ្មីជាជនជាតិចិន ឈ្មោះ តាន់ ។ យាយគឺជាកូនទី៣ក្នុងចំណោមបងប្អូន៧នាក់ (៣នាក់ជាកូនឪពុកមុន ៤នាក់កូនឪពុកក្រោយ) ។

នៅពេលដែលយាយមានអាយុ១៦ឆ្នាំ មានបុរសម្នាក់មកពីប្រទេសចិន ចូលស្តីដណ្តឹង ។ ឪពុកចុងរបស់យាយក៏ព្រមលើកយាយឲ្យទៅចិនម្នាក់នោះ ប៉ុន្តែយាយប្រកែកដាច់អហង្ការ ព្រោះយាយខ្លាចទឹក មិនហ៊ានជិះសំពៅ (បុរសនោះមានបំណងយកយាយទៅរស់នៅប្រទេសចិនក្រោយពេលរៀបការរួច) ។ បន្ទាប់ពីពេលនោះមក ក៏មានបុរសម្នាក់ទៀតធ្វើជាស្មៀនឃុំនៅខេត្តកំពតដែរ ចូលមកស្តីដណ្តឹងយាយ ។ ឪពុកម្តាយរបស់យាយក៏យល់ព្រមរៀបការយាយជាមួយស្មៀនឃុំម្នាក់នោះ ទោះជាយាយប្រកែកយ៉ាងណាក៏ដោយ ។ ប្តីរបស់យាយឈ្មោះ មាត ស៊ុន ។

យាយរៀបរាប់ថា រៀបការបាន៤ឆ្នាំទើបយាយមានកូនទី១ ។ ពេលនោះយាយនិងប្តីក៏ផ្លាស់មករស់នៅខេត្តពោធិសាត់ ។ ប្តីរបស់យាយក៏បានធ្វើជាស្មៀនរបស់មេស្រុកថៃ នៅស្រុកស្វាយដូនកែវ ។ ចំណែកខ្លួនយាយបានស៊ីឈ្នួលធ្វើស្រែរបស់សម្តេចព្រះ មុនីវង្ស បានទទួលប្រាក់ឈ្នួល២កាក់ក្នុងមួយថ្ងៃ ។ យាយបានឲ្យដឹងថា សម្តេចព្រះ មុនីវង្ស មានដីស្រែជាច្រើនរយហិកតានៅក្នុងស្រុកស្វាយដូនកែវ ត្រពាំងជង និងនាមប្រយោល ។ ព្រះអង្គបានជួលប្រជារាស្ត្រឲ្យធ្វើស្រែទាំងអស់នោះដោយឲ្យប្រាក់ឈ្នួលពលកម្មក្នុងមួយថ្ងៃ២កាក់ ។ ផលស្រូវដែលបានមកយកទៅដាក់ក្នុងឃ្លាំងព្រះរាជទ្រព្យ ហើយប្រសិនបើមានប្រជារាស្ត្រណាទៅទិញស្រូវនោះ ព្រះអង្គនឹងលក់ជូនក្នុងតម្លៃថោកបំផុត ។

ក្នុងការរៀបរាប់អំពីដំណើរជីវិត យាយពុំដែលភ្លេចរំឭកដល់ព្រះនាមព្រះមហាក្សត្រពីរអង្គ គឺ សម្តេចព្រះ មុនីវង្ស និង សម្តេចព្រះ នរោត្តម សីហនុ ។ យាយបង្ហាញទឹកចិត្តស្រលាញ់ និងគោរពព្រះមហាក្សត្រទាំងពីរអង្គយ៉ាងលើសលប់តាមរយៈពាក្យសរសើរមិនដាច់ពីមាត់ថា «*សម្តេចព្រះ មុនីវង្ស ជាក្សត្រដែលប្រកបដោយសេចក្តីមេត្តាករុណាណាស់ ។ រាល់លើកដែលទ្រង់យាងទៅទីណាៗក្តី កាលបើឃើញប្រជារាស្ត្រលក់ត្រីឬសត្វដែលនៅមានជីវិត ទ្រង់តែងតែទិញសត្វទាំងអស់នោះយកទៅដោះលែងឲ្យមានសេរីភាព*» ។ យាយប្រាប់ថា យាយតាំងព្រះឆាយាល័ក្ខណ៍សម្តេចឪតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ម្ល៉េះ ។ ក្នុងរបបខ្មែរក្រហម យាយខំលាក់ព្រះឆាយាល័ក្ខណ៍នោះដែរ ប៉ុន្តែដោយសារឈ្លបខ្មែរក្រហមតាមដានខ្លាំងពេក យាយក៏ដាច់ចិត្តបោះចោល ។ ទើបតែក្រោយពេលដែលព្រះអង្គវិលមកគ្រងរាជ្យជាថ្មី ទើបយាយដាវព្រះឆាយាល័ក្ខណ៍មួយសន្លឹកថ្មីទៀតមកតាំងនៅលើផ្ទះ ។

លោកយាយបានលែងលះជាមួយប្តី បន្ទាប់ពីមានកូនស្រី២នាក់ ។ យាយប្រាប់ថា «*ប្តីយាយប្រច័ណ្ឌខ្លាំងណាស់ យាយទ្រាំរស់នៅជាមួយគាត់បានប៉ុន្មានឆ្នាំហ្នឹង ចាត់ទុកថាយាយបិនទ្រាំណាស់ទៅហើយ*» ។ ក្រោយពីលែងលះគ្នាច្រើនឆ្នាំ យាយបានរៀបការប្តីថ្មីឈ្មោះ ពៅ ពុត ជនជាតិខ្មែរកម្ពុជាក្រោម រស់នៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ យាយក៏ផ្លាស់មករស់នៅឃុំរំលេចជាមួយប្តីក្រោយ ។

ទាំងពីរនាក់ប្តីប្រពន្ធបានកាប់គាស់ដើមឈើរានសម្អាតដីមួយកន្លែងនៅក្បែរមាត់អូរដើម្បីសង់ផ្ទះ (គឺទីដីដែលយាយរស់នៅនាពេលបច្ចុប្បន្ន) ។ យាយរស់នៅជាមួយប្តីក្រោយបាន

កូនប្រុស៣នាក់ ។ យាយប្រាប់ថា ប្តីក្រោយរបស់យាយមានអាយុតិចជាងយាយ ១០ឆ្នាំ ប៉ុន្តែគាត់ស្រលាញ់យាយខ្លាំងណាស់ ។ គាត់ជាមនុស្សខស្សរាហ៍ព្យាយាម ។ ដើម្បីក្រុមគ្រួសារគាត់ខិតខំធ្វើការមិនខ្លាចនឿយហត់ ។ ប្តីរបស់យាយបានស្លាប់ដោយអត់អាហារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យាយនិយាយទាំងអួលដើមកថា "គេ [ខ្មែរក្រហម] មិនបានសម្លាប់គាត់ដោយផ្ទាល់ទេ ប៉ុន្តែគេ [ខ្មែរក្រហម] សម្លាប់នឹងបង្អត់អាហារ ។ គេ [ខ្មែរក្រហម] ប្រើគាត់ធ្វើការមួយថ្ងៃៗគ្មានពេលសម្រាក ប៉ុន្តែឲ្យគាត់ហូបមិនឆ្អែត ។ គាត់ឃ្លានខ្លាំងពេក គាត់លួចស្បែកគោដែលទុកសម្រាប់ធ្វើខ្សែព្រ័ត្រយកមកស្ងោរហូប ជួនកាលគាត់លួចហូបកូនជ្រូកដែលងាប់ពេលកើតមក ។ ខ្ញុំថាឯងហូបអីក៏អាក្រក់ម្ល៉េះ គាត់ថា គាត់ឃ្លានណាស់ បេះតែហូបៗទៅក្រែងរស់ ។ ក្រោយមកគាត់ក៏ស្លាប់ទៅ ។"

នៅពេលដែលប្រទេសកម្ពុជាធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម យាយមានអាយុជាង៥០ឆ្នាំ ។ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់យាយទៅរស់នៅសហករណ៍ឃុំខ្នារទទឹង នៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ដែរ ។ ប្រធានសហករណ៍បានចាត់តាំងយាយឲ្យមើលកុមារ ប៉ុន្តែយាយមិនព្រមមើលកូនអ្នកដទៃទេ គឺមើលតែចៅបង្កើតរបស់ខ្លួនឯងតែម្នាក់ប៉ុណ្ណោះ ។ ដោយហេតុដូច្នេះ ប្រធានកងទិតៀនយាយថាសួនតួនិយម ហើយក៏ផ្លាស់យាយឲ្យទៅធ្វើការ នៅក្នុងកងដាំបន្លែ ។ ប្រធានកងដាក់ផែនការឲ្យយាយដាំខ្ទឹមស្លឹកជាច្រើនរង ។ យាយទទួលខុសត្រូវតែម្នាក់ឯង តាំងពីជ្រោយដី ដាំដើមខ្ទឹម ដាក់ដីស្រោចទឹក ថែទាំ ធ្វើយ៉ាងណាឲ្យខ្ទឹមដុះលូតលាស់ល្អ និងផ្គត់ផ្គង់ទាន់ពេលវេលាតាមការស្នើរបស់រោងបាយសហករណ៍ទាំងអស់នៅក្នុងឃុំ ។ ប្តីរបស់យាយធ្វើការនៅក្នុងកងផលិតរទេះ ។ កូនៗបង្កើតនិងកូនប្រសាររបស់យាយ ត្រូវខ្មែរក្រហមបំបែកឲ្យទៅធ្វើការនៅតាមកងចល័តផ្សេងៗពីគ្នា និងបង្ខំឲ្យធ្វើស្រែ ជីកប្រឡាយ គាស់គល់ លើកទំនប់ជាច្រើនម៉ោងក្នុងមួយថ្ងៃ ។ យាយនិយាយថា "គេ [ខ្មែរក្រហម] ប្រើធ្វើការធ្ងន់ធ្ងរតែឲ្យហូបតិចតួច មនុស្សឃ្លានខ្លាំង បេះតែហូបគ្រប់យ៉ាង ឲ្យតែហូបកើត ស្លឹកឈើអ៊ីៗក៏បេះតែហូបឲ្យតែតីងៗពោះ ។ អ្នកខ្លះកំពុងធ្វើការស្រាប់តែដួលស្លាប់ក៏មាន ។...សូម្បីតែដើរទៅណាក៏ត្រូវតែសុំច្បាប់សុំសំបុត្រគេដែរណ៎ បើមិនសុំទៅអត់បានទេ ។ កូនចៅអីគេបំបែកអស់ហើយ អត់ឲ្យជួបមុខគ្នាទេ ។ ពេលកូនខ្ញុំឈឺខ្ញុំទៅមើល គេដេញថាយាយឯងមិនបាច់មកមើលទេ មានពេទ្យអង្គការមើលហើយ យាយឯងមិនមែនពេទ្យទេ ។ ដើរកាត់មុខផ្ទះរបស់ខ្លួនឯងហើយមិនហ៊ានទាំងងាកមើលផង ខ្លាចគេវ៉ៃ ។ តែហ៊ានងាកមើលគេវ៉ៃណ៎ ។"

កូនប្រុសម្នាក់របស់យាយបានធ្លាយក្រពះស្លាប់ដោយសារហូបក្បាលអន្ទាម ។ យាយរំឭកថា "កូនមួយហ្នឹងវាភក ហើយខាងលាងបាយ ចែករបបឲ្យកន្ទុកមួយកំប៉ុង ។ ខ្ញុំឃើញកន្ទុកនោះមានលាយក្បាលអន្ទាមធំៗច្រើនពេកក៏រែងយកចេញ ។ ទើបតែរែងហើយដាក់ក្បាលអន្ទាមទៅម្ខាង យកកន្ទុកដាក់ម្ខាងដល់ងាកមកវិញ ស្រាប់តែបាត់ក្បាលអន្ទាមអត់ឃើញ ។ កូនខ្ញុំវាថា វាហូបអស់ហើយ ។ ក្បាលអន្ទាមនោះក៏ចាក់ពោះវៀនហើយវាក៏ស្លាប់ក្នុងថ្ងៃហ្នឹងទៅ ។...វេទនាណាស់កាលហ្នឹង ខ្ញុំមិនសមនឹងរស់ដល់សព្វថ្ងៃនេះទេ ។" និយាយដល់ត្រង់នេះ យាយប៉ប្រិចភ្នែកយ៉ាងញាប់ ហើយលើកដៃយក្រមាជូតទឹកភ្នែកដែលជ្រាបចេញពីភ្នែក ។ យាយបន្តថា "កូនមួយទៀតនោះ (ប្រុស) លួចបេះផ្លែដូង គេ [ឈ្លបខ្មែរក្រហម] ទាន់ក៏ចាប់យកទៅមន្ទីរ (សហករណ៍) ហើយក៏បាត់រហូតលែងឃើញមុខ ។ កូនប្រុសម្នាក់ទៀតមិនដឹងថាស្លាប់យ៉ាងម៉េចទេ យាយភ្លេចអស់ហើយ ។ ចំណែកកូនស្រីច្បងដែលមានប្តីជាប៉ូលិសហើយរត់ទៅភ្នំពេញក៏ត្រូវខ្មែរក្រហមសម្លាប់ចោលទាំងប្តីទាំងប្រពន្ធទាំងកូនអស់ទៅ ។ ឥឡូវខ្ញុំនៅសល់តែចៅម្នាក់ កាលហ្នឹងខ្ញុំអត់ឲ្យទៅភ្នំពេញជាមួយម៉ែវា បើឲ្យទៅជាមួយក៏ស្លាប់ដែរ ។"

បច្ចុប្បន្ន ចៅស្រីរបស់យាយមានអាយុប្រហែល៤០ឆ្នាំ ជាស្ត្រីមេម៉ាយមានកូន៧នាក់ រស់នៅក្នុងភូមិជាមួយយាយ ប្រកបរបរធ្វើស្រែនិងលក់នំចំណីកំប៉ិកកំប៉ុក ។ ក្រៅពីចៅស្រីម្នាក់នេះ យាយគ្មានសេសសល់បងប្អូនសាច់ញាតិឯណាទៀតឡើយ ។ យាយមានប្រសាសន៍ថា "យាយកាន់តែចាស់ណាស់ហើយចៅអើយ ឈឺច្រើន ភ្លេចភ្លាំងក៏ច្រើន មិនដឹងរស់បានដល់អន្កាល់ទៀតទេ ។ សព្វថ្ងៃនេះយាយរស់ដោយសារ

*អ្នកភូមិអាណិតស្រលាញ់ ចេះតែយកនេះយកនោះមកឲ្យយាយ កុំអីយាយមិនដឹងជារស់យ៉ាងម៉េចទេ ៗ»*

រហូតមកដល់ពេលនេះ យាយមិនចាំថាបានបាត់បង់សមាជិកគ្រួសារអស់ប៉ុន្មាននាក់ទេ ប៉ុន្តែប្រសិនបើរាប់គ្រួស ៗ ទាំងប្តី កូនបង្កើត៨នាក់ កូនប្រសារ៣នាក់ និងចៅៗទៀតនោះ យាយបាត់បង់សាច់ញាតិបង្កើតអស់ប្រមាណ១០នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រសិនបើរាប់ទាំងសាច់ញាតិជីដូនមួយ ជីទួតមួយ មាមីងទៀត ឃើញថាច្រើនណាស់រាប់មិនអស់ឡើយ ។ សូម្បីតែដីស្រែក៏យាយបាត់បង់អស់ដែរ ។ យាយបានឲ្យដឹងថា មុនរបបខ្មែរក្រហម យាយមានដីស្រែច្រើនហិកតាណាស់ នៅក្នុងឃុំរំលេចផង នៅក្នុងឃុំដំណាក់ត្រាចផង ។ នៅក្នុងរបបខ្មែរក្រហម ដីស្រែរបស់យាយត្រូវអង្គការដកហូតយកអស់ ។ ក្រោយរបបខ្មែរក្រហម យាយសេសសល់ដីស្រែតែបន្តិចបន្តួចប៉ុណ្ណោះ ។ យាយចង់សួរមេដឹកនាំខ្មែរក្រហមថាហេតុអ្វីបានជាសម្លាប់ប្តីនិងកូនរបស់យាយ ។ យាយចង់ឃើញមុខមនុស្សដែលមានចិត្តថ្លើមសាហាវព្រៃផ្សៃបែបនេះ ។ យាយនិយាយថា «កំហឹងរបស់យាយចំពោះខ្មែរក្រហមវាជ្រៅណាស់ រកពាក្យមកនិយាយមិនត្រូវទេ ។ ទោះជាយាយស្លាប់ទៅជាខ្មោចក៏យាយនៅតែខឹងដែរ ។ រាល់ថ្ងៃយាយទៅវត្តសុំសីល សូត្រធម៌ បន់ស្រន់សូមកុំឲ្យជួបរបបអ៊ីចឹងទៀត ៗ»

យាយយី បានគាំទ្រឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ យាយបានប្រាប់ថា ប្រសិនបើពេលដែលមានតុលាការយាយនៅរស់រានមានជីវិត ហើយប្រសិនបើតុលាការត្រូវការឲ្យយាយឆ្លើយបំភ្លឺ យាយនឹងបំភ្លឺគ្រប់ការពិតអំពីជីវិតក្រុមគ្រួសាររបស់យាយនៅក្នុងរបបខ្មែរក្រហមជូនដល់អង្គតុលាការ ។

តើអ្វីទៅដែលជាយុត្តិធម៌សម្រាប់ស្ត្រីចាស់ម្នាក់នេះ? ឆ្នាំនេះយាយ ឡឹង យី មានជន្មាយុ ៨៩ឆ្នាំហើយ តើគាត់ត្រូវរង់ចាំយុត្តិធម៌ដល់ពេលណាទៀត? ការចរចាដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានដំណើរការអស់រយៈពេលជាង៥ឆ្នាំទៅហើយ ប៉ុន្តែការងារនេះនៅតែមិនទាន់ចេញជាផ្លែផ្កានៅឡើយ ។ លុះមដល់ពេលដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា រួបរួមគ្នាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានសម្រេច ដើម្បីឲ្យជនរងគ្រោះនៃរបបខ្មែរក្រហមបានស្ងប់ចិត្ត មុនពេលដែលគាត់ឃ្លាតចាកពីលោកយើងនេះទៅ ។

**សាន់ កល្យាណ**



ផ្ទះរបស់យាយ ឡឹង យី

# ភូមិកន្ទែងរមាស សំណល់បដិវត្តន៍

ភូមិកន្ទែងរមាសស្ថិតនៅក្នុងឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានចម្ងាយប្រមាណ១២គីឡូម៉ែត្រភាគខាងលិចឆៀងខាងត្បូងទីរួមខេត្ត ។ ចាប់តាំងពីអំឡុងឆ្នាំ១៩៦៤ ខ្មែរក្រហមបានប្រើប្រាស់ភូមិកន្ទែងរមាសជាមូលដ្ឋានដើម្បីអប់រំបំពាក់បំប៉នមនោគមវិជ្ជាកុម្មុយនិស្តដល់ប្រជាជន ។ ខ្មែរក្រហមបានឃោសនាអំពីការគ្រប់គ្រងមិនរីកចម្រើន និងការនិយមបក្សពួករបស់អ្នកកាន់អំណាចនៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ព្រមទាំងបានបំផុសប្រជាជនឲ្យចូលរួមក្នុងចលនាតស៊ូរបស់ខ្លួនទៀតផង ។

នៅអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកភូមិកន្ទែងរមាសធ្វើជាមូលដ្ឋានដើម្បីប្រយុទ្ធជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរដែលមានទីតាំងនៅបន្ទាយស៊ុប ។ ប្រជាជនដែលរស់នៅក្នុងភូមិនេះ ត្រូវខ្មែរក្រហមបណ្តេញឲ្យទៅរស់នៅតាមភូមិឆ្ងាយៗ ដូចជានៅក្នុងស្រុកព្រៃឈរ ស្រុកកងមាស និងស្រុកមួយចំនួននៅក្នុងខេត្តកំពង់ធំ ។ ចំណែកផ្ទះសម្បែងរបស់ប្រជាជនត្រូវបោះបង់និងឆេះខូចខាតអស់រាប់រយខ្នងដោយសារការទម្លាក់គ្រាប់បែកនិងបាញ់ផ្លោងរបស់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ។ លាង ហេង ប្រធានភូមិកន្ទែងរមាសនាពេលបច្ចុប្បន្ន បានឲ្យដឹងថា អំឡុងសង្គ្រាមស៊ីវិល១៩៧០-៧៥ ភូមិកន្ទែងរមាស ស្គាល់តែផ្ទះតែមួយខ្នងប៉ុណ្ណោះ ក្រៅពីនោះឆេះអស់ដោយសារគ្រាប់បែក និងគ្រាប់ផ្លោង ។

នៅអំឡុងឆ្នាំ១៩៧០នេះដែរ មានសេចក្តីអំពាវនាវពីសម្តេច ព្រះ នរោត្តម សីហនុ ឲ្យកូនចៅចូលព្រៃម៉ាកគីតស៊ូវាយរំដោះប្រទេសជាតិពីចក្រពត្តិនិយម និងដោយសារតែប្រជាជនជួបប្រទះការលំបាកវេទនា ត្រូវរត់គេចពីគ្រាប់គ្រាប់បែកនិងគ្រាប់ផ្លោងផងនោះ ប្រជាជននៅភូមិកន្ទែងរមាស ពិសេសយុវជន-យុវនារីភាគច្រើន បានចូលបម្រើកងទ័ពខ្មែរក្រហម ដែលពេលនោះប្រើឈ្មោះថា កងទ័ពរំដោះ ។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ អង្គការខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនដែលធ្លាប់រស់នៅភូមិកន្ទែងរមាសវិលមករស់នៅក្នុងភូមិដដែលវិញ ។ ចំណែកកម្មាភិបាល យុទ្ធជន យុទ្ធនារី ដែលមានស្រុកកំណើតនៅភូមិកន្ទែងរមាសភាគច្រើនត្រូវបានអង្គការខ្មែរក្រហមដំឡើងបុណ្យសក្តិនិងផ្លាស់ឲ្យទៅធ្វើការនៅកន្លែងផ្សេងៗ ដូចជានៅភ្នំពេញជាដើម ។

នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមធ្វើវិសុទ្ធកម្មនយោបាយ ដោយបានចាប់ខ្លួននិងកម្ទេចកម្មាភិបាលជាន់ខ្ពស់នៅភូមិភាគឧត្តរ ដូចជា កុយ ធួន ហៅ ឃួន ឬ ធុច អតីតលេខាភូមិភាគឧត្តរ, កេត អឿន លេខាកងពល៣១០, មាន ម៉េញ ហៅ ឈិន អតីតលេខាកងពលទី២ភូមិភាគឧត្តរ និងជាលេខាកងពល៩២០, សយ សី លេខាកងពលប្រចាំភូមិភាគឧត្តរដែលប្រចាំនៅទីរួមខេត្តកំពង់ចាម, នូ ឆន ហៅ ហ៊ាន អតីតលេខាកងពល៤៥០ និងជាអនុលេខាតំបន់១០៦ ។ កម្មាភិបាលទាំងនេះសុទ្ធតែមានប្រភពមកពីភូមិកន្ទែងរមាស ។ ដូចនេះ អតីតកម្មាភិបាលយុទ្ធជនយុទ្ធនារីខ្មែរក្រហមដែលមានស្រុកកំណើតនៅភូមិកន្ទែងរមាស ដែលបានចូលបដិវត្តន៍តាមរយៈ អឿន, ឈិន, សី និង ហ៊ាន ត្រូវអង្គការខ្មែរក្រហមស្រាវជ្រាវចាប់យកទៅសម្លាប់ចោលជាបន្តបន្ទាប់ដោយចោទថាជាខ្សែក្បត់ ។


លាង ហេង

លាង ហេង បានឲ្យដឹងថា “បន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហម នៅឆ្នាំ១៩៧៩ អតីតកម្មាភិបាលយុទ្ធជនយុទ្ធនារីខ្មែរក្រហមដែលមានប្រភពនៅភូមិកន្ទែងរមាស ហើយបានរួចផុតពីការកាប់សម្លាប់ មានចំនួន

តិចតួចណាស់»។ ហេង បានប៉ាន់ស្មានថា «ក្នុងចំណោមអ្នកភូមិដែលបានចេញទៅបម្រើជាកងទ័ពខ្មែរក្រហមជាង២០០នាក់ អ្នកដែលមានដំណឹងថានៅមានជីវិត និងអ្នកដែលវិលត្រឡប់មកភូមិកំណើត មានប្រមាណ២០នាក់តែប៉ុណ្ណោះ»។


សៀម ហេង

សៀម ហេង ត្រូវជាប្អូនជីដូនមួយរបស់ មាន ម៉េញ ហៅ ឈិន បានប្រាប់ឲ្យដឹងថា «នៅអំឡុងឆ្នាំ១៩៦៤ កុយ ធួន ជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះសីហនុកំពង់ចាម បាននាំសិស្សមួយចំនួនចុះមកភូមិកន្ទែងរមាស ក្នុងរូបភាពធ្វើការងារផ្សេងៗ ដើម្បីបិទបាំងការឃោសនាគោលនយោបាយនិងបំពាក់បំប៉នមនោគមវិជ្ជាខ្មែរក្រហមឲ្យប្រជាជនចូលរួមចលនាតស៊ូរបស់ខ្លួន»។

នៅក្នុងឆ្នាំនេះដែរ ឈិន បានចូលរួមចលនាតស៊ូរបស់ខ្មែរក្រហម។ នៅពេលនោះ ឈិន មានអាយុប្រមាណ៣០ឆ្នាំ ប្រពន្ធឈ្មោះ សែម សន មានកូនប្រុសម្នាក់។ បន្ទាប់ពីចូលរួមជាមួយខ្មែរក្រហមបានមួយរយៈ ឈិន ត្រូវបានគណៈដឹកនាំតំបន់៣០៤ចាត់តាំងឲ្យទៅប្រចាំការនៅសមរភូមិបុស្សខ្នុរ ក្នុងស្រុកចំការលើ ខេត្តកំពង់ចាម មានតួនាទីជាប្រធានវរសេនាតូច ៣១៤ (នៅអំឡុងពេលតស៊ូរបស់ខ្មែរក្រហមមុនឆ្នាំ១៩៧៥ នៅតំបន់០៤ទាំងមូលមិនមានបង្កើតជាកងពលទេ គឺមានត្រឹមតែវរសេនាតូច)។

នៅសមរភូមិបុស្សខ្នុរ ឈិន បាននាំឪពុកម្តាយនិងបងប្អូនស្រី៣នាក់ ប្រុស២នាក់ ទៅរស់នៅក្នុងអង្គភាពជាមួយដែរ។ បងប្អូនប្រុសៗត្រូវបាន ឈិន បញ្ចូលក្នុងជួរកងទ័ពជាមួយគាត់ ចំណែកបងប្អូនស្រីៗ ត្រូវបាន ឈិន បញ្ចូលក្នុងកងនារីពេទ្យនៅអង្គភាពពេទ្យរបស់វរសេនាតូច៣១៤។ ឈិន ក៏បានហៅបងប្រុសម្នាក់របស់ សៀម ហេង ទៅធ្វើកងទ័ពដែរ។ កាលនោះ សៀម ហេង នៅក្មេងពេកមិនទាន់ទៅជាមួយ ឈិន ទេ រហូតដល់ឆ្នាំ១៩៧១ទើប ហេង ចូលបម្រើកងទ័ពខ្មែរក្រហម ប៉ុន្តែមិនមែនក្នុងអង្គភាពរបស់ ឈិន ទេ គឺក្នុងវរសេនាតូចលេខ ៣១៣ ដែលមានឈ្មោះ អ៊ុង ហ៊ាន ជាប្រធាន។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឈិន ត្រូវបានខ្មែរក្រហមដំឡើងឋានៈជាលេខាកងពលទី២ប្រចាំភូមិភាគឧត្តរ។ ឆ្នាំ១៩៧៦ ឈិន ត្រូវបានអង្គការផ្លាស់ទៅកាន់នាទីជាលេខាកងពល៩២០នៅមណ្ឌលគិរី។ ក្នុងពេលនោះ ឈិន បានយកបងប្អូនទៅជាមួយទាំងអស់។ ឆ្នាំ១៩៧៧ ហេង បានទទួលដំណឹងថា ឈិន ត្រូវអង្គការកោះអញ្ជើញទៅប្រជុំនៅភ្នំពេញ។ តាំងពីពេលនោះមក ឈិន និងក្រុមគ្រួសារ ក៏បាត់ដំណឹងរហូតដល់បច្ចុប្បន្ន។

សៀម ហេង មានសំណាងរួចផុតពីការសម្លាប់ជាខ្មែរសន្មាក់ ដោយសារតែ ហេង ត្រូវរបួសដាច់ចង្កានៅក្នុងសមរភូមិផ្ទាវ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៣។ ក្រោយពេលចេញពីមន្ទីរពេទ្យ ហេង បានវិលត្រឡប់មករស់នៅជាមួយម្តាយដែលត្រូវខ្មែរក្រហមជម្លៀសមកនៅភូមិគីរីអណ្តែត ស្រុកបារាយណ៍ ខេត្តកំពង់ធំ រហូតដល់ឆ្នាំ១៩៧៥។ ក្រោយពេលត្រឡប់មករស់នៅភូមិកន្ទែងរមាសវិញក្នុងឆ្នាំ១៩៧៥ ហេង ត្រូវបានឪពុកមាឈ្មោះ ម៉ែន គុជ នាំយកទៅនៅអង្គភាពជាមួយ។ ម៉ែន គុជ មានតួនាទីជាអនុប្រធានភ័ស្តុភារកងពលភូមិភាគឧត្តរ ប្រចាំនៅទីរួមខេត្តកំពង់ចាម ដែលមាន សយ សី ជាលេខា។

ដោយហេតុថា សៀម ហេង ជាមនុស្សពិការ មិនអាចធ្វើការងារធ្ងន់ៗបាន ក៏ត្រូវចាត់តាំងឲ្យកាប់ព្រៃ មើលថែទាំចម្ការចេក អំពៅ និងទៅឃ្វាលគោជាមួយកុមារ៤-៥នាក់ រហូតដល់ឆ្នាំ១៩៧៧។ ដោយសារតែនៅឆ្នាំ១៩៧៧ អង្គការចាប់ខ្លួន សយ សី, ម៉ែន គុជ និងកម្មាភិបាលភាគច្រើននៅក្នុងកងពល យកទៅសម្លាប់ចោល ធ្វើឲ្យ ហេង លែងមានទីពឹងទៀត ក៏សុំអង្គភាពវិលត្រឡប់មករស់នៅភូមិកន្ទែងរមាសជាមួយម្តាយរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។

ឈា ស្រ៊ុន ភេទប្រុសអាយុ៥៣ឆ្នាំ មានស្រុកកំណើតនៅភូមិកន្ទែងរមាស បច្ចុប្បន្នរស់នៅភូមិដដែល។ ស្រ៊ុន បានចូលបដិវត្តន៍នៅចុងឆ្នាំ១៩៧០ ដោយមាន ឈិន ជាអ្នកនាំចូល។ ពីដំបូង ស្រ៊ុន នៅជាមួយ ឈិន ឯស្រុកចំការលើ។ បន្ទាប់មក

ស្រ៊ុន ត្រូវបានផ្លាស់មកសមរភូមិប្រយុទ្ធនៅតាមផ្លូវជាតិលេខ៦ បន្ទាប់មកទៅសមរភូមិតាំងគោក ត្រពាំងថ្ម គីរីវណ្ណែត ក្នុងស្រុកបារាយណ៍ខេត្តកំពង់ធំ ។ បន្ទាប់ពីទទួលបានជ័យជម្នះលើសមរភូមិខាងលើនេះ ស្រ៊ុន ត្រូវបានបញ្ជូនទៅខាងសៀមរាបទៀតគឺបញ្ចូលទៅក្នុងវរសេនាតូច៣០៩ មានឈ្មោះ គុល, ឡុន និង ពិល ជាអ្នកគ្រប់គ្រង ។ នៅខណៈពេលវរសេនាតូច៣០៩ ប្រចាំការនៅសមរភូមិ អន្តរជ័យ កងវរសេនាតូច៣០៩ ជាកងចល័តរបស់តំបន់៣០៤ ។ រយៈពេល៦ខែក្រោយមក សមរភូមិអន្តរជ័យត្រូវកងទ័ពខ្មែរក្រហមដណ្តើមកាន់កាប់ ។ កងវរសេនាតូចលេខ៣០៩របស់ ស្រ៊ុន ក៏ផ្លាស់មកកំពង់ធំ នៅខាងសមរភូមិបាក់ខមក្នុងស្រុកតាំងគោក និងចុះមកដើងឆ្នុក តាមភ្នំល្អាកាត់មកស្តន់ស្រុកបាធាយ ខេត្តកំពង់ចាមវិញ ។ ក្នុងសមរភូមិប្រយុទ្ធនៅស្តន់ ស្រ៊ុន ត្រូវរបួសហើយត្រូវបានបញ្ជូនមកសម្រាកព្យាបាលនៅមន្ទីរពេទ្យក្រូចគរ ។ ៤ខែក្រោយមក គឺនៅឆ្នាំ១៩៧៤ ស្រ៊ុន បានចេញពីមន្ទីរពេទ្យ ប៉ុន្តែត្រូវពិការដងខ្លួននិងជើងម្ខាងមិនអាចវិលត្រឡប់ទៅសមរភូមិមុខបាន ។ ស្រ៊ុន ក៏ត្រូវបានអង្គភាព បញ្ជូនមកមន្ទីរ យ-២ ដែលជាមន្ទីររបស់ កែ ពក ស្ថិតនៅក្នុង ស្រុកចំការលើ ។


ឈា ស្រ៊ុន

នៅឆ្នាំ១៩៧៥ ស្រ៊ុន បានជួប កេត អឿន លេខាកងពល៣១០ ដែលជាអ្នកស្រុកជាមួយគ្នា ។ ស្រ៊ុន បានសុំអនុញ្ញាតពីអឿន ចូលធ្វើការនៅមន្ទីរភ័ស្តុភាររបស់កងពល៣១០ ។ ហើយបានទទួលតួនាទីជាអនុប្រធានកងអនុសេនាធំទី៣ ជាជាងជួសជុលទូក និងធ្វើផ្នែកប្រហុកសម្រាប់ផ្គត់ផ្គង់ដល់កងទ័ពនៅក្នុងកងពល ។

ដើមឆ្នាំ១៩៧៧ អឿន ត្រូវបានអង្គការចាប់ខ្លួនតាមរយៈការឆ្លើយដាក់របស់ កុយ ធួន ។ កាសែ្សតអាត់សំឡេងសារភាពរបស់ កុយ ធួន ត្រូវបានអង្គការយកមកចាក់ឲ្យកងទ័ពដែលកំពុងធ្វើស្រែស្តាប់ ។ គណៈកងពល គណៈវរសេនាធំ-វរសេនាតូច ឲ្យតែអង្គការចោទថាជាខ្សែក្បត់ គឺត្រូវចាប់ទាំងប្រពន្ធកូន ឪពុកម្តាយ បងប្អូន យកទៅទាំងអស់ ។ ចំណែក ស្រ៊ុន ក៏ត្រូវអង្គការតាមដាននិងធ្វើជីវទស្សន៍ជាញឹកញាប់ ។ ប្រមាណ៤ខែក្រោយ អង្គការក៏ផ្លាស់ ស្រ៊ុន ឲ្យមកនៅកង១៧ ។ កង១៧ជាកងលត់ដំសម្រាប់ដាក់សមាសភាពខ្មាំងនិងអ្នកមាននិន្នាការក្បត់ ។ អ្នកដែលចូលដល់កង១៧ ត្រូវធ្វើការទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាក ដូចជា ដាំបន្លែ ធ្វើស្រែ លើកទំនប់ ជីកប្រឡាយជាដើម ។ ចំពោះការហូបចុកគឺហូបមិនឆ្អែត ហើយមានយប់ខ្លះត្រូវប្រជុំរហូតដល់ម៉ោង១រំលងអធ្រាត្រក៏មាន ។ រៀងរាល់ថ្ងៃវេលាម៉ោង៤ទៀបភ្លឺ កងទ័ពត្រូវក្រោកពីដំណេក ដើម្បីប្រជុំរហូតដល់ម៉ោង៤និង៣០នាទីទើបចូលការដ្ឋានតែម្តង ។ ស្រ៊ុន មានជំងឺហើមស្ពឹក គ្មានកម្លាំងកំហែង ដើរកន្លងភ្លឺស្រែស្ទើរតែមិនផុត ទើបខ្មែរក្រហមបញ្ជូនមកពេទ្យ ។ សម្រាកពេទ្យបាន២ខែ កង១៧ត្រូវអង្គការបញ្ជូនមកធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ ស្រ៊ុន ក៏ត្រូវបង្ខំចេញពីពេទ្យ ធ្វើដំណើរមកតាមអង្គភាពទាំងមិនទាន់ជាសះស្បើយពីជំងឺ ។

ធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំងបានរយៈពេល៤ខែ កងទ័ពវៀតណាមក៏វាយលុកចូលប្រទេសកម្ពុជា ទើប ស្រ៊ុន មានជីវិតរស់ដល់សព្វថ្ងៃនេះ ។ ទោះជាមានជីវិតរស់ក៏ដោយ ក៏ ស្រ៊ុន រស់ក្នុងស្ថានភាពពិការធ្វើការងារធ្ងន់មិនកើតដដែល ។ សព្វថ្ងៃ ស្រ៊ុន រស់ដោយសារប្រពន្ធកូនរកស៊ីចិញ្ចឹម ។ ស្រ៊ុន បានប្រាប់ឲ្យដឹងថា “ក្នុងកងវរសេនាតូច៣០៩ មានសមាជិកប្រមាណ៣០០នាក់ ត្រូវស្លាប់ដោយសារការប្រយុទ្ធជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរ និងត្រូវខ្មែរក្រហមយកទៅសម្លាប់នៅអំឡុងឆ្នាំ១៩៧៧ស្ទើរតែទាំងអស់” ។ រីឯ នៅក្នុងកងពល៣១០ អ្នកដែលមានតួនាទីចាប់ពីគណៈវរសេនាតូចឡើងទៅ ត្រូវអង្គការខ្មែរក្រហមចាប់យកទៅសម្លាប់គ្មានសល់ម្នាក់ ។ ស្រ៊ុន បាននិយាយថា “ខ្មែរក្រហមចោទ កុយ ធួន និង កេត អឿន ថាជាសេ.អ៊ី.អា កា.ហ្សេ.បេ ហើយចាប់ទាំងថ្នាក់ក្រោមទៀត ។ ចំពោះកូនទាហានមិនដឹងថា សេ.អ៊ី.អា កា.ហ្សេ.បេ វាយ៉ាងម៉េចទេ បើមេបញ្ជាម៉េចទៅអ៊ីចឹងហើយ មិនដែលថាមេបញ្ជាហើយមិនធ្វើទេ ។ សម័យនោះគេគោរពតាមតែមេ” ។

នូ ឆន ហៅ ហ៊ាន ជាអនុលេខាតំបន់១០៦ទទួលបន្ទុកខាងកងទ័ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆន មានប្រពន្ធឈ្មោះ បៀន យ៉ែម ហៅ រុន និងមានកូនស្រី២នាក់ឈ្មោះ ឆន អេងឈុន និង ឆន ណារុំ ។ ឆន មានបងប្អូនបង្កើត៨នាក់ ប្រុសបីនាក់ ស្រីម្នាក់ ។ ខណៈដែល ឆន បានទទួលការចាត់តាំងជា


ឆន អេងឈុន

អនុលេខាតំបន់១០៦ ឆន បាននាំក្រុមគ្រួសារពីភូមិកន្ទែងរមាសទៅរស់នៅខេត្តឧត្តរមានជ័យជាមួយខ្លួនដែរ ។ អំឡុងឆ្នាំ១៩៧៧ នូ ឆន និងប្អូនប្រុស២នាក់ទៀត ឈ្មោះ នូ ឈន់ និង នូ ឆុន ត្រូវអង្គការសម្លាប់ចោល ។ ឆន អេងឈុន អាយុ៣៨ឆ្នាំ ដែលជាកូនស្រីរបស់ នូ ឆន បានប្រាប់ឲ្យដឹងថា «ឪពុកខ្ញុំបានចេញទៅប្រជុំ ហើយទៅបាត់រហូតតាំងពីប្អូនស្រីខ្ញុំអាយុ២ខែម្ល៉េះ ឥឡូវនេះប្អូនស្រីខ្ញុំអាយុ២៧ឆ្នាំហើយ» ។

ក្រោយពេល នូ ឆន ចេញទៅប្រជុំរយៈពេល២ថ្ងៃ យ៉ែម បានទៅសួរដំណឹង ឆន តាមរយៈអ្នកធ្វើការជាមួយ ហើយក៏បានដឹងថា ឆន ទៅប្រជុំនៅសៀមរាប ។ ដោយសារតែបាត់ដំណឹង ឆន យូរពេក យ៉ែម ក៏នាំកូនស្រីទាំងពីរនិងម្តាយក្មេកមកខេត្តសៀមរាបដែរ ។ យ៉ែម បានសាកសួរចុងភៅនៅមន្ទីរតំបន់១០៦ ចុងភៅបានប្រាប់ថា ឆន បានឡើងជិះយន្តហោះទៅហើយ ។ តាសេង ដែលធ្លាប់ធ្វើការជាមួយ ឆន តាំងពីជំនាន់តស៊ូនយោបាយ បានប្រាប់ យ៉ែម ឲ្យនាំគ្រួសារវិលត្រឡប់ទៅកំពង់ចាមវិញទៅ ព្រោះ ឆន ត្រូវអង្គការផ្លាស់ទៅកំពង់ចាមវិញហើយ ។

យ៉ែម ក៏នាំក្រុមគ្រួសារវិលមកភូមិកន្ទែងរមាសវិញ ប៉ុន្តែដំណឹងរបស់ ឆន នៅតែស្ងាត់ដដែល ។ អេងឈុន បាននិយាយថា «ក្រុមគ្រួសារខ្ញុំនៅតែរង់ចាំដំណឹងរបស់ពុករហូតមកដល់សព្វថ្ងៃ ហើយមិនបានដឹងច្បាស់ថាពុកស្លាប់ឬរស់ទេ» ។

បច្ចុប្បន្ន នៅក្នុងគ្រួសាររបស់ នូ ឆន នៅសល់តែសមាជិក៥នាក់សុទ្ធតែស្រី រស់នៅជាមួយជីដូនចាស់អាយុ៧៩ឆ្នាំ ។ នៅពេលគាត់មានជំងឺឬជួបការលំបាកម្តងៗ គាត់តែងតែរំពុកដល់កូនប្រុសរបស់គាត់ថា «បើអាឆន អាឈុន អាឆុន នៅជាមួយ ប្រហែលអញមិនពិបាកដូចសព្វថ្ងៃនេះទេ» ។ ដោយមានការព្រួយបារម្ភចំពោះការបាត់បង់ប្តីផង និងត្រូវប្រឈមមុខនឹងបញ្ហាជីវភាពប្រចាំថ្ងៃផងនោះ យ៉ែម មានជំងឺសរសៃប្រសាទបន្តិចម្តងៗ ហើយដោយមិនបានទទួលការព្យាបាលម៉ត់ចត់ ជំងឺនេះក៏មានសភាពកាន់តែធ្ងន់ធ្ងរៗទៅជាលំដាប់ ចំណែក អេងឈុន ពិការជើងស្តាំតាំងពីកំណើត មិនអាចជួយម្តាយធ្វើការងាររកស៊ីអ្វីបានឡើយ ។

**ឡុង ដានី**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ថ្នាក់លើវាយការណ៍ទៅថ្នាក់ក្រោមៈ*** គឺជាការរៀនសូត្រការផ្ញើទស្សនាវដ្តី ឯកសារ សេចក្តីសម្រេចចាត់តាំងផ្សេងៗ ។

◆ ***បដិសង្គមនិយមៈ*** គឺវាយកម្មសិទ្ធកសាងសង្គមនិយមសហករណ៍ គឺចិញ្ចឹមគោឲ្យធាត់ រកជីរ លើកភ្លឺប្រឡាយ ដោះស្រាយជីវភាពប្រជាជន ដោះស្រាយទឹក បំផុសពីការដាំដុះកសាងប្រជាជន ពិបាកគឺប្រវត្តិរូប ។

(កំណត់ហេតុលេខ ២០៩)

# រឿងរ៉ាវរបស់យាយ គាវ នៅក្នុងសម័យខ្មែរក្រហម



យាយ អៀប គាវ

អស់រយៈពេលជាង២០ឆ្នាំកន្លងផុតទៅ ក៏ប៉ុន្តែការចងចាំនិងការឈឺចាប់នៅតែបន្តកើតមានចំពោះយាយ អៀប គាវ ។ ទាំងប្តីទាំងកូនប្រុសច្បងរបស់យាយ ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ។ ប្តីនិងកូនរបស់យាយ គាវ សុទ្ធតែធ្លាប់បានបម្រើខ្មែរក្រហម ។ នៅក្នុងភូមិទឹកអណ្តូង ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មានប្រវត្តិរូបអតីតយុទ្ធជននិងកម្មាភិបាលខ្មែរក្រហមទាំងអស់៦នាក់ ដែលរហូតមកដល់បច្ចុប្បន្នមិនដឹងថាស្លាប់ឬរស់ ។ នៅមានអ្នកភូមិជាច្រើនទៀតដែលមានសាច់ញាតិធ្លាប់បម្រើឲ្យរបបខ្មែរក្រហម (ជាផ្លូវការហៅថារបបកម្ពុជាប្រជាធិបតេយ្យ) ហើយត្រូវបាត់ខ្លួន ។

យាយ អៀប គាវ អាយុ៦៧ឆ្នាំ បានរៀបរាប់សាច់រឿងដែលទាក់ទិននឹងការស្លាប់របស់ប្តីគាត់ថា ពីង វ៉ុរ ឈ្មោះហៅក្រៅ វង់ ជាប្តីរបស់យាយ ធ្លាប់មានស្នាដៃជាច្រើនក្នុងការកសាងជាតិ រហូតទទួលបានមេដាយកិត្តិយសពីសម្តេចព្រះនរោត្តម សីហនុ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ យាយបានយករូបថតប្តីរបស់គាត់ដែលថតក្នុងឱកាសទទួលមេដាយកិត្តិយសពីព្រះករុណា មកបង្ហាញក្រុមស្រាវជ្រាវដើម្បីបញ្ជាក់ថាប្តីរបស់គាត់ជាមនុស្សស្លូតត្រង់និងបានជួយជាតិពិតមែន ។ ក្រោយមក ប្តីរបស់យាយបានចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហម ។ នៅទីបំផុតប្តីរបស់យាយក៏ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ។

យាយ អៀប គាវ និយាយថា "គេសួរខ្ញុំថា អ៊ឹងឯងបាត់ប្តីទៅធ្វើម៉េចទៅអ៊ំ? ខ្ញុំថា បើគាត់ធ្វើខុសពីមាគ៌ាអង្គការក៏ស្រេចតែអង្គការ ធ្វើម៉េចបើគាត់ខុសហើយ បើគាត់ត្រូវក៏ស្រេចតែអង្គការអាណិតគាត់" ។ យាយគាវមិនហ៊ានយំទេ គាត់តែងតែយកដៃបូតចុងច្រមុះបន្ទំភ្នែកអ្នកដទៃកុំឲ្យដឹងថាគាត់ចង់យំគ្រប់គ្រាដែលមានសំណួរថា "បាត់ប្តីយាយទៅណា?" ។ រហូតមកដល់សព្វថ្ងៃនេះ គាត់តែងតែនិយាយទាំងធ្មេចភ្នែកយ៉ាងយូរ បន្ទាប់មកទឹកភ្នែកក៏ហូរចេញពីភ្នែករបស់គាត់ ។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យាយបានមករស់នៅទីក្រុងភ្នំពេញ ដោយសារប្តីរបស់យាយធ្វើការនៅភ្នំពេញ ។ ប៉ុន្តែយាយនិងកូនមិនបានរស់ជួបជុំជាមួយប្តីទេ ។ ក្រោយពេលដែលប្តីរបស់យាយត្រូវចាប់យកទៅបាត់ គឺដល់វេនយាយម្តង ។ ខ្មែរក្រហមបានដឹកយាយ គាវ និងកូនតូចៗ៦នាក់ទៅជាមួយផង ទៅដាក់ឲ្យរស់នៅក្នុងភូមិចាមម្តុំព្រែកប្រា ។ ដោយសារតែអត់ឃ្លានខ្លាំងពេក យាយ គាវ បានយកផ្លែសន្ទូចមួយមកចងធ្វើជាសន្ទូចដើម្បីស្ទូចត្រីមកឲ្យកូនរបស់គាត់ហូប ។ មិនទាន់បានស្ទូចត្រីផង ស្រាប់តែមានមិត្តម្នាក់ឈ្មោះ ម៉ៅ មកកញ្ឆក់សន្ទូចពីដៃរបស់គាត់ និងហាមប្រាមគាត់ក្នុងបំណងល្អកុំឲ្យស្ទូចត្រីរបស់អង្គការ ប្រយ័ត្នមានគ្រោះថ្នាក់ដល់ជីវិត ។ ម៉ៅបានលើកឧទាហរណ៍អំពីគ្រួសារមួយដែលត្រូវសម្លាប់មួយពូជដោយសារតែស្ទូចត្រីរបស់អង្គការ÷ "មិត្តឆនដែលច្រៀងពីរោះ

នោះណាំ ត្រូវអង្គការយកទៅបាត់ទាំងកូនទាំងម៉ែដោយសារតែរឿងសន្ទូចនេះ» ។

តាមរយៈក្មួយម្នាក់ឈ្មោះ លោត យាយបានដឹងថា ប្តីរបស់យាយត្រូវខ្មែរក្រហមចាប់ដាក់ឡានហ្ស៊ីបដឹកទៅបាត់ពុំដឹងយកទៅណា ។ នៅឆ្នាំ១៩៧៩ សាច់ញាតិម្នាក់របស់យាយ គាវ បានមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ហើយបានឃើញរូបថតប្តីរបស់យាយ គាវ ក៏បានសរសេរឈ្មោះពីលើ ប៉ុន្តែដោយមិនស្គាល់នាមត្រកូល ក៏សរសេរថា ហ៊ិន វ៉ិរ ។

ប្រសិនបើរាប់តែក្នុងរង្វង់គ្រួសាររបស់យាយ គាវ គឺបាត់បង់សមាជិកអស់៤នាក់ គឺប្តីរបស់គាត់ឈ្មោះ វង់ ត្រូវខ្មែរក្រហមសម្លាប់ កូនប្រុសច្បងឈ្មោះ អ៊ឹង វណ្ណៈ ហៅ សើ បាត់ខ្លួនរហូតដល់បច្ចុប្បន្ន និងកូនស្រី២នាក់ទៀតស្លាប់ដោយសារជំងឺនៅក្នុងរបបខ្មែរក្រហម ។ យាយ គាវ នៅតែនឹកដល់ការស្លាប់និងបាត់ខ្លួនប្តីនិងកូនរបស់គាត់ ។ យាយបានយករូបថតកូនប្រុសច្បងដែលថតតាំងពីមុនឆ្នាំ១៩៧៥ មកបង្ហាញក្រុមស្រាវជ្រាវ និងប្រគល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីថែរក្សាទុក ។

របបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំតាមលទ្ធិផ្តាច់ការនិយមមហាលោភលោតផ្លោះមហាអស្ចារ្យដោយ ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន នៅរវាងឆ្នាំ១៩៧៥-៧៩ បានបណ្តាលឲ្យជីវិតប្រជាជនកម្ពុជារាប់លាននាក់ស្លាប់ ដូចជាករណីប្តីនិងកូនរបស់លោកយាយ គាវ ។ ភាពអយុត្តិធម៌នេះបានលាន់ឮសុសសាយទាំងនៅក្នុងស្រុកនិងនៅលើឆាកអន្តរជាតិរឹតតែខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅក្នុងខែធ្នូឆ្នាំ២០០២នេះ ប្រទេសចំនួនជាង១៥០នៅលើពិភពលោកដែលជាសមាជិកអង្គការសហប្រជាជាតិ បានចូលរួមបោះឆ្នោតគាំទ្រសេចក្តីសម្រេចចិត្តមួយដើម្បីចាត់វិធានការទៅលើភាពអយុត្តិធម៌ដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។

ការឈឺឆ្អាលនឹងភាពយុត្តិធម៌ដែលសម្រេចឡើងដោយប្រទេសទាំង១៥០នេះ គឺជាចំណុចរបត់មួយដែលនឹងចាប់ផ្តើមក្នុងផ្លូវដ៏វែងឆ្ងាយមួយ ឆ្ពោះទៅរកការព្យាបាលរបួសផ្លូវចិត្តរបស់យាយ គាវ ក៏ដូចជាជនរងគ្រោះរាប់លាននាក់ ដែលកំពុងទន្ទឹងរង់ចាំអស់រយៈពេលជិត២៨ឆ្នាំមកហើយ ។

សម្តីចុងក្រោយមុននឹងបញ្ចប់ការរៀបរាប់ប្រាប់យើងអំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម យាយ គាវ បាននិយាយថា «...ដល់និយាយអស់ទៅ ដូចជាធូរទ្រូងណាំក្មួយ» ។

**ឌ៉ាន់ថាន់ ពៅដារ៉ា**



អ៊ឹង វណ្ណៈ រូបថតមុនឆ្នាំ១៩៧៥

# ជនជាតិចិននៅកម្ពុជា

(តចប់)

## ៣) ជនជាតិចិននៅប្រទេសកម្ពុជា ប្រទេសចិន និង កម្ពុជាប្រជាធិបតេយ្យ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរយៈពេលបីឆ្នាំកន្លះ ជនជាតិចិនជាងពាក់កណ្តាលបានស្លាប់បាត់បង់ជីវិត ។ ការគាំទ្រពីមុនរបស់ជនជាតិចិនចំពោះក្រុមខ្មែរក្រហមកុម្មុយនិស្ត និងទំនាក់ទំនងមិត្តភាពរវាងសាធារណរដ្ឋប្រជាមានិតចិននិងរបបកម្ពុជាប្រជាធិបតេយ្យ មិនបានជួយការពារជនជាតិចិននៅកម្ពុជាទេ ។ អ្វីដែលជាលក្ខខណ្ឌអវិជ្ជមានសម្រាប់លទ្ធភាពនៃការរស់រានមានជីវិតរបស់ជនជាតិចិននោះគឺថា ជនជាតិចិនច្រើនមានការប្រឡូកក្នុងសកម្មភាពជំនួញ ហើយរស់នៅតាមទីក្រុងនិងទីប្រជុំជន ។ លក្ខណៈទាំងនេះបានធ្វើឲ្យជនជាតិចិនក្លាយជាសត្រូវដ៏គ្រោះថ្នាក់របស់បដិវត្តន៍ និងជាអ្នកកេងប្រវ័ញ្ចខ្មែរ ។ យោងតាមការឃោសនារបស់កម្ពុជាប្រជាធិបតេយ្យថា ជនជាតិចិនបានរស់នៅយ៉ាងសុខស្រួលដោយសារញើសឈាមរបស់ប្រជាជនខ្មែរ ។ ដោយសារអត្តសញ្ញាណរបស់ខ្លួនងាយរងគ្រោះជាងជនជាតិចាម ថៃ និង ឡាវ ជាញឹកញាយ ជនជាតិចិនគឺជាគោលដៅនៃអំពើហិង្សា ។ នៅតាមជនបទ ប្រជាជនត្រូវបានណែនាំឲ្យស្អប់ខ្ពើមអ្នកចំណូលថ្មីដែលរួមមានជនជាតិចិនជាច្រើនមកពីទីក្រុងផង ។ ប៉ុន្តែដូចដែលលើកឡើងពីមុនរួច មកហើយថា បទពិសោធន៍របស់ជនជាតិចិននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈខុសប្លែកគ្នាទៅតាមតំបន់និងពេលវេលា ។ អ្នកខ្លះត្រូវបង្ខំឲ្យធ្វើខ្មែរូបនីយកម្ម ហាមឃាត់មិនឲ្យនិយាយភាសាចិន បំបែកពីក្រុមគ្រួសារនិងសហគមន៍របស់ខ្លួន និងក្រុមជនជាតិផ្សេងទៀត ។ ជីវិតរបស់ជនជាតិចិនត្រូវគ្របដណ្តប់ទៅដោយការយកទៅអប់រំកសាង ធ្វើការធ្ងន់ ចាប់ឃុំឃាំង ការបង្អត់អាហារ ជំងឺតម្កាត់ ធ្វើការបាក់កម្លាំងនិងការភ័យខ្លាចត្រូវយកទៅសម្លាប់ចោល ។ ជនជាតិចិនជាច្រើនដែលមិនធ្លាប់ធ្វើការងារធ្ងន់ៗពីមុនមក ខ្លះត្រូវស្លាប់ដោយធ្វើការបាក់កម្លាំងនិងអត់អាហារបរិភោគ ។ រឿងរ៉ាវដ៏លំបាកវេទនារបស់ជនជាតិចិនដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិបាកនឹងយកមកបញ្ជាក់ឲ្យសមនឹងទំហំនៃការរំលោភសិទ្ធិមនុស្សណាស់ ។ កត្តានិងឥទ្ធិពលទូទៅអាចពិពណ៌នាបាន ប៉ុន្តែនៅពេលណាមួយនោះ កត្តាមួយចំនួន (ឬក៏គ្មានសោះ) ប្រហែលជានឹងកំណត់ជោគវាសនារបស់ជនជាតិចិនផងក៏មិនដឹង ។

### ៣.១) ជនកុម្មុយនិស្តកម្ពុជា និង ជនជាតិចិន

មុនពេលចូលមកកាន់អំណាចនៅឆ្នាំ១៩៧៥ ក្រុមខ្មែរកុម្មុយនិស្តកម្ពុជាបានទទួលការគាំទ្រគួរឲ្យកត់សម្គាល់ពីជនជាតិចិនដែលមានសមានចិត្តចំពោះខ្លួន ។ ការបិទសាលារៀនរបស់ជនជាតិចិនដោយលោក លន់ ណុល បានដុតកំហឹងជនជាតិចិនឲ្យក្លាយជាអ្នកប្រឆាំងនឹងរបបនេះ ហើយជាលទ្ធផល ជនជាតិចិនបែរមកគាំទ្រជនកុម្មុយនិស្តកាន់តែច្រើនឡើងៗ ។ ជនជាតិចិនខ្លះក៏បានចូលរួមជាមួយក្រុមខ្មែរកុម្មុយនិស្តតាមការអំពាវនាវរបស់សម្តេច សីហនុ ដើម្បីប្រយុទ្ធប្រឆាំងនឹងពួកសាធារណរដ្ឋនិយម ។ នៅតំបន់រំដោះ ជនជាតិចិនបានផ្តល់ព័ត៌មានដែលបកប្រែពីវិទ្យុក្រុងប៉េកាំង និងបានផ្គត់ផ្គង់ស្បៀងដល់ខ្មែរក្រហម ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី មកដល់ចុងឆ្នាំ១៩៧៣ មេដឹកនាំខ្មែរបានចាប់ផ្តើមសង្ស័យជនជាតិចិនដែលរស់នៅភាគខាងកើតទន្លេមេគង្គ ថាមានសមានចិត្តចំពោះបក្សកួកម៉េងតាំង និងធ្វើការឲ្យសេ.អ៊ី.អា ។ ពួកកុម្មុយនិស្តលែងត្រៀមខ្លួនទទួលយកសហវិជ្ជមានពហុជាតិនៃវប្បធម៌ សិល្បៈ និងទំនៀមទម្លាប់ទៀតហើយ ។ នៅក្នុងតំបន់រំដោះក្នុងឆ្នាំ១៩៧៣ ខិតប័ណ្ណរបស់ជនកុម្មុយនិស្តបានចាប់ផ្តើមពិពណ៌នាថា ជនជាតិចិនជាពួកមូលធននិយមដែលបាន "ជញ្ជក់ឈាមប្រជាជនខ្មែរ" ។

### ៣.២) ភាពខុសគ្នាទៅតាមតំបន់

ការស្ទាបស្ទង់ជាទូទៅមួយទៅលើប្រវត្តិរបស់អ្នកដែលបាន

ផ្តល់បទសម្ភាសន៍ ដែលបង្ហាញជូននៅក្នុងស្នាដៃសិក្សាស្រាវជ្រាវថ្មីៗនេះ អះអាងថា ការជម្លៀសគឺជាកត្តាសំខាន់ដែលកំណត់វាសនាជនជាតិចិននៅក្រោមការគ្រប់គ្រងអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលត្រូវបានបង្ខំឲ្យចេញពីទីក្រុងនិងទីប្រជុំជន ជនជាតិចិនភាគច្រើនបានធ្វើដំណើរទៅភូមិស្រុកនិងជនបទនៅភាគខាងកើតនិងនិរតីនៃប្រទេសកម្ពុជា ។ បន្ទាប់មកត្រូវជម្លៀសបន្តទៅភូមិភាគពាយ័ព្យ ។ ដូចដែលបានបញ្ជាក់រួចមកហើយថា អ្នកដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ទំនងជាមិនសូវនៅរស់រានមានជីវិតទេ ។ យោងតាមអតីតនាយទាហានសាធារណរដ្ឋខ្មែរម្នាក់បានឲ្យដឹងថា កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យបានសម្លាប់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនិងជនជាតិចិនយ៉ាងច្រើន ។ នាយទាហានរូបនោះជឿជាក់ថា ជនជាតិចិននៅស្រុកកំពង់ត្រាច ខេត្តកំពត និងស្រុកលង្វែក ខេត្តកំពង់ឆ្នាំងត្រូវបានសម្លាប់ចោលទាំងអស់នៅអំឡុងឆ្នាំ១៩៧៧និង១៩៧៨ ។ សាក្សីម្នាក់ទៀតបានរៀបរាប់អំពីរបៀបដែលជនជាតិចិនត្រូវបានយកទៅសម្លាប់ចោលដោយសារតែអ្នកទាំងនោះបានប្រព្រឹត្តកំហុសឆ្គងបន្តិចបន្តួចប៉ុណ្ណោះ ឧទាហរណ៍ដូចជាជនជាតិចិនពីរនាក់បានលួចដំឡូងមួយមើមមកពីចំការនៅក្នុងឃុំមួយ ។ អ្នកទាំងពីរត្រូវចាប់ខ្លួននាំយកទៅកន្លែងមួយចម្ងាយ៥០០ម៉ែត្រពីភូមិ រួចក៏សម្លាប់ចោលតែម្តង ។ ហុង វ៉ា អ្នករស់រានមានជីវិតម្នាក់ពី ភូមិភាគពាយ័ព្យ ក៏បានឲ្យដឹងថា បើគាត់និយាយត្រង់ថាគាត់ធ្លាប់ ធ្វើគ្រូបង្រៀននោះ ខ្មែរក្រហមយកគាត់ទៅវាយចោលបាត់ទៅហើយ ។ គាត់បាននិយាយថា គាត់ជាអ្នកលក់ចេកចៀន នៅផ្សារថ្មីនៅទីក្រុងភ្នំពេញ ។ រឿងជាច្រើនបែបនេះបានកើតមាននៅតំបន់៣៧ភូមិភាគបស្ចិម ។ នៅទីនោះជនជាតិចិន គឺជាមុខសញ្ញាដែលត្រូវយកទៅសម្លាប់ចោល ។ ជាទូទៅ ជនជាតិចិនត្រូវបានផ្តល់អាហារឲ្យហូបតិចជាងអ្នកដទៃ ប៉ុន្តែត្រូវយកទៅសម្លាប់ចោលច្រើនជាងអ្នកដទៃ ។ ជាពិសេស គឺនៅឆ្នាំ១៩៧៧ ជនជាតិចិនត្រូវបានចោទប្រកាន់ថាក្បត់ប្រទេសចិនដែលប្រការនេះធ្វើឲ្យស្ថានភាពរស់នៅរបស់ជនជាតិចិនរឹតតែមិនទៀងទាត់ថែមមួយកម្រិតទៀត ។

ដូចដែល យៀវនិន កត់សម្គាល់កាលពីឆ្នាំ១៩៩៦ថា ជនជាតិភាគតិចចិននៅតំបន់មួយចំនួននៃភូមិភាគនិរតីប្តូបូព៌ា ដែលជាក្រុមមួយតូច មានការហូបចុកគ្រាន់បើជាងអ្នកនៅភូមិភាគពាយ័ព្យនិងបស្ចិម រហូតដល់ឆ្នាំ១៩៧៨ ។ លី ឈីវហា រស់នៅខេត្តព្រៃវែងភូមិភាគបូព៌ាអស់រយៈពេល៨ខែ កាលពីឆ្នាំ១៩៧៥ រួមជាមួយមនុស្ស៦គ្រួសារផ្សេងទៀតដែលមកពីទីក្រុងភ្នំពេញ ។ អ្នកស្រីបានមករស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋាន៧០គ្រួសារដែលសុទ្ធតែមានស្មារតីភក្តីចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ដំបូងមានអាហារហូបចុកគ្រប់គ្រាន់ បន្ទុកការងារក៏តិចតួច ហើយគាត់មិនដែលឮនរណាម្នាក់និយាយអំពីការសម្លាប់ទេ ។ តាមសម្តីរបស់អ្នកស្រី តាំង អេង បានឲ្យដឹងថាជនជាតិចិនដែលរស់នៅតំបន់១៣ ត្រូវបានបង្ខំឲ្យរស់នៅក្នុងភូមិចិនដាច់ស្រយាលមួយ ។ តាំង អេង មិនបានរៀបរាប់អំពីការប្រព្រឹត្តមិនគប្បីណាមួយដោយហេតុផលពូជសាសន៍ឡើយ ប៉ុន្តែគាត់នៅចាំថា ជនជាតិចិនត្រូវតែត្រឡប់ទៅប្រទេសចិនវិញ ជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ មានតែជនជាតិខ្មែរប៉ុណ្ណោះអាចរស់នៅប្រទេសកម្ពុជាបាន ។ ជនជាតិចិនរស់នៅខេត្តក្រចេះ តំបន់៥០៥ បានទទួលរងការលំបាកវេទនាតិចជាងជនជាតិចិនដែលរស់នៅតំបន់ផ្សេងៗទៀត ។ ជនជាតិចិនទាំងនេះមានអាហារហូបគ្រប់គ្រាន់ ហើយអាចនិយាយភាសាចិនជាលក្ខណៈឯកជនបានទៀតផង ។ លក្ខខណ្ឌរស់នៅបែបនេះមិនមានដូចគ្នានៅគ្រប់តំបន់ទេ ។ នៅខេត្តកំពតដែលស្ថិតក្នុងភូមិភាគនិរតីដែរនោះ មានជនជាតិចិនតែមួយភាគប្រាំប៉ុណ្ណោះដែលមានវាសនារស់រានមានជីវិត ។ នៅឃុំព្រៃធំនិងឃុំសម្រាប់បុត្រ ខេត្តកំពតបុរសជនជាតិចិនត្រូវបានយកទៅសម្លាប់ចោលទាំងអស់ ។

### ៣.៣) ភាពខុសគ្នាអំពីការបញ្ជា

កម្រិតទទួលខុសត្រូវផ្សេងៗពីគ្នាទៅលើជនជាតិចិននៅតំបន់ផ្សេងៗ គឺស្ថិតនៅក្រោមថ្នាក់ដឹកនាំខ្មែរក្រហមដែលមានអំណាចបញ្ជា ។ សមាជិកបក្សមិនបំបាត់ចោលនូវភាពខុសគ្នាដ៏សំខាន់ខាងផ្នែកគំនិតនិងការអធ្យាស្រ័យដែលលេចឡើងនិងជះឥទ្ធិពលទៅលើតំបន់នានាក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំទាំងនោះឡើយ ។ ជាឧទាហរណ៍ជាក់ស្តែង កម្ពុជាប្រជា-

ធិបតេយ្យនៅតំបន់២៤ក្នុងខេត្តព្រៃវែង មិនញញើតនឹងសម្លាប់ប្រជាជន១៧មេសាភ្លាមៗទេក្រោយពីបានចោទថាជាមូលធនចិន។ ដូចគ្នានេះដែរ មន្ត្រីកម្ពុជាប្រជាធិបតេយ្យម្នាក់ឈ្មោះ វ៉ា ដែលរស់នៅខេត្តកំពត ស្អប់ជនជាតិចិន។ វ៉ា បានប្រកាសថាជនជាតិចិនជាអ្នកជិះជាន់ប្រជាជនខ្មែរ ហើយបើមិនយកអ្នកទាំងនោះទៅអប់រំទេ មានតែយកទៅសម្លាប់ចោល។ នៅឆ្នាំ១៩៧៦ វ៉ា បានរៀបចំផែនការរកចាប់ខ្លួនពួកមូលធនជាពិសេសជនជាតិចិនតែម្តង។ វ៉ា បានធ្វើដូច្នេះម្តងទៀតនៅឆ្នាំបន្ទាប់។ ប៉ុន្តែក៏មានឧទាហរណ៍ដទៃទៀតបញ្ជាក់អំពីការដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមានសមានចិត្តចំពោះជនជាតិចិនដែរ។ ជនជាតិចាម វៀតណាម និងចិន ត្រូវបានប្រមូលផ្តុំដាក់នៅផ្សារក្រូចឆ្មារដើម្បីសម្លាប់ចោល ប៉ុន្តែពេលនោះ កម្មាភិបាលដែលទទួលខុសត្រូវរឿងនេះដែលជាកូនកាត់ខ្មែរ-ចិនទាជីវចេះនិយាយភាសាចិន បានបញ្ជាឲ្យកូនចៅកុំឲ្យសម្លាប់ជនជាតិចិនទាំងនេះ ហើយឲ្យជម្លៀសទៅកាន់ស្រុកស៊ីងត្រង់ (ខ្មែរ-ចិនទាជីវនៅស្រុកក្រូចឆ្មារ)។ នៅកន្លែងមួយទៀត មានអ្នកជំនួញចិនទាជីវម្នាក់មិនបានរងការឈឺចាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ ពីព្រោះកម្មាភិបាលដែលទទួលបន្ទុកគ្រប់គ្រងគាត់ ចាប់អារម្មណ៍និងជៅតែមន្ត្រីរបស់របបមុនៗប៉ុណ្ណោះ។ ដូច្នេះឃើញថា ក្នុងរូបភាពខ្លះ ភាពខុសគ្នាតាមតំបន់ហាក់ដូចជាពាក់ព័ន្ធទៅនឹងអ្នកដែលមានអំណាចបញ្ជាដែរ។ ប្រការនេះប្រហែលជាផ្តល់នូវការការពារខ្លះៗដល់ជនជាតិចិនទៅតាមកាលៈទេសៈជាក់ស្តែង។ ប៉ុន្តែការផ្លាស់ប្តូរថ្នាក់ដឹកនាំនៅក្នុងតំបន់មួយ ឬក៏នៅថ្នាក់ទាបជាងនេះនៃឋានានុក្រមបក្ស អាចកែប្រែរូបភាពបែបនេះជាដុំកំភួន ជាពិសេសបើអ្នកទាំងនោះមានការពាក់ព័ន្ធទៅនឹងការបន្ទុចបង្អាក់ផ្នែកនយោបាយក្នុងបក្ស



ទីប្រឹក្សាចិននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

និងវិសុទ្ធកម្មនានា ដូចជាករណីនៅខេត្តកោះកុងជាតឹកតាងស្រាប់ ។ នៅតំបន់១១នៃខេត្តកោះកុង ជនជាតិចិនត្រូវបានការពារដូចជាករណីខាងលើនេះដែរ ពីសំណាក់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលមានគំនិតសេរីនិយមគួរសម ។ ប៉ុន្តែជនជាតិចិនត្រូវបានបោសសម្អាតដោយពួកកងទ័ពដាច់ខាតមកពីមជ្ឈិម ។

## ៣.៤) ការផ្លាស់ប្តូរទីលំនៅ និងការជួបលំបាកក្នុងការងារ

អ្វីដែលប៉ះពាល់មួយទៀតចំពោះជោគវាសនារបស់ជនជាតិចិននៅតំបន់នានាខាងលើ គឺបទពិសោធន៍នៃការផ្លាស់ប្តូរទីលំនៅ ជាពិសេសលក្ខណៈតំបន់និងកម្រិតនៃការលំបាកទាំងការងារទាំងការរកចំណីអាហារហូប និងរបស់ដែលត្រូវការជាចាំបាច់ផ្សេងទៀត ។ ជនជាតិចិននៅទីក្រុងភាគច្រើនមិនស៊ាំទៅនឹងការងារធ្ងន់ៗប្រើកម្លាំងទេ ទោះបីជាអ្នកដែលមានកំណើតនៅតាមជនបទស្រុកស្រែចម្ការក៏ដោយ ។ នៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ទោះបីជាភាពខុសគ្នារវាងការសម្លាប់និងការបង្ខំឲ្យធ្វើការងារហួសកម្លាំងដោយចេតនាហាក់ដូចជាមានតិចតួច ហើយសូម្បីតែមិនត្រឹមត្រូវក៏ដោយ ក៏វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ជាញឹកញាប់ កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យមិនបានសម្លាប់ជនជាតិចិនដោយសារតែពូជសាសន៍ទេ ប៉ុន្តែកម្ពុជាប្រជាធិបតេយ្យបង្ខំឲ្យជនជាតិចិននិងប្រជាជនថ្មីដទៃទៀតធ្វើការធ្ងន់ធ្ងរជាងកសិករខ្មែរ ។ ដោយពុំមានអាហារគ្រប់គ្រាន់ អ្នកខ្លះបានស្លាប់ដោយសារការអត់ឃ្លាន ។ យៀវនិន (ឆ្នាំ១៩៩៦) បានកត់សម្គាល់ថា ជនភៀសខ្លួនខ្មែរបានរាយការណ៍ថា ជនជាតិភាគតិចចិនរងទុក្ខខ្លាំងជាងគេបង្អស់ ដោយសារមិនធ្លាប់ធ្វើការងារធ្ងន់នៅស្រែចម្ការ ទោះបីជាអ្នកទាំងនោះមានដើមកំណើតនៅជនបទក្តី ។ ជនជាតិចិនត្រូវតែខំប្រឹងធ្វើការឲ្យខ្លាំងជាងអ្នកមូលដ្ឋាន ហើយរស់នៅលំបាកវេទនាជាងប្រជាជនមូលដ្ឋាន ។ នៅតំបន់៣៧ ក្នុងចំណោមយុវជនយុវនារីក្មេងៗ១ម៉ឺននាក់ដែលភាគច្រើនជាជនជាតិចិនលើកទំនប់ដីកប្រឡាយ មាន២០ភាគរយនៃអ្នកទាំងនោះបានស្លាប់នៅឆ្នាំ១៩៧៦ដោយសារអត់អាហារនិងជំងឺតម្កាត់ ។ ពួកឈ្លបកម្ពុជាប្រជាធិបតេយ្យក៏សម្លាប់អ្នកធ្វើការដែលមានកម្លាំងល្ងិតល្ហៃដទៃទៀតដែរ ។ ស្ថានការណ៍កាន់តែធ្ងន់ធ្ងរទៅៗនៅពេលដែលភាពអត់ឃ្លានចេះតែរាលដាលខ្លាំងឡើងៗនៅតាមតំបន់មួយចំនួននៅចុងឆ្នាំ១៩៧៧ ។ ដំណើររឿងលំបាកវេទនានេះវាស៊ីគ្នាទៅនឹងការរកឃើញរបស់ ស៊ីវ ហេដឌ័រ ដែលថា ជនជាតិចិនស្លាប់ដោយឃាតកម្ម ការបង្អត់អាហារ និងជំងឺ ក្នុងចំនួនស្មើគ្នា ។ ឧទាហរណ៍ៈ អ្នកផ្តល់បទសម្ភាសន៍ម្នាក់រាយការណ៍ថា ក្នុងចំណោមជនជាតិចិន៤៦០០នាក់រស់នៅភូមិជាមួយគាត់ មានមនុស្សជាង១០០០នាក់បានស្លាប់ដោយសារអត់អាហារនិងជំងឺតម្កាត់ ហើយមានតែ១០នាក់ប៉ុណ្ណោះដែលត្រូវបានសម្លាប់ដោយកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៧ ។ លើសពីនេះទៀតវាជាការសំខាន់ដែរក្នុងការពិចារណាអំពីវិសាលភាពនៃការបន្ទុចបន្ទាក់ ឬការបំផ្លិចបំផ្លាញបណ្តាញសង្គមជនជាតិចិន ។ នៅក្នុងអំឡុងពេលនៃការធ្វើដំណើរនិងការតាំងទីលំនៅជាថ្មីរបស់ជនជាតិចិន និងភាពងាយទទួលរងគ្រោះថ្នាក់ដែលកាន់តែកើនខ្ពស់ឡើងៗ ។ ដើម្បីជីវិតរស់ ជនជាតិចិនខ្លះបានសម្របខ្លួនរស់នៅជាមួយប្រជាជនខ្មែរ ។

## ៣.៥) ការហាមឃាត់ខាងវប្បធម៌

កម្រិតនៃភាពទទួលស្របមិនប្រឆាំងនឹងវប្បធម៌ដទៃក៏មានឥទ្ធិពលទៅលើអត្រានៃការរស់រានមានជីវិតរបស់ជនជាតិចិននៅក្នុងតំបន់ផ្សេងៗដែរ ។ ការហាមឃាត់ប្រឆាំងនឹងអាកប្បកិរិយាមួយចំនួន មិនគ្រោះថ្នាក់ដល់ជីវិតដោយផ្ទាល់ទេ ប៉ុន្តែវាក្លាយជាហេតុផលនិងលក្ខខណ្ឌសម្រាប់ការស្លាប់របស់ជនជាតិចិនជាច្រើននាក់ ។ បើចង់រស់ ជនជាតិចិនត្រូវតែបង្ខំចិត្តសម្របខ្លួនតាមរបៀបរបបរស់នៅរបស់ប្រជាជនខ្មែរ ។ សម្រាប់អ្នកខ្លះ ដូចជា ម៉ុក ឆុត ជាជនជាតិចិនមកពីភ្នំពេញ បានប្រាប់បញ្ចូលគ្នាទាំងបង្ខំនូវវប្បធម៌ខុសគ្នាដូចជា ការហូបរួមជាមួយជនជាតិខ្មែរគឺមានសារសំខាន់ ព្រោះថា ម៉ុក ឆុត និងក្រុមគ្រួសារគាត់មិនចេះរកត្រីឬស្វែងរកម្ហូបអាហារហូបផងទេ ។

ការហាមមិនឲ្យនិយាយភាសាចិនហាក់ដូចជារាលដាលឆាប់បំផុត ដែលនេះជាវិធីសម្រាប់យកធ្វើជាលេសក្នុងការធ្វើទុក្ខបុកម្នេញ ។ ប្រាកដហើយថា ការស្លាប់ដែលទាក់ទងនឹងការប្រើភាសាចិនជាភាសាមួយដែលត្រូវហាមឃាត់ អាចនឹងត្រូវបកស្រាយថា

ជាហេតុផលជាតិសាសន៍ ហើយក៏អាចពន្យល់ដូចអ្វីដែល ឆេនដល័របានឲ្យហេតុផលទៅលើការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិចចាម ។ នៅក្នុងការរំលោភដែលទាក់ទងនឹងភាសានេះ គឺមានលក្ខណៈជាការរំលោភទៅលើបទបញ្ជាអ្នកមានអំណាច ជាជាងការបង្ហាញអំពីក្រុមជនជាតិមួយណានោះ ។ ពោលគឺរបបកម្ពុជាប្រជាធិបតេយ្យស្អប់អ្នកដែលប្រឆាំងនឹងវិន័យ ជាជាងស្អប់ពូជសាសន៍ខុសគ្នា ។

ជាទូទៅ អ្នកទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានហាមឃាត់មិនឲ្យនិយាយភាសាខ្មែរក្នុងលក្ខណៈទន់ភ្លន់ ឬមិនឲ្យនិយាយគ្រាមភាសាចិនផ្ទាល់ឡើយ ។ មានករណីលើកលែងដែរ ។ អ្នកខ្លះមិនហ៊ានសូម្បីតែខ្សឹបគ្នាផង ខ្លាចឈ្លបលួចស្តាប់ៗ ។ អ្នកខ្លះទៀតនិយាយភាសាចិនដោយសេរី ដោយពុំមានការយកទោសពៃរ៍អ្វីទាំងអស់ ។ ឈឹម កសិករមកពីខេត្តបាត់ដំបង បានរំឭកឡើងវិញថា មានពេលមួយនោះ ខ្មែរក្រហមឮគាត់និយាយភាសាចិន ។ ប្រការនេះធ្វើឲ្យមេកងរិះគន់ ឈឹម ហើយផ្តាច់របបអាហារគាត់ពេញមួយថ្ងៃ ។ ចាប់ពីពេលនោះមក ឲ្យតែអ្នកណាហ៊ាននិយាយភាសាចិន គឺត្រូវចាប់ខ្លួនទាំងអស់ ។ ការសរសេរអក្សរចិនក៏ត្រូវហាមឃាត់ដែរ ។ អ្នកដែលមិនធ្វើតាមការហាមឃាត់ ត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ឬយកទៅសម្លាប់ចោល ។ អ្នកខ្លះប្រឡំមាត់និយាយចិន ហើយក្នុងចំណោមអ្នកប្រឡំមាត់ទាំងនេះ មានអ្នកខ្លះត្រូវយកទៅធ្វើទារុណកម្ម ចំណែកអ្នកខ្លះទៀតត្រូវបាត់បង់ជីវិត ។ នៅភូមិដប់ មានស្ត្រីវ័យកណ្តាលពីរនាក់បានភ្លេចខ្លួននិយាយភាសាចិន ។ ថ្ងៃបន្ទាប់មក ស្ត្រីទាំងពីរត្រូវបានយកទៅសម្លាប់ចោលដូចជាករណីជនជាតិចិន២៧គ្រួសារដទៃទៀតដែរ ។ ម្យ៉ាងវិញទៀត កត្តាតំបន់និងកត្តាដទៃទៀតក៏ជះឥទ្ធិពលដល់កម្រិតនៃការអត់ឱនទាក់ទងនឹងការប្រើភាសាដែលមិនមែនជាភាសាខ្មែរដែរ ។ ភាសាមានសារសំខាន់ដល់ការរស់រានមានជីវិត ។ ដោយគ្មានមធ្យោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការប្រាស្រ័យទាក់ទង ជនជាតិចិនកាន់តែងាយទទួលគ្រោះថ្នាក់ជាងអ្នកដទៃទៀតចំពោះមុខរបបកម្ពុជាប្រជាធិបតេយ្យ ។

កត្តាដទៃទៀតដែលជះឥទ្ធិពលដល់ស្ថានភាពរស់នៅរបស់ជនជាតិចិននៅទូទាំងប្រទេសកម្ពុជា គឺការបំបែកចេញពីសហគមន៍ ឬពីក្រុមគ្រួសារ ។ ដូចជាករណី តាំង អេង ដែលពិពណ៌នាថា នៅតំបន់១៣នៃខេត្តតាកែវ ជនជាតិចិនត្រូវបានបង្ខំឲ្យរស់នៅតាមភូមិចិនដាច់ដោយឡែកដូចជា នៅតំបន់២ដែរ ។ ការបែងចែកជនជាតិក៏ត្រូវបានធ្វើឡើងនៅបាត់ដំបង កំពង់ឆ្នាំង និងកំពង់ស្ពឺ ។ នៅក្នុងករណីខ្លះ ការបែងចែកដំបូងត្រូវបានធ្វើឡើងដោយយោងទៅតាមសាវតារជាតិនៃពូជសាសន៍ ប៉ុន្តែក្រោយមក ជនជាតិចិនត្រូវបានបញ្ជូនឲ្យទៅរស់នៅលាយឡំជាមួយជនជាតិខ្មែរ ។ ម្យ៉ាងវិញទៀត ក្នុងចំណោមជនជាតិចិនទាំងនេះ ការសម្របសម្រួលទៅតាមសង្គមមិនមែនជាគ្រោះថ្នាក់ដល់ជីវិតទេ ប៉ុន្តែការបែងចែកពូជសាសន៍ធ្វើឲ្យជនជាតិចិនកាន់តែងាយនឹងក្លាយទៅជាមុខសញ្ញាមួយ ។ ការបែងចែកប្រហែលជាកាន់តែគ្រោះថ្នាក់ថែមទៀតនៅពេលដែលកុមារត្រូវបានបោកបញ្ឆោតឲ្យបែកពីឪពុកម្តាយ និងយកទៅធ្វើការជាមួយកុមារដទៃទៀត ហើយកុមារទាំងនោះមានឱកាសជួបឪពុកម្តាយបានតិចតួចណាស់ ។ ជាក់ស្តែងដូចជាករណី មុត ឆុត គាត់បានជួបកូនៗដែលមានអាយុពី៨-១០ឆ្នាំ តែមួយដងប៉ុណ្ណោះក្នុងរយៈពេលពីរខែ ។ វិធីបែបនេះបានធ្វើឲ្យប៉ះពាល់ជាប្រព័ន្ធដល់រចនាសម្ព័ន្ធសង្គមដែលទាក់ទងទៅនឹងភាពគង់វង្សនៃវប្បធម៌និងសហគមន៍ ។ ជាងនេះទៅទៀត កាលៈទេសៈទាំងនេះច្បាស់ជាបានបង្កើតនូវការបង្ខិតបង្ខំកាន់តែខ្លាំងឡើង ហើយបង្កើននូវលទ្ធភាពនៃការល្មើសច្បាប់ថែមទៀត ។ ប៉ុន្តែការបែងចែកក្រុមពូជសាសន៍ប្រហែលជាបានដើរតួស្ថាបនាទំនាក់ទំនងសហគមន៍ខ្លះដោយឯកឯង ។

## ៣.៦) ការគំរាមកំហែងចំពោះកម្ពុជាប្រជាធិបតេយ្យ

អារម្មណ៍នៃការគំរាមកំហែងនោះ ទោះពិតឬមិនពិតក្តី ក៏ជាកត្តាកំណត់សំខាន់មួយដែលបង្កើតជាលក្ខខណ្ឌនានានៃជីវិតរស់នៅរបស់ជនជាតិចិននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ លក្ខខណ្ឌខ្លះត្រូវបានភ្ជាប់ទៅនឹងវិសុទ្ធកម្មផ្ទៃក្នុងប្រឆាំងនឹងជនជាតិចិននៅក្នុងជួរបក្ស ដែលទាក់ទងនឹងការជ្រៀតចូលរបស់បក្សពួកម៉េងតាំង ។ ការស៊ើបអង្កេតធ្វើឡើងដោយកម្ពុជាប្រជាធិបតេយ្យនៅដើមឆ្នាំ១៩៧៨ បានបញ្ជាក់អំពីសេចក្តី

ភ័យខ្លាចរបស់ខ្លួនថា សមាជិកកម្ពុជាប្រជាធិបតេយ្យដែលមានសែស្រឡាយចិន កំពុងតែគាំទ្រដល់បក្សពួកម៉េងតាំង និងមានផែនការក្បត់ដណ្តើមអំណាចដោយសហការជាមួយកងទ័ពវៀតណាម ។ បន្ទាប់ពីរកឃើញដូច្នេះ នៅដើមឆ្នាំ១៩៧៨ កម្ពុជាប្រជាធិបតេយ្យបានធ្វើវិសុទ្ធកម្មមួយនៅក្នុងបក្ស និងចំណោមជនជាតិចិននៅទីក្រុងនិងខេត្តនានា ។ នៅភូមិកំចាយ ជនជាតិចិនមួយចំនួនត្រូវបានសម្លាប់ដោយចោទប្រកាន់ថាជាភ្នាក់ងាររបស់ពួកម៉េងតាំង ។ នៅទីក្រុងភ្នំពេញនិងខេត្តកណ្តាល មានជនជាតិចិនប្រមាណ២៦នាក់ត្រូវបានចាប់យកទៅធ្វើទារុណកម្មរហូតដល់ស្លាប់នៅគុកទួលស្លែង ។

### ៣.៧) ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងប្រទេសចិន

ទោះជារដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនបានបង្ហាញឆន្ទៈជ្រៀតជ្រែកចូលក្នុងនយោបាយកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ១៩៦០ក៏ដោយ មិនថានៅពេលនោះឬនៅពេលកម្ពុជាប្រជាធិបតេយ្យកំពុងកាន់អំណាចទេ ក៏រដ្ឋាភិបាលចិនមិនដែលតំណាងឲ្យជនជាតិចិននៅក្រៅប្រទេសម្តងណាដែរ ។ ជាពិសេស នៅក្នុងករណីកម្ពុជាប្រជាធិបតេយ្យតែម្តង រដ្ឋាភិបាលចិនមិនដែលរវល់នឹងជនជាតិចិនដែលគាំទ្រការថែរក្សាទំនាក់ទំនងនយោបាយជាមួយរបបកម្ពុជាប្រជាធិបតេយ្យដែលសម្លាប់ជនជាតិរបស់ខ្លួនឡើយ ។ ដំបូង កម្ពុជាប្រជាធិបតេយ្យទទួលបានការគាំទ្រគួរឲ្យកត់សម្គាល់ពីរដ្ឋាភិបាលចិន ។ ចាប់ពីឆ្នាំ១៩៧០មក ចិនបានជំរុញឲ្យមានសម្ព័ន្ធភាពរវាងសម្តេច សីហនុ ជាមួយពួកខ្ទុមកុម្មុយនិស្ត ។ ចិនបានផ្តល់ការគាំទ្រដល់ទស្សនវិស័យមនោគមវិជ្ជារ៉ាឌីកាល់របស់កម្ពុជាប្រជាធិបតេយ្យ ហើយឆ្លើយតបទៅនឹងសំណើសុំជំនួយខាងសេដ្ឋកិច្ចនិងយោធា ។ បញ្ហានៅក្នុងទំនាក់ទំនងរវាងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងរដ្ឋាភិបាលចិន រឹតតែជិតស្និទ្ធឡើងៗ គឺមិនមែនដោយសារផលវិបាកនៃការធ្វើទុក្ខបុកម្នេញរបស់កម្ពុជាប្រជាធិបតេយ្យទៅលើជនជាតិភាគតិចចិនទេ ប៉ុន្តែគឺដោយសារការផ្លាស់ប្តូរនយោបាយនៅប្រទេសចិន និងលក្ខខណ្ឌនយោបាយភូមិសាស្ត្រនៅក្នុងតំបន់ ។ គ្មានអ្វីជាមន្ទិលសង្ស័យទេថា ថ្នាក់ដឹកនាំចិនបានដឹងអំពីការប្រព្រឹត្តរបស់កម្ពុជាប្រជាធិបតេយ្យ មកលើជនជាតិចិននៅកម្ពុជា ។ អៀង សារី បានសារភាពអំពីទង្វើនេះនៅឆ្នាំ១៩៧៧ ។ ជាងនេះទៅទៀត រដ្ឋាភិបាលចិនក៏បានទទួលសំណូមពរពីសំណាក់ជនជាតិចិនកាត់ខ្មែររស់នៅទីក្រុងប៉ារីស ឲ្យបង្កើតគណៈកម្មាធិការជួយសង្គ្រោះមួយ ក្នុងគោលបំណងសង្គ្រោះជនជាតិចិនពីការសម្លាប់រង្គាល ។ រដ្ឋាភិបាលចិនបានប្រាប់ទៅគណៈកម្មាធិការនោះឲ្យអត់ធ្មត់សិន ។ អ្នកនាំពាក្យចិនបានបន្តស្ងើចសរសើរជាសាធារណៈដល់កម្ពុជាប្រជាធិបតេយ្យ ។ ទីប្រឹក្សាចិននៅកម្ពុជាមិនបានផ្តល់ការគាំទ្រដល់ជនជាតិចិនទេ ។ ជាថ្មីម្តងទៀត ទីប្រឹក្សាចិននៅកម្ពុជាឆ្លើយតបទៅនឹងអ្នកចោទប្រកាន់កម្ពុជាប្រជាធិបតេយ្យថា គួរតែ“អត់ធ្មត់” ។ ទស្សនវិស័យរបស់រដ្ឋាភិបាលចិនចំពោះកម្ពុជាប្រជាធិបតេយ្យ ត្រូវទទួលឥទ្ធិពលយ៉ាងសំខាន់ដោយសារនយោបាយផ្ទៃក្នុងរបស់ចិន តួយ៉ាងដូចជាការស្លាប់របស់ប្រធាន ម៉ៅ ការចាប់ខ្លួន “ក្រុមបួននាក់” និងនយោបាយភូមិសាស្ត្រតំបន់ដែលកំពុងតែប្រែប្រួល ។ និយាយឲ្យខ្លី ការដឹកនាំរបស់ លោក តេង ស៊ាវភីង និងរ៉ាឌីកាល់និយមរបស់កម្ពុជាប្រជាធិបតេយ្យ មិនសូវស៊ីសង្វាក់គ្នាទេ ។ ប្រការនេះកាន់តែច្បាស់ទៅទៀតនៅពេលដែលរដ្ឋាភិបាលចិនបានសម្តែងនូវការស្ទាក់ស្ទើរ ក្នុងការគាំទ្រការវាយប្រហាររបស់កម្ពុជាប្រជាធិបតេយ្យទៅលើប្រទេសវៀតណាម ជាពិសេសនៅក្រោយឆ្នាំ១៩៧៧ ។ ដើមឡើយ រដ្ឋាភិបាលចិនបានបង្ហាញនូវឆន្ទៈថាខ្លួនជាអ្នកគាំទ្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងតំបន់ ។ នៅក្នុងឱកាសប្រារព្ធពិធីបុណ្យខួបរំឭកថ្ងៃជ័យជំនះ១៧មេសា ឆ្នាំ១៩៧៦ នៅទីក្រុងប៉េកាំង ដែលជាខួបគម្រប់មួយឆ្នាំនៃការរំដោះប្រទេសកម្ពុជា មានការប្រកាសថា ប្រជាជនចិននឹងប្រយុទ្ធរួមគ្នាជាមួយប្រជាជនកម្ពុជា ហើយបោះជំហានទៅមុខជាមួយគ្នាជារៀងរហូត ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៧ទៅ រឿងបែបនេះទំនងលែងកើតឡើងទៀតហើយ ចំណែកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យកាន់តែរឹងរូសនៅក្នុងទំនាក់ទំនងជាមួយអ្នកដែលខត្តម្ពខ្លួនដ៏សំខាន់ជាងគេនេះ ។ ទោះបីជាខ្លួនមានការព្រួយបារម្ភអំពីសន្តិសុខកម្ពុជាក្នុងខណៈដែលទ័ពវៀតណាមមានប្រៀបលើកងទ័ពកម្ពុជា ភាពលែងមានចេតនារបស់ចិនក្នុងការជួយគាំទ្រការបង្កជម្លោះតាមព្រំដែន

របស់កម្ពុជាប្រជាធិបតេយ្យ គឺអាចស្តែងចេញតាមរយៈការព្រួយបារម្ភដែលថាការវិវត្តន៍នយោបាយភូមិសាស្ត្រ អាចបន្ទុចបន្ទាក់ដល់កម្មវិធីទំនើបកម្មរបស់ចិន ។

### ៤) សេចក្តីសន្និដ្ឋាន

កម្ពុជាប្រជាធិបតេយ្យត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ជនជាតិចិនជាច្រើននាក់នៅកម្ពុជា នៅក្នុងដំណើរការកសាងនូវសង្គមបដិវត្តថ្មីមួយ ។ ទិន្នន័យសិក្សាស្រាវជ្រាវបង្ហាញច្បាស់ថា ក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ក្រុមជនជាតិភាគតិចទាំងអស់បានទទួលរងទុក្ខវេទនាខ្លាំងណាស់ ។ កម្រិតនៃការឈឺចាប់នឹងប្រការថាតើជាតិពន្ធុជាមូលហេតុចម្បងឬយ៉ាងណានោះ គឺពិតជាពិបាកកំណត់ឲ្យបានច្បាស់ណាស់ ។ ភស្តុតាងបង្ហាញថា ចំពោះជនជាតិចិននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជាតិពន្ធុគឺគ្រាន់តែជាកត្តាមួយប៉ុណ្ណោះក្នុងចំណោមកត្តាជាច្រើនទៀតដែលបានកំណត់លក្ខណៈនៃការប្រព្រឹត្តរបស់កម្ពុជាប្រជាធិបតេយ្យ ។ ជាតិនិយមហួសហេតុរបស់កម្ពុជាប្រជាធិបតេយ្យមានន័យថា ជនជាតិចិនក៏ដូចជាជនជាតិផ្សេងៗទៀតនៅកម្ពុជាដែរ គឺងាយនឹងទទួលរងនូវការធ្វើទុក្ខបុកម្នេញជាងគេ ។ ប៉ុន្តែនេះគ្រាន់តែជាការពន្យល់មួយផ្នែកអំពីការសង្កត់សង្កិន និងអារម្មណ៍ប្រឆាំងនឹងជនជាតិចិនតែប៉ុណ្ណោះ ។ ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់ថែមទៀតអំពីស្ថានភាពរបស់ជនជាតិចិន ជាការសំខាន់ណាស់គឺត្រូវយល់ថាស្ថានភាពសេដ្ឋកិច្ចរបស់ជនជាតិចិនត្រូវបានមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចាត់ទុកថាជាផលផ្លែផ្កាដែលបានមកពីការកេងប្រវ័ញ្ចជញ្ជក់ញើសឈាមគេ ។ ចាប់តាំងពីមានការគ្រប់គ្រងរបស់អាណានិគមបារាំង ការប៉ុនប៉ងរឹតត្បិតឥទ្ធិពលនៅក្នុងជំនួញរបស់ជនជាតិចិន និងការបង្កើតសកម្មភាពរបស់ខ្មែរនៅក្នុងផ្នែកនេះ ជាទូទៅតែងតែទទួលផលបញ្ច្រាសទៅវិញ ។ ការដែលជនជាតិចិនឈានចូលទៅក្នុងវិស័យជំនួញនិងរួមផ្សំជាមួយនគរូបនីយកម្មវិស័យជំនួញ មានន័យថា ជនជាតិចិនពិតជាមុខសញ្ញាយ៉ាងពិតប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យ ដែលកាន់លទ្ធិកុម្មុយនិស្តនិងប្រពៃណីនិយមក្លែងក្លាយ ។ ជនជាតិចិនគឺជានិមិត្តរូបចម្បងនៃមូលធននិយម កេងប្រវ័ញ្ច និងទីក្រុងនិយមទំនើបពុករលួយ ។ ម្យ៉ាងទៀត សំខាន់ត្រូវយល់អំពីគំនិតនយោបាយរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនិងកម្មាភិបាលរបស់ខ្លួន ។ ដូចដែលអ្នកសិក្សាស្រាវជ្រាវមុនៗបានគូសបញ្ជាក់អំពីគំនិត «យើងនិងគេ» ដែលប្រាប់ឲ្យដឹងថា ខ្សែសង្វាក់នៃការបញ្ជា មិនចាំបាច់តែមានលក្ខណៈជាប្រព័ន្ធទេ ប៉ុន្តែថា ខ្សែសង្វាក់បញ្ជាដែលបង្កើតឡើងពីអ្វីក៏ដោយ ដែលមើលទៅហាក់ដូចជាប្រឆាំងទៅនឹងក្រឹត្យក្រមរបស់ខ្លួននៅពេលណាមួយជាក់លាក់ ។ បើពិនិត្យមើលឲ្យទូលំទូលាយទៅឃើញថា ប្រការនេះត្រូវបានចាត់ទុកថាជាបញ្ហាជាតិពន្ធុនិងការបែងចែករវាងអ្នកទីក្រុងនិងជនបទ ។ ប៉ុន្តែបើពិនិត្យមើលតាមន័យចង្អៀតវិញ ឃើញថា ប្រការនេះវាអាស្រ័យទៅនឹងលក្ខណៈពិសេសនៃកាលៈទេសៈ និងបុគ្គលិកលក្ខណៈជាក់ស្តែង ។ បើច្របាច់បញ្ចូលគ្នា ឃើញថា ផ្នែកផ្សេងៗនៃជាតិពន្ធុអាចត្រូវបានបញ្ចូលគ្នាដើម្បីបង្កើតជាបរិយាកាសគាបសង្កត់មួយ ។ ប្រការនេះគឺទាក់ទងគ្នាទៅវិញទៅមកជាមួយការរកឃើញរបស់អ្នកស្រាវជ្រាវមុនៗ ។ ដូច្នេះ ដើម្បីបកស្រាយការឆ្លងកាត់របស់ជនជាតិចិននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាជាបទពិសោធន៍មួយដោយផ្អែកទៅលើជាតិពន្ធុតែមួយចំណែកនោះ គឺមិនត្រឹមត្រូវទេ ។ ផ្ទុយមកវិញ ជាតិពន្ធុអាចត្រូវចាត់ទុកថាបានជះឥទ្ធិពលប្រវត្តិសាស្ត្រទៅលើឥទ្ធិពលផ្សេងៗទៀតនៃស្ថានភាពរស់នៅជាក់ស្តែងរបស់ជនជាតិចិននៅកម្ពុជា ដែលរួមជាមួយនឹងការប្រតិបត្តិវប្បធម៌របស់ខ្លួនទៀតនោះ បានធ្វើឲ្យជនជាតិចិនកាន់តែងាយក្លាយជាមុខសញ្ញាធ្វើទុក្ខបុកម្នេញពីសំណាក់កម្ពុជាប្រជាធិបតេយ្យ ទោះបីជាកម្ពុជាប្រជាធិបតេយ្យមានទំនាក់ទំនងជាមួយរដ្ឋាភិបាលចិនក៏ដោយ ។

**ច័ន្ទ សម្បត្តិ**

## ពាក្យស្លោកខ្មែរក្រហម

◆ **ក្តាប់ជាប់និងអនុវត្តឱ្យបានល្អ ផែនការបង្កើនចំនួនប្រជាជនឱ្យបានច្រើនជាអតិបរមាក្នុង១ឆ្នាំ ៣ឆ្នាំ ៥ឆ្នាំ ១០ឆ្នាំ និង១៥ឆ្នាំ។**

(កំណត់ហេតុលេខ ០៧៦)



# ប៊ូ ម៉េង
# អ្នកទោសគុកទួលស្លែងដែលនៅមានជីវិត

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ប៊ូ ម៉េង អាយុ៦១ឆ្នាំ អតីតអ្នកទោសមន្ទីរ ស-២១ (គុកទួលស្លែង) បានធ្វើដំណើរមកកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងម្តងទៀតដើម្បីបង្ហាញដល់ប្រជាជនកម្ពុជានិងពិភពលោក អំពីការធ្វើទារុណកម្មដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហមមកលើរូបគាត់ ។ អ្វីដែលគាត់សម្រេចចិត្តមកបំភ្លឺនៅពេលនេះគឺដោយសារតែអត្ថបទមួយរបស់ទស្សនាវដ្តី«ស្វែងរកការពិត» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ២២ ខែតុលា ឆ្នាំ២០០២ ដែលបានចុះផ្សាយអំពីរូបថតរបស់គាត់ដែលបានថតរួមជាមួយអតីតអ្នកទោស៦នាក់ផ្សេងទៀត ។

ប៊ូ ម៉េង បានទទួលទស្សនាវដ្តី «ស្វែងរកការពិត» ដែលមានចុះផ្សាយអំពីរឿងរ៉ាវរបស់គាត់ តាមរយៈព្រះចៅអធិការវត្តសម្ពៅ នៅក្នុងខេត្តស្វាយរៀង ។ ម៉េង និយាយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(ស-២១)ថា «ខ្ញុំមិនទាន់ស្លាប់ទេ ។ ខ្ញុំគឺជាជនរងគ្រោះនៅទីនេះ ។ ខ្ញុំចង់ឃើញតុលាការកាត់ទោសពួកមេខ្មែរក្រហម ហើយខ្ញុំនឹងនៅធ្វើជាសាក្សី» ។

មន្ទីរ ស-២១ គឺជាមន្ទីរឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្មមនុស្សយ៉ាងសាហាវព្រៃផ្សៃ ។ មន្ទីរស-២១ ត្រូវបានបង្កើតឡើងដោយមេដឹកនាំនៃរបបខ្មែរក្រហមហើយនៅក្នុងអំឡុងពេលជាង៣ឆ្នាំនៃដំណើរប្រព្រឹត្តទៅនៃកន្លែងនេះ មានប្រជាជនស្លូតត្រង់ជាមួយម៉ឺននាក់ត្រូវបានចាប់យកមកឃុំឃាំងធ្វើទារុណកម្ម និងសម្លាប់ចោល ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ មានអ្នកទោសមួយចំនួនតូចប៉ុណ្ណោះដែលមានសំណាងរួចផុតពីការសម្លាប់រង្គាលហើយដែលនៅក្នុងនោះរួមមានទាំង ប៊ូ ម៉េង ម្នាក់ផង ។

ប៊ូ ម៉េង មានឈ្មោះដើមថា ប៊ូ ម៉ុងសៀង ។ គាត់បានប្តូរឈ្មោះថា «ម៉េង» នៅក្នុងឆ្នាំ១៩៧០ ខណៈពេលដែលគាត់ចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧០តាមរយៈជនជាតិខ្មែរដើមកំណើតវៀតណាមម្នាក់ ។ ម៉េង និងប្រពន្ធរបស់គាត់បានបម្រើការនៅក្នុងអគ្គភាពភ័ស្តុភារសេនាធិការភូមិភាគឧត្តរដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ឆុន ។ យូរៗម្តង ម៉េង បានឃើញ កុយ ធួន មកកាន់ការិយាល័យរបស់គាត់ ។

ចាប់តាំងពីឆ្នាំ១៩៧៥រហូតដល់មុនពេលត្រូវចាប់ខ្លួន ម៉េង បម្រើការនៅផ្នែកភស្តុភារសេនាធិការភូមិភាគឧត្តរដែលមានមន្ទីរតាំងនៅខាងជើងស្ពានជ្រោយចង្វារទីក្រុងភ្នំពេញ ។ អំឡុងពេលនោះ ម៉េង ធ្លាប់បានទៅគូរគំនូរអំពីគ្រឿងម៉ាស៊ីនសម្រាប់បង្រៀនដល់កម្មាភិបាលនៅសាលាបច្ចេកទេសឫស្សីកែវ ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ បូ ម៉េង និង (ម៉ា យឿន ជាប្រពន្ធរបស់គាត់) ត្រូវបានអង្គការចាប់ខ្លួនពីការដ្ឋានលត់ដែកតាឡី ដែលស្ថិតនៅប៉ែកខាងត្បូងឆៀងខាងលិចទីក្រុងភ្នំពេញបញ្ជូនមកមន្ទីរ ស-២១ ។ ប្រពន្ធរបស់ ម៉េង ត្រូវកងសន្តិសុខយកទៅដាក់នៅបន្ទប់ផ្សេងពីគាត់ ។ ម៉េង ត្រូវចាប់ខ្លួនក្នុងខណៈពេលដែលខ្មែរក្រហមកំពុងចាត់វិធានការបោសសម្អាត "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" នៅភូមិភាគឧត្តរ ហើយដែលពេលនោះ កុយ ធួន លេខាភូមិភាគឧត្តរ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវបានចាប់ខ្លួនរួចទៅហើយ ។ ម៉េង សន្និដ្ឋានថា ការចាប់ខ្លួនគាត់ដោយសារតែគាត់ជាយុទ្ធជនបម្រើការនៅក្នុងអង្គភាពភូមិភាគឧត្តរ ។

ចាប់តាំងពីចូលមកដល់មន្ទីរ ស-២១ ម៉េង ត្រូវព្រាត់ប្រាសប្រពន្ធនិងកូនប្រុសស្រីពីរនាក់របស់គាត់ជារៀងរហូត ។ ម៉េង យល់ថា ប្រពន្ធរបស់គាត់ពិតជាត្រូវកងសន្តិសុខយកទៅសម្លាប់នៅបឹងជើងឯក ហើយគាត់មិនច្បាស់ថាកូនទាំងពីររបស់គាត់បានស្លាប់ទៅហើយឬក៏នៅរស់ទេ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះគាត់មិនដែលបានទទួលដំណឹងអ្វីឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកទោសមួយចំនួនតូចដែលមានសំណាងនិងអាចរក្សាជីវិតឲ្យរួចពីការសម្លាប់រង្គាលនៅមន្ទីរ ស-២១ គឺដោយសារតែម្នាក់ៗមានវិជ្ជាជីវៈរៀងៗខ្លួន ។ បូ ម៉េង មានចំណេះផ្នែកគូរគំនូរ ។ ចាប់តាំងពីដឹងក្តីមក ម៉េង មាននិស្ស័យខាងគូររូបភាព ហើយរហូតមកទល់សព្វថ្ងៃនេះគាត់នៅតែប្រកបរបរគូររូបភាពនៅតាមវត្តអារាមជាច្រើនដើម្បីផ្គត់ផ្គង់ជីវភាព ។

ម៉េង បានឲ្យដឹងថា មនុស្សដែលបានមើលគំនូររបស់គាត់ហើយសរសើរថាគំនូររបស់គាត់មិនអន់ជាងគំនូររបស់វិចិត្រករ ញឹក ឌឹម ប៉ុន្មានឡើយ ។ គាត់បានរៀនសូត្រផ្នែកគំនូរក្រោយវិចិត្រករ ញឹក ឌឹម មួយជំនាន់ ។ ជាមួយគ្នានោះ គាត់ក៏តែងតែសង្កេតមើលគំនូររបស់វិចិត្រករបរទេសម្នាក់ ឈ្មោះ ពីកាសូដែរ ។ គាត់អាចគូររូបភាពបានគ្រប់ប្រភេទ ហើយគំនូរដែលគាត់ស្រលាញ់បំផុតគឺរូបផ្កានិងរូបស្ត្រី ។

ចាប់តាំងពីចាកចេញពីគុកទួលស្លែង ម៉េង មិនដែលគិតប៉ងត្រឡប់មកកន្លែងដ៏ជូរចត់នេះទៀតទេ ។ ខណៈពេលដែលគាត់ឈានជើងចូលទៅក្នុងបរិវេណនៃសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងជាថ្មីម្តងទៀត គាត់មានការរន្ធត់ចិត្តជាខ្លាំងនិងនឹកឃើញដល់រឿងរ៉ាវដែលបានកន្លងផុតទៅជាងម្ភៃឆ្នាំហើយនោះ ហាក់ដូចជានៅថ្មីៗ ។

ម៉េង បានរៀបរាប់អំពីវិធីដែលយុទ្ធជននៃមន្ទីរ ស-២១ សួរចម្លើយនិងធ្វើទារុណកម្មមកលើរូបគាត់ ÷ បន្ទាប់ពីថតរូបនិងធ្វើប្រវត្តិរូបសង្ខេបរួចហើយ កងការពារអ្នកទោសបានបញ្ជូន ម៉េង ទៅដាក់នៅក្នុងអគារ "គ" ជាន់ទី២ រួមជាមួយអ្នកទោសប្រមាណ៣០នាក់ផ្សេងទៀត ។ គាត់ត្រូវបាននាំយកទៅសួរចម្លើយនៅក្នុងផ្ទះល្វែងមួយដែលស្ថិតនៅខាងមុខបរិវេណនៃអគារមន្ទីរ ស-២១ អស់រយៈពេលប្រមាណពីរសប្តាហ៍ ។ អ្នកសួរចម្លើយមានគ្នាបួននាក់ ប៉ុន្តែនៅក្នុងចំណោមបួននាក់នោះ ម៉េង នៅចាំតែមនុស្សម្នាក់គត់គឺ ហ៊ី ដែលជាអនុប្រធានមន្ទីរ ស-២១ ។ អ្នកសួរចម្លើយបានសួរគាត់ថា "ឯងបានចូល សេ.អ៊ី.អា កា.ហ្សេ.បេ ជាមួយអ្នកណា? នៅឆ្នាំណា? ..." ។

ម៉េង និយាយថា គាត់មិនដឹងថា សេ.អ៊ី.អា កា.ហ្សេ.បេ ជាអ្វីទេ ហើយគាត់បានឆ្លើយតបវិញថា "ខ្ញុំមិនដឹងទេ" ។ ដោយសារតែ ម៉េង នៅតែឆ្លើយរបៀបនេះច្រើនលើកច្រើនសា អ្នកសួរចម្លើយបានទះកំផ្លៀងនិងវាយគាត់នឹងបន្ទះឫស្សីរហូតដល់បែកឈាមពេញខ្នងនិងសន្ទប់ ។ នៅពេលដែលគាត់មានរបួសយ៉ាងនេះ អ្នកសួរចម្លើយបានបញ្ជូនគាត់ទៅផ្នែកពេទ្យនៃមន្ទីរ ស-២១ ។ ពេទ្យបានព្យាបាលមុខរបួសនៅលើខ្នងរបស់គាត់ដោយទឹកអំបិល ។

ម៉េង និយាយថា "វាពិបាកនឹងរៀបរាប់អំពីសេចក្តីឈឺចាប់ដែលពួកវាធ្វើទារុណកម្មមកលើរូបខ្ញុំណាស់" ។ បន្ទាប់ពីព្យាបាលរបួសរួចហើយ ម៉េង ត្រូវសន្តិសុខនាំយកទៅសួរចម្លើយបន្ត

ទៀត ។ ម៉េង បានរៀបរាប់ថា អ្នកសួរចម្លើយនៅតែសួរគាត់នូវសំណួរដដែល ហើយគាត់នៅតែឆ្លើយចម្លើយដដែលដែរ ។ ឆ្លើយទៅនឹងសំណួរដែលថា តើអ្នកសួរចម្លើយបានធ្វើទារុណកម្មអ្វីទៀតនោះ គាត់បាននិយាយថា «នៅពេលនោះអ្នកសួរមិនចាំបាច់វាយគាត់ទេ គ្រាន់តែយកបន្ទះឫស្សីចាក់ឆ្កឹះត្រង់កន្លែងរបួសចាស់នោះ គឺគ្រប់គ្រាន់ធ្វើឲ្យគាត់ឈឺផ្សាពេកទៅហើយ» ។

ម៉េង និយាយថា សន្តិសុខតែងតែធ្វើទារុណកម្មជាច្រើនប្រភេទទៅលើអ្នកទោស ។ អ្នកទោសត្រូវបានដាក់ឃ្នាងទាំងខ្សែៗ ហើយអ្នកទោសប្រុសនិងស្រីត្រូវបានដាក់នៅក្នុងបន្ទប់ដោយឡែកពីគ្នា ។ ម៉េង ធ្លាប់បានឃើញឆ្មាំគុកម្នាក់ឡើងទន្រ្ទាំលើទ្រូងអ្នកទោសប្រុសម្នាក់ដែលនៅក្នុងបន្ទប់ជាមួយគាត់ រហូតដល់អ្នកទោសនោះស្លាប់ ។

ដោយសារតែមិនមានចម្លើយគ្រប់គ្រាន់សម្រាប់រាយការណ៍ទៅគណៈ ស-២១ អ្នកសួរចម្លើយបានសម្លុត ម៉េង ថា «អង្គការភ្នែកម្នាស់មិនដែលចាប់អ្នកណាខុសទេ ។ អ្ហែងជាជាងគំនូរ អ្ហែងច្បាស់ជាមានទាក់ទងជាមួយខ្សែ សេ.អ៊ី.អា របស់អាមេរិកាំងហើយ ។ ឥឡូវអ្ហែងឆ្លើយតាមអញប្រាប់» ។ ម៉េង មិនបានចាំថាចម្លើយសារភាពរបស់គាត់មានប៉ុន្មានទំព័រទេ ប៉ុន្តែគាត់និយាយថា ចម្លើយទាំងអស់នោះសុទ្ធតែប្រឌិតឡើងដោយអ្នកសួរចម្លើយទាំងស្រុង ។

បន្ទាប់ពីផ្អាកការសួរចម្លើយបានប្រមាណមួយខែ ឌុច បានប្រកាសរកអ្នកចេះគូរគំនូរ ដើម្បីគូររូប ប៉ុល ពត ។ ម៉េង ក៏ស្ម័គ្រចិត្ត ។ ពេលនោះ ឌុច បានសម្លុត ម៉េង ថា «បើគូររូបមិនដូចទេ នឹងយកអ្ហែងទៅវៃចោល» ។ អំឡុងពេលដែល ម៉េង ជាប់នៅក្នុងមន្ទីរ ស-២១ គាត់គូររូប ប៉ុល ពត បានចំនួនបួនផ្ទាំង ។ ដោយសារតែវិជ្ជាជីវៈនេះ ទើបធ្វើឲ្យការរស់នៅរបស់ ម៉េង បានប្រសើរជាងមុន និងគ្រាន់បើជាងអ្នកទោសដទៃទៀត ហើយគាត់បានរក្សាជីវិតរស់នៅរហូតដល់សព្វថ្ងៃនេះ ។

ដោយសារទារុណកម្មនៅមន្ទីរ ស-២១ ធ្វើឲ្យត្រចៀកម្ខាងរបស់ ម៉េង ថ្លង់រហូតមកដល់សព្វថ្ងៃ និងបន្សល់ទុកនូវស្លាកស្នាមរបួសជាច្រើនកន្លែងនៅលើខ្នងរបស់គាត់ ។

នៅក្នុងបញ្ជីឈ្មោះអ្នកទោសចំនួន២៨នាក់នៃមន្ទីរ ស-២១ ផ្ញើនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា «អ្នកទោសដែលនៅប្រើការបាន» នៅត្រង់លេខរៀងទី១២ បានសរសេរថា «ប៊ូ ម៉េង អាយុ៣៧ឆ្នាំ មកពីអគ្គភាពឧស្សាហកម្មរដ្ឋមានតួនាទីជាយុទ្ធជនសាលាបច្ចេកទេសឫស្សីកែវ ជាជាងគំនូរ ចូលឆ្នាំ១៩៧៧» ។ នៅក្នុងឯកសារដដែលនេះមានឈ្មោះអតីតអ្នកទោសនៃមន្ទីរ ស-២១ ដែលនៅរស់រានមានជីវិតនៅក្រោយឆ្នាំ១៩៧៩ ដូចជា ÷ វុយ នាគង់ ជាងឈើ, ហេង ណាត ជាងឆ្លាក់, អៀម ចាន់ ជាងឆ្លាក់, អ៊ឹង ប៉ិច ជាងជួសជុលរថយន្ត ។ ចំណែកឯ ជុំ ម៉ាញ ហៅ ម៉ី អតីតអ្នកទោសម្នាក់ទៀតដែលនៅរស់រានមានជីវិតពីមន្ទីរ ស-២១ ដែរនោះ មិនត្រូវបានកត់ត្រាចូលក្នុងបញ្ជីនេះទេ ប៉ុន្តែបានកត់ត្រានៅក្នុងបញ្ជីដោយឡែកមួយទៀតមានចំណងជើងថា «អ្នកទោសមកពីក្រសួងការពាររដ្ឋ» ។ នៅផ្នែកខាងមុខឈ្មោះ ជុំ ម៉ាញ ហៅ ម៉ី មានចំណាររបស់គណៈមន្ទីរ ស-២១ ចារថា «ទុកសិន» ។

រហូតមកដល់បច្ចុប្បន្ន នៅក្នុងចំណោមអតីតអ្នកទោសរួចជីវិតពីមន្ទីរស-២១ ទាំង៧នាក់ មានតែបីនាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនិងកំពុងទន្ទឹងរង់ចាំយុត្តិធម៌ ។

**ហ៊ុយ វណ្ណៈ**



ប៊ូ ម៉េង

# គំរូយុត្តិធម៌អន្តរជាតិមានន័យដូចម្តេច

គ្មាននិយមន័យច្បាប់ដែលមានលក្ខណៈច្បាស់លាស់ឬដែលទទួលស្គាល់ជាអន្តរជាតិទៅលើពាក្យ «គំរូយុត្តិធម៌ដែលទទួលស្គាល់ជាអន្តរជាតិ» *(Internationally Accepted Standards of Justice)* ឬ «គំរូយុត្តិធម៌អន្តរជាតិ» *(International Standards of Justice)* ទេ ។ ពាក្យទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា ទោះបីជាពាក្យទីមួយ ហាក់ដូចជាមានន័យច្រើនជាងក្នុងការនិយាយដល់គំនិតអន្តរជាតិ ចំណែកឯពាក្យទីពីរ ហាក់ដូចជាមានន័យច្រើនជាងក្នុងការនិយាយដល់ការអនុវត្តន៍ជាក់ស្តែងជាអន្តរជាតិ ។

គំនិត «គំរូយុត្តិធម៌អន្តរជាតិ» មានទាំងទិដ្ឋភាពនីតិវិធី និងទិដ្ឋភាពសារធាតុ ។ ក៏ប៉ុន្តែ ពាក្យនេះជាទូទៅហាក់ដូចជាត្រូវយកមកប្រើយោងដល់បញ្ហានីតិវិធី ។ នៅក្នុងករណីតុលាការខ្មែរក្រហមដែលនឹងចេញរូបរាងនាពេលឆាប់ៗនេះ ពាក្យថា «គំរូ» ឬ «បទដ្ឋានយុត្តិធម៌អន្តរជាតិ» តែងតែត្រូវបានពិភាក្សាទាក់ទងនឹងការមានឬមិនមានការធានាផ្នែកនីតិវិធីទាំងឡាយណា ដែលអាចធានាឲ្យមានការជម្រះក្តីប្រកបដោយយុត្តិធម៌ត្រឹមត្រូវដែលជាការពារសិទ្ធិចុងចោទនិងសាក្សី ។

ដើម្បីសម្រេចថា នីតិអន្តរជាតិអ្វីដែលត្រូវបង្កើតឡើងជាបុព្វលក្ខខណ្ឌសម្រាប់ការជម្រះក្តីប្រកបដោយយុត្តិធម៌ត្រឹមត្រូវ យើងត្រូវតែពិនិត្យមើល «ប្រភព» នីតិអន្តរជាតិនោះ ។ មានប្រភពនីតិអន្តរជាតិសំខាន់ៗចំនួនប្រាំ ពោលគឺ ទំនៀមទម្លាប់និងការអនុវត្តជាក់ស្តែងរបស់រដ្ឋ, អនុសញ្ញាដែលមិនអាចទុកជាមោឃៈបាន, សេចក្តីសម្រេច និង «ច្បាប់ទន់» «*opinio juris*» (គោលការណ៍បង្កើតឡើងដោយអ្នកច្បាប់ឧត្តម) និង គំនិតជាលក្ខណៈសិក្សាជាន់ខ្ពស់ ។ ជាលទ្ធផល (នៅពេលនិយាយដល់បទដ្ឋានយុត្តិធម៌អន្តរជាតិតាមនីតិវិធី) គេនិយាយយោងដល់គោលការណ៍ដែលបង្កើតឡើងតាមរយៈកត្តាចម្រុះទាំងប្រាំដូចខាងក្រោមនេះ ៖

◆ តើប្រព័ន្ធអនុវត្តច្បាប់ជាក់ស្តែងយ៉ាងដូចម្តេច?

◆ តើបទបញ្ញត្តិណាខ្លះនៃអនុសញ្ញាដែលភ្ជាប់កាតព្វកិច្ច?

◆ តើបញ្ញាជននិយាយយ៉ាងដូចម្តេចខ្លះ?

◆ តើតុលាការអន្តរជាតិសំខាន់ៗនិងក្នុងស្រុកដោះស្រាយបញ្ហានីតិវិធីយុត្តិធម៌តាមរបៀបដូចម្តេចខ្លះ?

◆ តើអ្វីជាលក្ខណៈពិសេសនៃនីតិវិធី ដែលសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិនិងសេចក្តីប្រកាសទាមទារឲ្យមាន?

ជាការពិតណាស់ថា ដំណើរការសម្រេចថាអ្វីជា «លក្ខណៈអន្តរជាតិ» ឬ «ទទួលស្គាល់ជាអន្តរជាតិ» តម្រូវឲ្យមានការពិភាក្សាវែកញែកជាច្រើន ព្រមទាំងមានផលប្រយោជន៍នយោបាយផង ។ ជាទូទៅ ការក្រឡេកមើលប្រព័ន្ធច្បាប់សំខាន់ៗរបស់លោកខាងលិច និងតុលាការអន្តរជាតិកន្លងមក នឹងផ្តល់នូវគំនិតដ៏ប្រពៃនៃពាក្យថា «បទដ្ឋានអន្តរជាតិ» ។ លក្ខណៈពិសេសនៃប្រព័ន្ធច្បាប់លោកខាងលិចបានក្លាយទៅជាលក្ខណៈដែលអាចទទួលយកបានតាមរយៈសន្ធិសញ្ញា សេចក្តីសម្រេចរបស់តុលាការនិងកិច្ចការជាលក្ខណៈសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលជាផ្នែកមួយនៃច្បាប់អន្តរជាតិ ។ តាមន័យនយោបាយប្រទេសដែលមានការអភិវឌ្ឍន៍ខ្ពស់ ចង់គ្របសង្កត់ទៅលើអង្គនានាដែលសម្រេចថា អ្វីទៅជា «ការប្រកបដោយយុត្តិធម៌ ហើយប្រើខ្នាតគំរូរបស់ខ្លួនមកធ្វើជារង្វាស់» ។

នៅក្នុងបរិបទប្រទេសកម្ពុជា អ្វីដែលពាក្យទាំងពីរនេះហាក់ដូចជាមានន័យនោះ (យ៉ាងហោចណាស់នៅក្នុងពាក្យប្រើក្នុងនីតិវិធី) គឺថា តុលាការមួយត្រូវមានការធានាការពារឲ្យបានគ្រប់គ្រាន់ ដើម្បីធានាថា ការជំនុំជម្រះក្តីនឹងមានលក្ខណៈយុត្តិធម៌ និងការពារដល់សិទ្ធិរបស់បុគ្គល ដូចដែលតុលាការអន្តរជាតិ ឬតុលាការបរទេសបានអនុវត្ត (ដែលមានន័យច្បាស់លាស់ថាជាវេទិកាលោកខាងលិច ឬ «ពិភពលោកទីមួយ») ។

**ចន ឆរធីអារី**



# សង្គ្រាមនៃអំពើប្រល័យពូជសាសន៍

មិនសមនឹងកើតឡើងសោះថា ខ្មែរក្រហមដែលចេះតែមានអារម្មណ៍សង្ស័យមិនចេះអស់មិនចេះហើយថាមានខ្មាំងផ្ទៃក្នុងនៅគ្រប់ទិសទី បែរជាត្រូវផ្តួលរំលំយ៉ាងងាយដោយសត្រូវដែលនៅជិតបំផុត គឺប្រទេសវៀតណាម ។ នៅសប្តាហ៍ទី១នៃខែមករា ឆ្នាំ១៩៧៩ យន្តហោះ រថក្រោះ និងកងទ័ពវៀតណាម បានបង្កើនល្បឿនសម្រុកចូលទីក្រុងភ្នំពេញ ។ នៅក្នុងខណៈដែលមានជនភៀសសឹករាប់សែននាក់រត់ចូលព្រៃនៅតាមបណ្តោយព្រំដែនថៃ វាច្បាស់ណាស់ថា រឿងរ៉ាវជីវិតគួរឲ្យរំជួលចិត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនខុសអំពីការពិតប៉ុន្មានទេ ។

ប៉ុល ពត បានប្រកាសតាមរលកធាតុអាកាសនៅអំឡុងសប្តាហ៍ទីមួយនៃខែមករាឆ្នាំ១៩៧៩ថា កងកម្លាំងរបស់ខ្លួនកំពុងតែជាប់ដៃ «ប្រយុទ្ធស្លាប់រស់» ជាមួយ «ខ្មាំងយួនឈ្លានពាន» ។ បងលេខ១និយាយថា វៀតណាមកំពុងតែធ្វើ «សង្គ្រាមនៃអំពើប្រល័យពូជសាសន៍» ហើយបានប្រៀបធៀបរបបដឹកនាំរបស់ខ្លួនទៅនឹងជនជាតិជ្វីហ្វដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស៊ីត វីអ៊ីចៈ «អ៊ីត្លែ សម្លាប់ជនជាតិជ្វីហ្វនិងអ្នកដែលប្រឆាំងនឹងខ្លួន ។ វៀតណាមសម្លាប់អ្នកណាដែលប្រឆាំងនឹងវា ព្រមទាំងប្រជាជនស្លូតត្រង់ដែលមិនចូលខាងវា» ។ នៅពេលដែលមានប្រជាជនកម្ពុជាស្លាប់ប្រហែលមួយលាននាក់ ប៉ុល ពត អះអាងថា «ប្រជាជនកម្ពុជាស្លាប់តែប្រមាណពាន់នាក់ប៉ុណ្ណោះ ដោយសារកំហុសខ្វះៗក្នុងការអនុវត្តនយោបាយរបស់យើងក្នុងការបង្កើនកម្រិតជីវភាពរស់នៅ» ។

ដូចជា អូសាម៉ា ប៊ិនឡាដិន យ៉ាងដូច្នោះដែរ ប៉ុល ពត បានលាក់ខ្លួនរហូតស្ទើរតែពីរទសវត្សរ៍ទើបលេចមុខសាជាថ្មី ។ ប៉ុល ពត ទុកការពន្យល់ដោះសារ ឲ្យ អៀង សារី និង អៀង ធីរិទ្ធ និងកូនចៅក្រោមបង្គាប់ដ៏យូរលង់ គឺ ខៀវ សំផន ជាអ្នកអនុវត្តន៍ ។ អ្នកទាំងនេះបានចេញមុខចេញមាត់ជាសាធារណៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចំណែកឯ ប៉ុល ពត វិញបានបញ្ឆោតពីក្រោយយ៉ាងរឹងប៉ឹងក្នុងលក្ខណៈក្រៅឆាក (កំបាំងមុខ) ។ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ និង អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជា-ធិបតេយ្យបានអំពាវនាវដល់អង្គការសហប្រជាតិឲ្យបញ្ឈប់ការចូលលុកលុយរបស់វៀតណាម ។ មិនយូរប៉ុន្មាន អង្គការសហ-ប្រជាជាតិក៏បានគាំទ្រដល់របបប្រល័យពូជសាសន៍ ។ ជនម៉ៅនិយមដែលធ្លាប់តែឯករាជ្យនិងមោះមុត ប្រែជាលុតក្រាបក្រោមជើងអង្គការសហប្រជាជាតិ ។

រដ្ឋការលោក ជីមី ខាទ័រ បាន «លើកលែង» ចំពោះ«ឯកសារសិទ្ធិមនុស្ស» របស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកនាំពាក្យក្រសួងការបរទេសអាមេរិក លោក ហូដឌីង ការ៉ទ័រ ទី III ជឿជាក់ថាមានគោលការណ៍មួយដែលមានបញ្ហា «*យើងពុំមានអារម្មណ៍ថាអន្តរាគមន៍ជាឯកតោភាគីពីសំណាក់ប្រទេសទីបីជាមហាអំណាចប្រឆាំងនឹងរបបនោះ ជាការសមហេតុផលឡើយ*» ។

ប្រហែលជាការគួរឲ្យភ្ញាក់ផ្អើលនោះគឺនៅថ្ងៃទី៧ ខែមករា ទីភ្នាក់ងារពត៌មាននៃរដ្ឋាភិបាលចិន ស៊ិនហួរ ប្រកាសថា សម្តេច សីហនុ កំពុងស្ថិតក្នុងទីក្រុងប៉េកាំង ក្នុងដំណើរឆ្ពោះទៅទីក្រុងញូវយ៉ក ដើម្បីថ្លែងទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិក្នុងឋានៈជាតំណាងឲ្យខ្មែរក្រហម ។ អមដំណើរដោយ ជួន ប្រាសិទ្ធិ តំណាងកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិ សម្តេច សីហនុ មានព្រះទ័យជ្រួលច្រាល ហើយទ្រង់បានផ្តល់នូវសារមានលក្ខណៈចម្រុះ ។ ជាថ្មីម្តងទៀត ចិននិងខ្មែរក្រហមកំពុងតែប៉ុនប៉ងប្រើប្រាស់ព្រះមហាក្សត្រដើម្បីជះឥទ្ធិពលទៅលើទស្សនៈមហាជនអន្តរជាតិ ។ ក៏ប៉ុន្តែក្រោយពីស្ថិតនៅក្នុងឃុំ តែក្នុងដំណាក់អស់រយៈពេលបីឆ្នាំ មិនច្បាស់ថាតើ សម្តេច សីហនុ នឹងសហការជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យដល់កម្រិតណាឡើយ ។

នៅពេលដែលសម្តេច សីហនុ លេចមុខនៅទីក្រុងប៉េកាំង

មានខន្តីរភាពថ្មីមួយចំពោះព្រះមហាក្សត្រដែលធ្លាប់តែរួសរាយ និងមានមនោសញ្ចេតនាជ្រាលជ្រៅ ។ ស្ថិតក្នុងសម្លៀកបំពាក់របៀបចិន សម្តេច សីហនុ បានធ្វើសន្និសីទកាសែតអស់រយៈពេល៦ម៉ោង នៅសាលប្រជុំមហាជននៅទីក្រុងប៉េកាំង ។ ដូចជាប្រជាជនកម្ពុជារាប់លាននាក់ទៀតដែរ សម្តេច សីហនុ ផ្តល់ចម្លើយខ្លីៗថា «ខ្ញុំមិនដឹងថាគេនៅទីណា មិនដឹងថាស្លាប់ឬរស់ ឬក៏ស្ថិតនៅក្រោមវៀតណាមយ៉ាងណានោះទេ» ។ សម្តេច សីហនុ ហាក់ទាល់ព្រះទ័យជាមួយនឹងការដឹកនាំដែលមានរយៈពេល៨ឆ្នាំមុន ដោយមានព្រះបន្ទូលថា «ខ្ញុំមិនដឹងហេតុអ្វីបានជាគេសម្រេចចិត្តដាក់នយោបាយរបៀបនេះចំពោះប្រជាជនទេ ប៉ុន្តែគេបានប្រាប់ខ្ញុំថា វាគឺជាលទ្ធិកុម្មុយនិស្តពិតៗ» ។ ជាពិសេសទៅទៀត សម្តេច សីហនុ មានទឹកព្រះទ័យព្រួយបារម្ភចំពោះ «ការស្លាប់ផុតពូជ» នៃប្រជាជាតិរបស់ព្រះអង្គ ហើយជឿជាក់ថា វៀតណាម កំពុងតែលេបទឹកដីកម្ពុជា ។

ជំហរជាផ្លូវការរបស់សហរដ្ឋអាមេរិកពិបាកនឹងបកស្រាយណាស់ ដោយសារការបញ្ចេញពាក្យតាមរយៈគំនិតដែលមានភាពផ្ទុយគ្នាពីសំណាក់ទីក្រុងវ៉ាស៊ីនតោនពេញអំឡុងឆ្នាំ១៩៧៩ ។ នៅក្នុងខណៈដែលក្រសួងការបរទេសសហរដ្ឋអាមេរិកតវ៉ាចំពោះការចូលលុកលុយរបស់វៀតណាម សហរដ្ឋអាមេរិកក៏ជំទាស់នឹងការរំលោភសិទ្ធិមនុស្សរបស់កម្ពុជាប្រជាធិបតេយ្យដែរ ។ ជាថ្មីម្តងទៀត កម្ពុជាកំពុងតែក្លាយជាសមរភូមិវិវាទនៃនយោបាយពិភពលោក ។

នៅពេលថ្លែងទៅកាន់មហាសន្និបាតនៅថ្ងៃទី១០ ខែមករា សម្តេច សីហនុ បានពន្យល់ថា ការរស់ឡើងវិញរបស់ជាតិមានអាទិភាពជាងការទាស់គំនិតគ្នារវាងព្រះអង្គជាមួយនឹងមេដឹកនាំខ្មែរក្រហម «មិនមែនជាបញ្ហានៃការខ្វែងគំនិតគ្នាខាងនយោបាយឬសិទ្ធិមនុស្សទៀតហើយ ប៉ុន្តែជាបញ្ហាថាតើប្រទេសកម្ពុជានឹងត្រូវបាត់ស្រមោលពីផែនទីពិភពលោក ហើយក្លាយទៅជាអាណាខេត្តរបស់ចក្រពត្តិវៀតណាម និងសូវៀត ដែលជាចៅហ្វាយនាយរបស់វៀតណាម ឬយ៉ាងណា» ។ នៅថ្ងៃបន្ទាប់ ការប៉ះទង្គិចគ្នារវាងសូវៀតនិងតំណាងចិនប្រចាំនៅអង្គការសហប្រជាជាតិ ត្រូវបានសារពត៌មានញូវយ៉កថែម ពិពណ៌នាថា «ជាការប៉ះទង្គិចខាងការទូតខ្លាំងក្លាជាងពេលណាៗទាំងអស់ដែលខ្លួនមិនដែលជួបប្រទះនៅក្នុងវេទិកាសាធារណៈអន្តរជាតិ ចាប់តាំងពីការផ្តាច់ទំនាក់ទំនងរវាងគ្នានឹងគ្នាអស់ជាងពីរទសវត្សរ៍កន្លងទៅ» ។ លើកនេះទៀត ជម្លោះអំពីបញ្ហាកម្ពុជាមានទាក់ទងតិចតួចប៉ុណ្ណោះដល់ការឈឺចាប់ដែលប្រជាជនកម្ពុជាកំពុងទទួលរង ។ ប្រជាជាតិអាស៊ីនិងអាហ្វ្រិកបានចូលរួមខាងចិន ហើយចោទវៀតណាមថាជាអ្នកឈ្លានពាន សូម្បីតែសារពត៌មានញូវយ៉កថែម ក៏ចូលរួមបន្ទរថ្កោលទោសដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដែរ «ការវាយលុករបស់ទីក្រុងហាណូយទទួលបានលទ្ធផលមិនមែនដោយសារការអស់ភក្តីភាពពីប្រជាជននៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែដោយសារវៀតណាមមានទ័ពខ្លាំងជាង» ។ ចំណែកឯអង្គការសារពត៌មានសូវៀត «ប្រាវដា» និយាយជិតត្រឹមត្រូវហើយដែលថា «នៅក្នុងប្រទេសមួយដែលត្រូវបានប្រែក្លាយទៅជាជំរំប្រមូលផ្តុំ ដែលនៅទីនោះមានការចូលរួមយ៉ាងសកម្មពីទីក្រុងប៉េកាំងនូវការនាំចេញនូវបដិវត្តន៍វប្បធម៌នោះ ប្រជាជនដែលមានសិទ្ធិចេញចូលដោយសេរីមានតែទីប្រឹក្សាចិនប៉ុណ្ណោះដែលមានចំនួនរាប់ពាន់នាក់» ។

ប្រហែលជានៅពេលជំណាលគ្នានេះដែរ មេដឹកនាំខ្មែរក្រហម អៀង សារី ស្ថិតក្នុងខទ្ទម្ពាគចក្រយោធាថៃ ហោះហើរចេញពីប៉ោយប៉ែតឆ្ពោះទៅទីក្រុងបាងកក ។ នៅពេលដល់ទីក្រុងបាងកក អៀង សារី ជិះយន្តហោះរបស់ក្រុមហ៊ុនទេសចរណ៍ថៃឆ្ពោះទៅក្រុងហុងកុង ។ អ្នកដែលរង់ចាំ អៀង សារី នៅកាប៊ីនថ្នាក់លេខមួយគឺ ហេនរី កាំ មកពីកាសែតញូវយ៉កថែម ។ នៅដំណាក់កាលដំបូងនេះ ពោលគឺប៉ុន្មានម៉ោងក្រោយពីរបបខ្លួនត្រូវបានផ្តួលរំលំ អៀង សារី សារភាពថា «នៅប៉ុន្មានថ្ងៃដំបូងពិតជាមានការសម្លាប់មនុស្សច្រើនមែន» ។ នៅពេលដែល អៀង សារី ប្រាប់ទៅ ហេនរី កាំ ថា «យើងសូមវាយតម្លៃខ្ពស់ចំពោះជំហររបស់ប្រធានាធិបតី កាទ័រ និងគោលការណ៍របស់លោក» ពេលនោះអ្នករាយការណ៍រូបនោះបានសរសេរថា វាធ្វើឲ្យគាត់មានអារម្មណ៍ «ចង់ក្អួតរឹកៗ» ហើយនិយាយថា ខ្មែរក្រហមប្តូរទិស១៨០អង្សា ។ ខ្មែរក្រហមកំពុងតែប៉ុនប៉ងប្រែក្លាយខ្លួនទៅជាអ្នកគាំទ្រមនោគមវិជ្ជាសង្គ្រាមត្រជាក់ ។ អ្នកសារពត៌មាន

ដើងចាស់រូបនោះនិយាយថា "នៅពេលឮថាមេដឹកនាំខ្មែរក្រហមមានចរិតលុតក្រាបខ្សែបខ្សបចំពោះអាកប្បកិរិយានិងគោលការណ៍របស់ប្រធានាធិបតីសហរដ្ឋអាមេរិក កាទ័រ យ៉ាងដូច្នេះ ជាការគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលនេះគឺជាការផ្ទុយទៅនឹងអ្វីដែលខ្ញុំធ្លាប់ដឹងធ្លាប់ឮពីមុនមក" ។ អៀង សារី បានប្រាប់ទៅ ហេនរីកាំ ថា ខ្លួនមានបេសកកម្ម "យ៉ាងលំបាកលំបិនណាស់" នៅទីក្រុងប៉េកាំង ។

អៀង សារី ហៀបតែនឹងត្រូវបានស្តីបន្ទោសដោយចិនដែលជាអ្នកប្រៀនប្រដៅខ្លួនទៅហើយ ៗ វាសនាស្លាប់រស់គឺស្ថិតនៅលើលទ្ធផលនៃកិច្ចប្រជុំនេះ ។ នៅពេល អៀង សារី មកដល់ទីក្រុងប៉េកាំង មេដឹកនាំចិន តេង ស៊ាវពីង បានស្តីបន្ទោសថា "ទស្សនៈមតិពិភពលោកបានកត់សម្គាល់ទៅលើទិដ្ឋភាពនៃវិសុទ្ធកម្មដែលមានលក្ខណៈលើសលស់បន្តិចហើយ មានទំហំធំធេងពេកទៀតផង ។ខ្ញុំប្រាកដក្នុងចិត្តថា ពត៌មាននេះ ក៏បានឮទៅដល់សមមិត្តដែរ ។ ខ្ញុំលើកយកបញ្ហានេះមកនិយាយ គឺដើម្បីការតស៊ូទៅថ្ងៃមុខទៀត" ។ មេដឹកនាំរូបនោះបន្តលើកឡើងនូវយុទ្ធសាស្ត្រដើម្បីខ្មែរក្រហមរស់តទៅមុខ ដែលនឹងយកមកប្រើប្រាស់ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់សម្រាប់ពីរទសវត្សរ៍ទៀត ។ មេដឹកនាំខ្មែរក្រហមទាំងឡាយសារភាពទាំងស្រពេចស្រពិលមិនច្បាស់លាស់ថា ខ្លួនពិតជាមាន "កំហុស" ដែលធ្វើឲ្យមានប្រជាជនស្លាប់មួយចំនួន ប៉ុន្តែស្តីបន្ទោសថា វៀតណាមជាអ្នកធ្វើឲ្យប្រជាជនកម្ពុជាស្លាប់រាប់លាននាក់ ។ តេង ស៊ាវពីង ព្រមានថាជំនួយរបស់ចិននឹងបន្តទៅទៀត លុះត្រាណាតែខ្មែរក្រហមស្រុះស្រួលរួបរួមជាមួយនឹងសម្តេច សីហនុ វិញ ហើយបានកត់សម្គាល់ទៅលើសុន្ទរកថាថ្លែងទៅកាន់អង្គការសហប្រជាជាតិរបស់សម្តេចថា "សុន្ទរកថារបស់សម្តេច សីហនុ នៅឯអង្គការសហប្រជាជាតិ គឺល្អ និងមានមូលដ្ឋានត្រឹមត្រូវ" ។ ទោះបីជាចិនផ្តល់អំណោយខាងផ្នែកថវិកានិងស្ថានីយ៍ផ្សាយវិទ្យុដល់ខ្មែរក្រហមទៅតាមសំណើក្តី ប៉ុន្តែចិនបានព្រមានថា ការផ្សាយរបស់ខ្មែរក្រហមនឹងស្ថិតក្រោមការត្រួតពិនិត្យយ៉ាងជិតដល់របស់ចិន ។ មេដឹកនាំចិនរូបនេះក៏បានប្រាប់ទៅ អៀង សារី ក្នុងលក្ខណៈមិនជាក់លាក់ថា កុំសូវបញ្ចេញវោហាសាស្ត្រដែលមិនសមហេតុផលច្រើនពេក ។ "ការផ្សាយរបស់សមមិត្ត នឹងត្រូវគេសើចចំអកនៅពេលមិនមានការពិត ។ ចំពោះឥឡូវនេះវិញ កុំនិយាយច្រើនពេកអំពីបក្សកុម្មុយនិស្ត ។ ចូរនិយាយអំពីស្នេហាជាតិ ជាតិនិយម និងប្រជាធិបតេយ្យ" ។

ក្រោយពីមានស្ថានីយ៍វិទ្យុនៅទីក្រុងប៉េកាំង និងការផ្តល់ជំនួយចិនសាជាថ្មី អៀង សារី បានរៀបចំអនុវត្តផែនការរបស់ចិន ។ អៀង សារី ប្រកាសនៅខែខសភាថា មេដឹកនាំជាន់ខ្ពស់ ប៉ុល ពត នឹងយល់ព្រមរួមគ្នាប្រឆាំងនឹងវៀតណាមដោយមានគោលដៅបង្ខំឲ្យវៀតណាមដកថយពីប្រទេសកម្ពុជា ។ ការរួមគ្នានេះអាចធ្វើឲ្យចិន ថៃ និងសហរដ្ឋអាមេរិក បំពាក់អាវុធដល់ខ្មែរក្រហម ហើយចាប់ផ្តើមប្រឹងប្រែងធ្វើការផ្សារដើម្បីកែខែមុខមាត់ឲ្យល្អឡើងវិញ ។ ដូចជា ប៉ុល ពត និង ខៀវ សំផន ដែរ អៀង សារី បានសារភាពថា "មានមនុស្សរាប់ពាន់នាក់" ត្រូវបានសម្លាប់នៅក្នុងរបបដឹកនាំរបស់ខ្លួន ប៉ុន្តែ អៀង សារី បានបន្ថែមថា វៀតណាមកំពុងតែអនុវត្ត "អំពើបំបាត់ពូជសាសន៍និងប្រជាជាតិយើង" ។ តាមសម្តីរបស់ អៀង សារី វៀតណាមបានសម្លាប់ប្រជាជនកម្ពុជាច្រើនជាងជនជាតិបារាំងនិងអាមេរិកាំងទៀតផង ។ "ពួកអាណានិគមសម្លាប់រង្គាលប្រជាជនយើងតិចជាង ចំណែកឯចក្រពត្តិអាមេរិកដែលទម្លាក់គ្រាប់បែកនោះ ក៏មិនបានសម្លាប់រង្គាលដល់ថ្នាក់នេះដែរ" ។

ពេលវេលានៃការបញ្ចេញការពិតចំពោះសហរដ្ឋអាមេរិកកើតឡើងនៅខែកញ្ញាឆ្នាំ១៩៧៩ គឺនៅពេលដែលការបោះឆ្នោតជ្រើសរើសរបបថ្មីដែលតំណាងឲ្យប្រទេសកម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ ចូលមកដល់ ។ តើជារបប ហេង សំរិន ដែលលើកបន្ទុបដោយវៀតណាម ឬក៏របបប្រល័យពូជសាសន៍ខ្មែរក្រហម? តើរបបមួយណាដែលសហរដ្ឋអាមេរិកគាំទ្រ? នៅពេលបោះឆ្នោត មានប្រាំមួយសំឡេង (រួមទាំងសហរដ្ឋអាមេរិក) ទល់នឹងបីសំឡេង ។ គណៈកម្មាធិការសារតាំងនៃអង្គការសហប្រជាជាតិបានអនុញ្ញាតឲ្យរបបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយ ប៉ុល ពត រក្សាអាសនៈកម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ (ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៩ មហាសន្និបាតអង្គការសហប្រជាជាតិទទួលយកនូវ

របាយការណ៍ពីគណៈកម្មាធិការសារតាំង ដោយសំឡេងឆ្នោត ៧១គាំទ្រ ៣៥ប្រឆាំង និង ៨អនុបវាទ) ។ ទោះបីជារបបដឹកនាំរបស់លោក កាទ័រ បានប្រកាសយ៉ាងឧឡារិកថា ខ្មែរក្រហមគឺជា "អ្នករំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុតនៅក្នុងពិភពលោក" យ៉ាងណាក៏ដោយ ក៏តំណាងរបស់លោកប្រចាំនៅអង្គការសហប្រជាជាតិ ស៊ីរ៉ឺស វ៉ែន បានបោះឆ្នោតគាំទ្ររបបដែលត្រូវបានផ្តួលរំលំ ឲ្យរក្សាអាសនៈប្រចាំនៅមហាសន្និបាតអង្គការសហប្រជាជាតិដដែល ។ ក្រោយអំពីមានការសម្រេចចិត្តរួច ហើយមន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកបានប្រាប់ទៅអ្នកកាសែតម្នាក់ឈ្មោះ ណាយ៉ាន់ ចាន់ដា ថា "ជម្រើសរបស់យើងគឺរវាងគោលការណ៍សីលធម៌និងច្បាប់អន្តរជាតិ ។ ទម្ងន់បានទោរទៅខាងច្បាប់ ព្រោះថាវាបម្រើដល់ផលប្រយោជន៍សន្តិសុខ" ។ សហរដ្ឋអាមេរិក និងប្រជាជាតិអាស៊ី-អាគ្នេយ៍ ដូចជា សិង្ហបូរី ថៃ ម៉ាឡេស៊ី ហ្វីលីពីន និងឥណ្ឌូនេស៊ី កំពុងតែរីករាយជាមួយនឹងទស្សនីយភាពនៃការផ្តន្ទាទោសដែលវៀតណាមគួរតែទទួលរង ។ សហរដ្ឋអាមេរិក ប្រទេសចិន និងថៃ កំពុងតែរៀបចំបណ្តាញគាំទ្រជាសម្ងាត់របស់ខ្លួនដល់ខ្មែរក្រហម ដែលបណ្តាញនេះនឹងធ្វើឲ្យខ្មែរក្រហមរស់រហូត និងអាចកសាងកម្លាំងសាជាថ្មីពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។

ទន្ទឹមពេលនោះដែរ នៅប្រទេសកម្ពុជា ភាពដែលអាចជឿជាក់បាននៃតុលាការខុក្រិដ្ឋសង្គ្រាម បានជួបប្រទះឧបសគ្គនៅខែសីហា ឆ្នាំ១៩៧៩ ។ រដ្ឋាភិបាល ហេង សំរិន ក៏បានបង្កើតនូវ "តុលាការប្រជាជនបដិវត្ត" ដើម្បីវិនិច្ឆ័យទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខអំពីបទប្រល័យពូជសាសន៍ ។ មានអ្នកសង្កេតការណ៍៥០០នាក់បានចូលរួមយ៉ាងច្រើនកកកុញនៅសាលចតុមុខក្នុងទីក្រុងភ្នំពេញ ដើម្បីស្តាប់សាក្សីឡើងស្រាយបំភ្លឺចំពោះមុខតុលាការ ។ អ្នកច្បាប់និងអ្នកកាសែតបរទេសមួយចំនួនដែលមានលិខិតអនុញ្ញាត រួមទាំងវៀតណាមផង ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសវនាការជំនុំជម្រះដែលធ្វើឡើងតែមួយរយៈពេលខ្លីនេះ ។ តុលាការដែលមានសមាសភាពតែ១០នាក់ដែលហៅថា "ក្រុមប្រឹក្សាប្រជាជន" មានភាពលាយចម្រុះគ្នាគួរឲ្យចម្លែក ពោលគឺមាន មេធាវី គ្រូបង្រៀន កម្មកររោងចក្រ អគ្គិសនី និងមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗទៀត ។ ប្រធានតុលាការគឺជារដ្ឋមន្ត្រីថ្មីនៃក្រសួងពត៌មាន គឺសមមិត្ត កែវ ចិន្តា ។ រដ្ឋអាជ្ញារស់ សម័យ បានថ្លែងបើកអង្គជំនុំជម្រះថា "មិនអាចកត់ត្រាដោយពេញលេញបានទេ នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រព្រឹត្តដោយបន ប៉ុល ពត, អៀង សារី ដែលជារបបយង់ឃ្នងដើរតាមពួកប្រតិកិរិយាប៉េកាំង ដែលជាការធ្វើឲ្យខូចដល់អរិយធម៌អង្គរដ៏បវរ និងធ្វើឲ្យប៉ះពាល់ដល់មនសិការ មនុស្សជាតិដែលកំពុងតែលូតលាស់" ។

នៅពេលដាក់កំហុសរួចហើយ តុលាការបានបើកសវនាការស្តាប់នូវកសិណសាក្សីដែលថ្លែងពីដំណើររឿងសោកនាដកម្ម ។ ម្នាក់ក្នុងចំណោមអ្នកដែលរស់រានមានជីវិតពីមន្ទីរស-២១ ជាអតីតវិស្វករសំណង់ ឈ្មោះ អ៊ឹង ប៉ិច បាននិយាយថា "បើកុំតែគាត់ចេះជួសជុលម៉ាស៊ីន ម្ល៉េះសមគាត់ស្លាប់បាត់ទៅហើយ ។ "ប្រធានគុកឈ្មោះ ហ៊ី ប្រាប់ខ្ញុំថា ខ្ញុំនឹងត្រូវគេយកទៅសម្លាប់ចោល ប្រសិនបើមិនចេះជួសជុលម៉ាស៊ីនទេនោះ" ។ ក្រោយពីដេកមិនលក់អស់រយៈពេលពីរយប់ជាប់ៗគ្នាមក ប៉ិច ក៏ជួសជុលម៉ាស៊ីនភ្លើងដាក់នៅក្នុងគុកនោះបានសម្រេច ហើយប្រធានគុកក៏ទុកជីវិតឲ្យគាត់រហូតមក ។ ដោយសារធ្លាប់បានទទួលទារុណកម្មអស់រយៈពេល៥ថ្ងៃជាប់ៗគ្នានៅមន្ទីរស-២១ ជាងចម្លាក់ឈ្មោះ អៀម ចាន់ បានឡើងមកធ្វើជាកសិណសាក្សីឲ្យតុលាការដោយអះអាងថា ខ្មែរក្រហមធ្វើឲ្យគាត់ហៀបតែសារភាពអ្វីៗគ្រប់យ៉ាង ។ ជនជាតិចាមនិយាយថា ខ្មែរក្រហមបង្ខំឲ្យខ្លួនហូបសាច់ជ្រូក ចំណែកឯព្រះសង្ឃវិញមានសង្ឃដីកាអំពីការបំផ្លាញព្រះវិហារនិងដុតសៀវភៅធម៌របស់ព្រះអង្គ ។

វ៉ាង ភាព ឆ្មាំគុក ស-២១ ដែលត្រូវចាប់ខ្លួន បានរៀបរាប់អំពីអ្នកទោសដែលត្រូវយកទៅសម្លាប់ចោល "ក្រោយពីសួរចម្លើយរួចហើយ អ្នកទោសទាំងអស់ ទោះជាឆ្លើយឬមិនឆ្លើយ ត្រូវតែសម្លាប់នៅជិតគុក ឬក្នុងវាលស្រែនៅភូមិព្រៃស ខណ្ឌដង្កោ ខេត្តកណ្តាល" ។ វ៉ាង ភាព បានរៀបរាប់យ៉ាងពិស្តារ និងសុក្រឹតអំពីការយកមនុស្សទៅសម្លាប់ថា "មុននឹងយកទៅសម្លាប់

គេឲ្យអ្នកទោសជីករណ្តៅជាមុន.... គេបញ្ជាឲ្យយើងទៅយកអ្នកទោសម្តងម្នាក់ៗដាក់នៅគែមរណ្តៅ រួចហើយគេវ៉ៃចំកញ្ចឹងកឬចំក្បាល រួចទម្លាក់ចូលទៅក្នុងរណ្តៅតែម្តងៗ រណ្តៅនោះមានបណ្តោយជិតមួយម៉ែត្រៗ»

ចុងបញ្ចប់ ពីរថ្ងៃក្រោយពីការឡើងបំភ្លឺពីសំណាក់សាក្សីដាក់បន្តុករួចមក តុលាការក៏បានតែងតាំងមេធាវីការពារក្តីឲ្យ ប៉ុល ពត និង អៀង សារី ជាជនជាតិអាមេរិកាំងឈ្មោះ អ្នកស្រី ហូប ស្ទីវិន។ អ្នកស្រីក៏បានអានចំណាប់អារម្មណ៍ដំបូង ហើយផ្តល់នូវវិធីការពារក្តីដ៏តិចតួចបំផុត។ ជាការពិបាកក្នុងការកំណត់ថា ការរិះគន់ដោយចំហរបស់គាត់ប្រឆាំងនឹងចិននិងអាមេរិក ជាអ្វីដែលនិយាយដដែលៗ។ គាត់បាននិយាយថាៈ «ខ្ញុំមិនមែនមកពីពាក់កណ្តាលពិភពលោកដើម្បីផ្តល់នូវការយល់ស្របចំពោះឧក្រិដ្ឋកម្មដ៏សែនអាក្រក់ ឬសុំក្តីមេត្តាឲ្យឧក្រិដ្ឋជនទេ ។ គ្មានទេ ។ ពិតជាទោរាប់ពាន់ដង ៗ» ស្ទីវិន ហៅកូនក្តីរបស់ខ្លួនថាជា «បិសាចដ៏ឆ្កួតលីលា» ដែលបាន «អនុវត្តកម្មវិធីមួយដែលបានបង្កើតឡើងដោយអ្នកផ្សេង» ។ មេធាវីការពារក្តីរូបនោះចង់ធ្វើវិសោធនកម្មលើដីកាបណ្តោះអាសន្ន ដើម្បីបញ្ចូលបន្ថែមមិនត្រឹមតែ ប៉ុល ពត និង អៀង សារី ទេ ប៉ុន្តែថែមទាំង «អ្នកសម្របសម្រួលនៃចក្រពត្តិនិយម អ្នកឆ្លៀតយកកម្រៃពីអាណានិគមបែបថ្មី មេគំនិតហ្វាស៊ីស ពួកអនុត្តរភាពដែលគាំទ្រចលនាហ្ស៊ីយូនីសនិយម (កសាងនិងអភិវឌ្ឍន៍ប្រជាជាតិជ្វីហ្វសាឡើងវិញ), សាសន៍និយម, ការរើសអើង និងរបបប្រតិកិរិយាទូទាំងពិភពលោក ។ អ្នកទាំងអស់នេះនឹងឈរនៅទីនោះជាមួយនឹងមេដឹកនាំសង្គមនិយមនៃប្រទេសចិនដែលកាន់របបហ្វាស៊ីស រង់ចាំតែសាលក្រមនិងទទួលការវិនិច្ឆ័យទោសរួមគ្នាទៅតាមសេចក្តីសម្រេចរបស់តុលាការ» ។

តុលាការនេះបានរកឃើញកំហុសរបស់ ប៉ុល ពត និង អៀង សារី ថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ រួចហើយកាត់ទោសប្រហារជីវិតកំបាំងមុខនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ១៩៧៩ ។ ទោះបីជាតុលាការបានបង្ហាញនូវភ័ស្តុតាងធម្មានរូបដូចជាកសិណសាក្សី អ៊ីង ប៊ុច និង អៀម ចាន់ ដែលនៅរស់រួចផុតពីការសម្លាប់នៅមន្ទីរស-២១ក៏ដោយ ក៏ដំណើរការជំនុំជម្រះក្តីនេះមិនខុសគ្នាប៉ុន្មានពីការជំនុំជម្រះក្តីនៅប្រទេសរុស្ស៊ីដែលកាន់លទ្ធិស្តាលីននិយមនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៣០ ឡើយ ។ សាលក្រមដាក់កំហុសខុសជំពូកបទល្មើស ការជំនុំជម្រះក្តីក្នុងរយៈពេលខ្លី ការការពារក្តីមិនសមហេតុសមផល កត្តាទាំងអស់នេះរួមបញ្ចូលគ្នាបង្កើតបានជាការស្តែងឲ្យឃើញនូវយុត្តិធម៌នយោបាយបែបបុរាណមួយ ។ ប្រតិកម្មពីលោកខាងលិច ចំពោះសាលដីការបស់តុលាការប្រជាជនបដិវត្តសឹងតែគ្មាន ហើយត្រូវបានចុះផ្សាយជាពត៌មានដ៏ខ្លីនៅលើទំព័រក្រោយនៃកាសែតញូវយ៉កថែមប៉ុណ្ណោះ ។

ទោះបីជាត្រូវបានកាត់ទោសប្រហារជីវិតកំបាំងមុខនៅខែសីហា ឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តនៅទីក្រុងភ្នំពេញក៏ដោយ ក៏ អៀង សារី រដ្ឋមន្ត្រីការបរទេសកម្ពុជាប្រជាធិបតេយ្យ នៅតែធ្វើជាតំណាងកម្ពុជាតែមួយគត់នៅអង្គការសហប្រជាជាតិ ។ នៅពេលត្រូវចោទសួរអំពីសាលក្រមសម្រេចទោស អៀង សារី សើចហើយនិយាយថា «ខ្ញុំបានអានសាលក្រមនៅឯអង្គការសហប្រជាជាតិ ដូចជាអ្នកការទូតដទៃទៀតដែរ ។ គេនិយាយថា វាជារឿងកំប្លែងដែលមិនគួរឲ្យចង់មើលសោះ» ។ អៀង សារី និយាយថា «មេដឹកនាំខ្មែរក្រហមមិនបានដឹងអំពីការរស់នៅរបស់ប្រជាជននៅតាមមូលដ្ឋានឡើយ ដែលនេះហើយបានជាមានមនុស្សឃាតកើតឡើង ។ ចំពោះបញ្ហានេះយើងដែលជាអ្នកដឹកនាំត្រូវតែមានការទទួលខុសត្រូវ» ។

អ្នកដែលនៅចចេសគាំទ្រខ្មែរក្រហមនៅលោកខាងលិច បានប្រមូលផ្តុំគ្នានៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ នៅចុងឆ្នាំ១៩៧៩ ដើម្បីប្រកាសជាឧឡារិកថា វៀតណាមធ្វើ«សង្គ្រាមឈ្លានពានមកលើកម្ពុជាប្រជាធិបតេយ្យ» ហើយទាមទារឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា ។ ម៉ារីតា វីកកាន់ឌ័រ ប្រធានសមាគមមិត្តភាពស៊ុីស-កម្ពុជា បានបើកសន្និសីទមួយដោយអាននូវសារមកពី ខៀវ សំផន ប្រមុខកម្ពុជាប្រជា-ធិបតេយ្យ ។ ខៀវ សំផន ចោទប្រកាន់ថា វៀតណាមធ្វើ

*"សង្គ្រាមប្រល័យពូជសាសន៍ផុតពូជ"* ហើយអះអាងថា នៅក្នុងរយៈពេល១១ខែចាប់តាំងពីការចូលលុកលុយ វៀតណាមបានសម្លាប់ប្រជាជនកម្ពុជាអស់មួយលាននាក់ ។ ខ្មែរក្រហមចង់បង្វែរកំហុសបំផ្លិចបំផ្លាញកម្ពុជាទម្លាក់ទៅលើវៀតណាមវិញ ។ ខៀវ សំផន ភូតភរដោយឥតអៀនខ្មាសថា *"នៅក្នុងអំឡុងពេល១១ខែនៃការលុកលុយនេះ មានប្រជាជនជាង៥សែននាក់ត្រូវបានសម្លាប់រង្គាល ហើយជាង៥សែននាក់ទៀតស្លាប់ដោយអត់អាហារ..."* ។

ចំណុចចាប់អារម្មណ៍នៃសន្និសីទនេះលេចរូបរាងឡើងនៅពេលដែល អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់ អៀង សារី និងជាប្អូនថ្លៃរបស់ ប៉ុល ពត បញ្ចេញវោហារទៅកាន់ក្រុមមនុស្សកាន់តែធ្ងន់ថា *"សូម្បីតែយាយៗដែលមានអាយុ៧០ទៅ៨០ឆ្នាំក៏វាមិនទុកជីវិតឲ្យដែរ ។ ចំពោះក្មេងៗវិញ គឺត្រូវសម្លាប់ចោលទៅតាមវិធីពិសេសរបស់វា ។ កូនក្មេងទើបនឹងកើតនៅក្នុងអង្រឹងពួកវាហែកជើងឲ្យដាច់ជាពីរឬចាក់នឹងចំពុះទុង ។ ចំណែកក្មេងជំទង់ៗត្រូវយកទៅបោកនឹងគល់ឈើ"* ។ ក្នុងចំណោមមេដឹកនាំខ្មែរក្រហម អៀង ធីរិទ្ធ និយាយចេញមកគួរឲ្យខ្មាសអៀនជាងគេ ។ ដូច ប៉ុល ពត, ខៀវ សំផន និង អៀង សារី ដែលជាប្តីដែរ អៀង ធីរិទ្ធ បានចោទវៀតណាមពីបទប្រល័យពូជសាសន៍ *"សង្គ្រាមប្រល័យពូជសាសន៍នេះធ្វើឡើងក្នុងគោលបំណងសម្លាប់បំផុតពូជប្រជាជាតិនិងជាតិកម្ពុជាទាំងមូលតាមរយៈការសម្លាប់រង្គាលនិងទុរភិក្ស ហើយធ្វើឲ្យកម្ពុជាក្លាយទៅជាផ្នែកដីសំខាន់មួយរបស់វៀតណាម ។ នេះគឺជាសង្គ្រាមដ៏សាហាវឃោរឃៅបំផុតដែលមិនដែលមាននៅក្នុងសតវត្សរ៍ទី២០ដែលយើងបានរស់នៅឆ្លងកាត់"* ។ ចុងបញ្ចប់ អៀង ធីរិទ្ធ ថ្លែងអំណរគុណអង្គការសហប្រជាជាតិក្នុងការបន្តទទួលស្គាល់ ហើយសុំទាមទារឲ្យវៀតណាមដកថយពីកម្ពុជា ។

វាគ្មិនសំខាន់មួយទៀតនៅឯសន្និសីទនៅទីក្រុងស្តុកខូម គឺជាអ្នកការពារខ្មែរក្រហមឈ្មោះ ចច ហ៊ីលប្រែន ជាសហនិពន្ធជាមួយលោក ហ្គារ៉េត ផតធ័រ ដែលសរសេរសៀវភៅមានចំណងជើងថា "ការអត់អាហារ និង បដិវត្តន៍" ។ សៀវភៅនេះត្រូវបានលោក ណាម ឆមស្គី និង អេដវ៉ាដ ហឺមែន សរសើរនៅក្នុងទស្សនាវដ្តី "The Nation" ចេញផ្សាយឆ្នាំ១៩៧៨ថា មានលក្ខណៈ "សុក្រឹតនិងស្រាវជ្រាវបានល្អ" ។ ឆមស្គី និងអ្នកជំនួយការ បានវាយប្រហារទៅលើអ្នកសិក្សាជាន់ខ្ពស់អំពីបញ្ហាកម្ពុជាដែលប្រកបដោយមនសិការដូចជា ញេមប្រុស ប៉ុនចូត ថាមានកំហុសពិតប្រាកដ ហើយបានប្រៀបប្រដូចរបបកម្ពុជាប្រជាធិបតេយ្យទៅនឹងប្រទេសបារាំងក្រោយសង្គ្រាម ។ ហ៊ីលប្រែន ដើរតាមមាគ៌ាថ្មីរបស់ចិន ហើយបានសារភាពថា ពិតជាមាន"បញ្ហាធ្ងន់ធ្ងរមួយចំនួននៅក្នុងប្រទេសកម្ពុជា នៅអំឡុងឆ្នាំ១៩៧៥-៧៨ ។ ខ្ញុំជឿថា អ្វីៗដែលកើតឡើង និយាយឲ្យស្រួលស្តាប់គឺខុសទាំងផ្លូវសីលធម៌និងនយោបាយ" ។ ក៏ប៉ុន្តែ ហ៊ីលប្រែន មិនបានបកអាក្រាតអំពើឃោរឃៅទាំងនោះទេ បែរជាសុំឲ្យមានការ"រិះគន់ប្រកបដោយន័យស្ថាបនាទៅវិញ" ។ សូម្បីតែមកទល់នឹងចុងឆ្នាំ១៩៧៩ទៅហើយ ក៏ ចច ហ៊ីលប្រែន នៅតែបន្តអះអាងថាវាជាការពិបាកពិពណ៌នាឲ្យបានសុក្រឹតណាស់អំពីសភាពការណ៍នៅកម្ពុជា ។ មិនដូចអ្នកសារពត៌មានដទៃទៀត ដូចជា ណេល ដាវីស ដែលពិតជាបានចំណាយពេលនៅកម្ពុជា និងបានពិពណ៌នាយ៉ាងសុក្រឹតអំពីចេតនារបស់ខ្មែរក្រហមនៅដើមខែឧសភា ឆ្នាំ១៩៧៨ ហ៊ីលប្រែន អះអាងថា សភាពការណ៍នៅកម្ពុជានៅតែមិនច្បាស់នៅឡើយ ។ ហ៊ីលប្រែន និង ឆមស្គី បានសរសេរអត្ថបទរិះគន់ជាច្រើនដាក់កាសែតញូវយ៉កថែម, វ៉ាស៊ីនតោនប៉ុស្តិ៍ និង រីតឌ័រឌីហ្គេស ដើម្បីទាញជាសេចក្តីសន្និដ្ឋានថា "សង្គ្រាមបង្ហាញពីការឃោសនា ប៉ុន្តែនៅទីនេះយើងមានឯកសារភូតកុហកដែលអាចប្រៀបបាននឹងទស្សនៈរបស់បណ្ឌិត ហ្គោប៊ែល ដែរ ។ ដូច្នេះចូរយើងចាប់ផ្តើមដោយប្រុងប្រយ័ត្នក្នុងការព្យាយាមស្វែងយល់អំពីកម្ពុជា ចេញពីអ្វីដែលគេបាននិយាយអំពីប្រជាជនកម្ពុជានិងសត្រូវរបស់ខ្លួនទាំងអតីតកាលនិងបច្ចុប្បន្នកាល ។ នៅក្នុងស្ថានការណ៍បែបនេះ អ្វីៗត្រូវតែថ្លឹងថ្លែង ត្រូវតែវែងចម្រាញ់ និងធ្វើតេស្តសាកល្បងមើលសិន" ។ ហ៊ីលប្រែន បានលើកសរសើរកម្ពុជាប្រជាធិបតេយ្យដែលបានបង្កើនផលិត

ផលស្បៀង ហើយអរគុណចំពោះអង្គការសហប្រជាជាតិដែលបានជួយគាំទ្រខ្មែរក្រហមៈ «ពិភពលោកក៏ដឹងបញ្ហានេះដែរ ដូចដែលស្តែងឲ្យឃើញស្រាប់តាមរយៈការបោះឆ្នោតគាំទ្រកៅសិបមួយសំឡេងទល់នឹងម្ភៃមួយសំឡេង ទាមទារឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា» ។

នៅថ្ងៃចុងបញ្ចប់ សន្និសីទអន្តរជាតិស្តីអំពីកម្ពុជាបានថ្កោលទោស «ការកាន់កាប់ប្រកបដោយភាពឃោរឃៅរបស់វៀតណាមមកលើកម្ពុជា» ហើយសុំឲ្យមានការដកកងទ័ពវៀតណាម និងទ័ពបរទេសទាំងអស់ចេញពីទឹកដីកម្ពុជាជាបន្ទាន់និងដោយគ្មានលក្ខខណ្ឌ ព្រមទាំង «ជនជាតិវៀតណាមដែលមកតាំងទីលំនៅក្នុងប្រទេសកម្ពុជាតាំងពីពេលដែលកងទ័ពវៀតណាមចូលមកលុកលុយកម្ពុជា» ផង ។ គណៈប្រតិភូអបអរសាទរ «យ៉ាងកក់ក្តៅ» ចំពោះការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ក្នុងការរក្សាអាសនៈរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅមហាសន្និបាតអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចសុំឲ្យដកកងទ័ពបរទេសទាំងអស់ចេញពីទឹកដីកម្ពុជា ។

នៅចុងឆ្នាំ១៩៧៩ និងស្ទើរតែពេញមួយឆ្នាំ១៩៨០ អតីតមេដឹកនាំខ្មែរក្រហម អៀង ធីរិទ្ធ និងប្តីឈ្មោះ អៀង សារី បានធ្វើដំណើរជុំវិញពិភពលោក ក្នុងនាមជាមុខជាមាត់របស់កម្ពុជាប្រជាធិបតេយ្យ ។ អៀង ធីរិទ្ធ បានទៅធ្វើទស្សនកិច្ចនៅប្រទេសអេហ្ស៊ីប ស៊ូដង់ សូម៉ាលី ហ្សាអៀ ទីក្រុងម៉ានីល ទីក្រុងរ៉ូម ទីក្រុងហ្សឺណែវ និង វីយែនណា ត្រឹមតែរយៈពេលមួយឆ្នាំប៉ុណ្ណោះគឺនៅឆ្នាំ១៩៨០ ពីព្រោះអាទិភាពនៃនយោបាយកំពូលរបស់កម្ពុជាប្រជាធិបតេយ្យគឺ ត្រូវបង្កើនទំនាក់ទំនងសាធារណៈ ។ គ្រីស្តូហ្វ័រ ចូន បានសរសេរនៅក្នុងកាសែតញូវយ៉កថែមថា «នៅក្នុងរដ្ឋធានីជាច្រើននៅលើពិភពលោក អង្គទូតខ្មែរក្រហមតូចតាចបានប្រឹងប្រែងធ្វើការជាអាទិភាព... គឺដើម្បីបង្ហាញពីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យថា ជាសុភាពបុរសមានចរិតថ្លៃថ្នូរ ត្រូវបានគេចោទប្រកាន់ទាំងកម្រោលថាបានប្រព្រឹត្តអំពើឃោរឃៅ ឈ្លក់វង្វេងនឹងសហរដ្ឋអាមេរិក ពាណិជ្ជកម្មអន្តរជាតិ សេដ្ឋកិច្ចទីផ្សារ ការបោះឆ្នោតដោយមានការគ្រប់គ្រងត្រឹមត្រូវ បារាំងនិយម និង សិទ្ធិមនុស្ស» ។

នៅពេលដែលអ្នកកាន់ម៉ាស៊ីនថតមកពីស្ថានីយ៍ថតឯកសាររបស់អាល្លឺម៉ង់ខាងកើតឈ្មោះ ហេណ្ហូស្កី និងសូម៉ាន់ ធ្វើសម្ភាសន៍ អៀង ធីរិទ្ធ នៅឆ្នាំ១៩៧៩ នៅសន្និសីទទីក្រុងស្តុកខូម អៀង ធីរិទ្ធិ បានព្យាយាមពន្យល់បង្ហាញអំពីវិធីដែលខ្មែរក្រហមបានប្រើប្រាស់ដើម្បីប្រែក្លាយខ្លួនពីលទ្ធិកុម្មុយនិស្តសម័យុគថ្មរំលីងទៅជាលទ្ធិប្រជាធិបតេយ្យនិងមូលធននិយមបែបទីផ្សារសេរីនៅក្នុងអំឡុងពេលមួយមិនដល់មួយឆ្នាំផង ។ អ្វីដែលចម្លែកអស្ចារ្យនោះគឺសម្ព័ន្ធភាពថ្មីរបស់ខ្មែរក្រហមជាមួយសត្រូវដ៏សម្អប់បំផុតរបស់ខ្លួន គឺសហរដ្ឋអាមេរិក ។ អៀង ធីរិទ្ធ ព្យាយាមបញ្ជាក់ទំនាស់ជាក់ស្តែងនេះថា «អស់លោកដឹងទេថាសហរដ្ឋអាមេរិកមុនដំបូងមកឈ្លានពានប្រទេសយើងខ្ញុំ ប៉ុន្តែឥឡូវនេះគេគាំទ្រឯករាជ្យភាពរបស់យើង យើងចាត់ទុកសហរដ្ឋអាមេរិកថាជាមិត្តរបស់យើង» ។ លើសពីអ្វីៗទាំងអស់ អៀង ធីរិទ្ធ នឹងក្លាយជាមនុស្សដែលអ្នកផងចាំមិនភ្លេច ដែលបានបែងចែកអកុសលថាជាមេដឹកនាំខ្មែរក្រហមទីមួយដែលផ្ទាញ់ផ្ទាលភាពត្រឹមត្រូវនៃរូបថតនៅទួលស្លែងៈ «អំពីរូបថត អស់លោកដឹងទេថាវៀតណាមគេប្រសប់ណាស់អំពីរឿងនេះ ។ គេអាចប្រឌិតអ្វីៗគ្រប់យ៉ាង ។ គេគ្មានក្តីមេត្តាសោះឡើយ ធ្វើយ៉ាងម៉េចឲ្យតែការឈ្លានពានរបស់គេមានលក្ខណៈស្របច្បាប់ ។ ខ្ញុំសូមសារភាពដូចដែលខ្ញុំបានជម្រាបអស់លោករួចហើយថា ពិតជាមានការលើសលស់មែន ប៉ុន្តែការលើសលស់ទាំងនោះគឺបញ្ហាពីខាងហាណូយមកទេ ។ ដូច្នេះអាជ្ញាធរទីក្រុងហាណូយគេមានមុខពីរ ។ ម្យ៉ាងគេបញ្ជាឲ្យភ្នាក់ងារធ្វើហួសនៅក្នុងប្រទេសរបស់យើង ។ ម្យ៉ាងទៀត គេធ្វើលើសលស់មួយចំនួនដើម្បីពង្រីកការឃោសនាមួលបង្កាច់ជាប្រព័ន្ធរបស់ខ្លួនចូលក្នុងជួររដ្ឋាភិបាលរបស់យើង ដើម្បីថានៅពេលគេចូលមកឈ្លានពានទឹកដីយើងជាសាធារណៈ ទស្សនៈមតិអន្តរជាតិមួលមិរប្រឆាំងនឹងយើងស្រាប់ ពេលនោះទស្សនៈមតិអន្តរជាតិអាចនិយាយថា អូ! វៀតណាមល្អណាស់ ។ គេមិនមែនជាអ្នកឈ្លានពានទេ គេគឺជាអ្នករំដោះប្រជាជនដែលជាជនរងគ្រោះពីរបបដឹកនាំរបស់ខ្លួនទេតើ» ។ **ភីតធ័រ ម៉ាឃ្យៀ**

# សុន្ទរកថារបស់ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដា ស្តេហ្វានី ប៉ែក នៅក្នុងសន្និសីទតាមដានរបស់អ្នកជំនាញការ ស្តីអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិនៅអាស៊ី-អាគ្នេយ៍ និងតំបន់មហាសមុទ្រប៉ាស៊ីហ្វិក

ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលកម្ពុជាដែលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទនេះឡើង និងសូមទទួលស្គាល់ជាពិសេសចំពោះមជ្ឈមណ្ឌលស្តារយុត្តិធម៌នៅអាស៊ី ដែលបានខិតខំធ្វើយ៉ាងណាឲ្យសន្និសីទនេះចេញជារូបរាងឡើង ។ សន្និសីទនេះផ្តល់ឱកាសដល់ទីប្រឹក្សាអ្នកមានអំណាចសម្រេចចិត្តនិងសង្គមស៊ីវិលឲ្យបានចូលរួមជាគំនិត យោបល់ និងបទពិសោធន៍ជាមួយគ្នាទៅវិញទៅមក ទៅលើបញ្ហាថាត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីជំរុញការអនុវត្តនិងការផ្តល់សច្ចាប័នដល់លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ សន្និសីទរបៀបនេះកំពុងតែកើតមានឡើងនៅជុំវិញពិភពលោកនៅគ្រប់តំបន់ដែលជាសក្ខីភាពបញ្ជាក់ពីចលនាឆ្ពោះទៅមុខគួរឲ្យកត់សម្គាល់ នៅពីក្រោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងការជំរុញឲ្យមានការទទួលខុសត្រូវនិងយុត្តិធម៌ជាលក្ខណៈអន្តរជាតិ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាស្ថាប័នសំខាន់បំផុតមួយរបស់អន្តរជាតិចាប់តាំងពីការចាប់បដិសន្ធិនៃអង្គការសហប្រជាជាតិមក ។

តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាស្ថាប័នតុលាការអចិន្ត្រៃយ៍ដែលជួយធានាថា គ្មានបុគ្គលណាម្នាក់អាចរត់គេចពីសំណាញ់ច្បាប់បានឡើយ ប្រសិនបើបុគ្គលនោះប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ។ ដូចយើងជ្រាបស្រាប់ហើយថា ប្រវត្តិសាស្ត្រកន្លងមក រដ្ឋតែងតែខកខានមិនបានចាត់វិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះឧក្រិដ្ឋកម្មទាំងនេះឡើយ ។ បរិយាកាសនៃនិទណ្ឌភាពសព្វថ្ងៃនេះបានជំរុញមានការប្រព្រឹត្តអំពើឃោរឃៅយ៉ាងគឃ្លើនដូចដែលមានជនរងគ្រោះរាប់លាននាក់ជាតឹកតាងស្រាប់ ។ ប្រជាជនកម្ពុជានឹងទទួលការឈឺចាប់ដោយសារថា និទណ្ឌភាពនិងភាពអយុត្តិធម៌ត្រូវបានអនុញ្ញាតឲ្យកើតមានឡើង ។

ជាការសំខាន់ណាស់សម្រាប់សន្តិសុខរបស់មនុស្សជាតិនិងសន្តិសុខជាអន្តរជាតិទាំងមូល ដែលយើងត្រូវចាត់វិធានការមិនរារែកក្នុងការគ្រឡប់ទិសនិន្នាការនេះ តាមរយៈវិធានការស្វាហាប់ ដើម្បីបង្កើតឡើងនូវបរិយាកាសទទួលខុសត្រូវមួយចំពោះមុខច្បាប់ ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី តុលាការព្រហ្មទណ្ឌអន្តរជាតិមិនត្រឹមតែជាការឆ្លើយតបទៅនឹងការទទូចអង្វរករពីសំណាក់ជនរងគ្រោះនៃអតីតកាលនោះទេ ការជួយធានាថា ឧក្រិដ្ឋជនអន្តរជាតិត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ នឹងជួយធ្វើឲ្យរាងចាលមិនមានការប្រព្រឹត្តអំពើឃោរឃៅនៅថ្ងៃអនាគត ។ កត្តានេះនឹងកាត់បន្ថយចំនួនជនរងគ្រោះឲ្យកាន់តែតិចទៅៗ ។

កិច្ចការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងការប្រតិបត្តិតាមបទដ្ឋានគ្រឹះនានា និងធ្វើឲ្យរាងចាលមិនប្រព្រឹត្តអំពើឧក្រិដ្ឋនោះ នឹងជំរុញមិនត្រឹមតែដល់សន្តិសុខរបស់បុគ្គលប៉ុណ្ណោះទេ ប៉ុន្តែដល់ស្ថិរភាពអន្តរជាតិទៅតាមវិធាននៃច្បាប់ទៀតផង ។

ហេតុនេះហើយបានជាលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានហៅតុលាការព្រហ្មទណ្ឌអន្តរជាតិថាជា «ទាយជ្ជទាននៃក្តីសង្ឃឹមសម្រាប់មនុស្សស្រករក្រោយ» ។

តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលបាននូវការគាំទ្រយ៉ាងអឺកអធឹកពីសំណាក់មហាជននៅគ្រប់តំបន់ទាំងអស់នៅក្នុងពិភពលោក ចំណែកឯរដ្ឋាភិបាលនានាកំពុងតែឆ្លើយតបទៅនឹងការទាមទារពីសាធារណជនសុំឲ្យមានចំណាត់វិធានការ ។

លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានអនុម័តនៅក្នុងសន្និសីទទីក្រុងរ៉ូមកាលពីខែកក្កដា ឆ្នាំ១៩៩៨ ។ ការផ្តល់សច្ចាប័នចំនួន៦០ដើម្បីធ្វើឲ្យច្បាប់នេះចូលជាធរមាន បានប្រព្រឹត្តទៅយ៉ាងឆាប់បំផុត ហើយនៅចុងបញ្ចប់ ច្បាប់នេះចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ។

គិតមកដល់ថ្ងៃនេះ ភាគីដែលផ្តល់សច្ចាប័នមានចំនួន៨១ ទៅហើយ ។ ភាគីដទៃៗទៀតកំពុងប្រញាប់ប្រញាល់ចូលមកបន្តបន្ទាប់ទៀត ដែលនេះគឺជាការបង្ហាញនូវចលនារបស់ពិភពលោកទាំងមូល ឆ្ពោះទៅរកការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។

រដ្ឋនានាដែលបានផ្តល់សច្ចាប័នស្មោះស្ម័គ្រចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ បានប្រឆាំងជិតស្និទ្ធឥតងាករេចំពោះភាពរួចទោសនៃអំពើទាំងនេះ ។

ជាការសំខាន់ណាស់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាសាលាក្តីសាកលពិតប្រាកដ ។ ដូចនេះ យើងបន្តធ្វើការទាំងអស់គ្នាដើម្បីជំរុញឲ្យមានការផ្តល់សច្ចាប័នកាន់តែច្រើនពីគ្រប់តំបន់ ។ យើងត្រូវការជាចាំបាច់នូវតុលាការមួយដែលមានទស្សនៈតំណាងឲ្យសហគមន៍មនុស្សជាតិទាំងមូល ។

ខ្ញុំសូមបរិយាយជូនអស់លោក-លោកស្រីនូវលក្ខណៈពិសេសបំផុតរបស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ ព្រមជាមួយនឹងបញ្ហាលំបាកមួយចំនួនដែលមាននៅពេលខាងមុខ ។

### លក្ខណៈពិសេសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ចំណុចដែលលេចធ្លោបំផុតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលខ្ញុំសូមលើកយកមកចូលរួមជាយោបល់នៅពេលនេះ គឺការគោរពចំពោះការវិនិច្ឆ័យទោសនៅក្នុងស្រុក ដែនសមត្ថកិច្ចរបស់តុលាការនិងការធានា នៅក្នុងលក្ខន្តិកៈច្បាប់នេះផ្ទាល់ ។

### ឧក្រិដ្ឋកម្ម

សូមបញ្ជាក់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចតែទៅលើឧក្រិដ្ឋកម្មដែលមានចរិតធ្ងន់ធ្ងរ ដែលធ្វើឲ្យសហគមន៍អន្តរជាតិទាំងមូលព្រួយបារម្ភ ជាអាទិ៍មានៈ អំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ថ្ងៃណាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមានដែនសមត្ថកិច្ចទៅលើឧក្រិដ្ឋកម្មឈ្លានពានថែមទៀត ល្គឹកណាតែនិយមន័យដែលទទួលស្គាល់ជាទូទៅមួយត្រូវបានអនុម័ត ។

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានឲ្យនិយមន័យយ៉ាងផ្ចិតផ្ចង់នៅក្នុងលក្ខន្តិកៈច្បាប់ ដោយអនុលោមតាមច្បាប់ដែលបានកំណត់និងការផ្តោតសំខាន់នៅលើអំពើឃោរឃៅទ្រង់ទ្រាយធំដែលប្រព្រឹត្តឡើងដោយចេតនា ។

មិនតែប៉ុណ្ណោះ "ធាតុផ្សំនៃបទឧក្រិដ្ឋ" បន្ថែមផ្សេងទៀតត្រូវបានអនុម័តដោយមតិទូទៅ ដោយរាយឈ្មោះធាតុផ្សំនានាដែលរដ្ឋអាជ្ញាត្រូវតែបង្ហាញចំពោះករណីបទឧក្រិដ្ឋនីមួយៗនិងដោយផ្តល់នូវភាពច្បាស់លាស់ថែមទៀត និងការផ្តោតទៅលើបទឧក្រិដ្ឋធ្ងន់ធ្ងរដែលលែងទទួលស្គាល់ដោយប្រព័ន្ធ(យុត្តិធម៌)របស់ជាតិ ។

### ភាពបំពេញគ្នាទៅវិញទៅមក

ចំណុចសំខាន់ទីពីរនៃតុលាការព្រហ្មទណ្ឌអន្តរជាតិគឺថាតុលាការនេះមិនមានបំណងជំនួសតុលាការជាតិឡើយ ។

លក្ខន្តិកៈច្បាប់របស់តុលាកាព្រហ្មទណ្ឌអន្តរជាតិយកគោល-ការណ៍ "បំពេញគ្នាទៅវិញទៅមក" ដែលមានន័យថា រដ្ឋជាសមាជិកមានសិទ្ធិនិងឱកាសអាទិភាពក្នុងការស៊ើបអង្កេតនិងកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិឈានជើងចូលមកនៅពេលណាដែលរដ្ឋទាំងនោះខកខានមិនបានទទួលខុសត្រូវនាំយកចារីនៃបទល្មើសមកកាត់ទោសចំពោះមុខតុលាការតែប៉ុណ្ណោះ ។

លក្ខន្តិកៈច្បាប់នេះមានបទដ្ឋាននិងនីតិវិធីហ្មត់ចត់ដើម្បីធានាថា រដ្ឋនានាដែលមានប្រព័ន្ធយុត្តិធម៌ច្បាស់លាស់ និងធ្វើការដោយសុឆន្ទៈនោះ នឹងមិនមានផលប៉ះពាល់ពីសំណាក់តុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ។

ដូច្នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនទន្រ្ទានមកលើអធិបតេយ្យភាពរបស់ជាតិឡើយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់នូវការធានាបន្ថែមនៅក្នុងករណីដែលយើងបរាជ័យ ឬខ្វះសក

ទៅរករបបផ្តាច់ការសង្កត់សង្កិន ហើយមិនអាចឬគ្មានឆន្ទៈចង់ឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិដែលមានចរិតធ្ងន់ធ្ងរ ។

## ដែនសមត្ថកិច្ច

ចំណុចសំខាន់ទីបីគឺ ដែនសមត្ថកិច្ច ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមានមូលដ្ឋានត្រឹមត្រូវចំពោះដែនសមត្ថកិច្ចដែលកំពុងអនុវត្ត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចប្រតិបត្តិបាន÷

◆ នៅក្នុងករណីដែលដែនសមត្ថកិច្ចរបស់ខ្លួនត្រូវបានទទួលយកដោយរដ្ឋមួយដែលមានឧក្រិដ្ឋកម្មកើតឡើងនិងនៅក្នុងករណីដែនសមត្ថកិច្ចរបស់ខ្លួនត្រូវបានទទួលយកដោយរដ្ឋដែលជាជាតិរបស់ជនជាប់ចោទ ។

◆ នៅពេលដែលពិចារណាថាឧក្រិដ្ឋកម្មទាំងនេះគឺជាឧក្រិដ្ឋកម្មដែលមានដែនសមត្ថកិច្ចសាកលឃើញថា ប្រការនេះគឺមានមូលដ្ឋានគ្រឹះនៃដែនសមត្ថកិច្ចដែលមានលក្ខណៈព្រមាននិងរឹងមាំ ។

◆ នៅពេលចរចាទៅលើលក្ខន្តិកៈច្បាប់នេះ មតិភាគច្រើនលើសលប់នៃរដ្ឋនានាបានគាំទ្រដល់ទម្រង់ដែនសមត្ថកិច្ចមួយដែលមានលក្ខណៈកាន់តែទូលំទូលាយដូចដែលបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិដែលនៅជាធរមាន ។ នៅទីបញ្ចប់ មូលដ្ឋានដែលមានលក្ខណៈព្រមាននេះត្រូវបានអនុម័តថាជាសម្បទានចំពោះរដ្ឋនានាដែលស្ទាក់ស្ទើរមិនចង់ចូលរួម ។

តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងចាប់ផ្តើមប្រតិបត្តិទៅលើមូលដ្ឋានគ្រឹះនៃដែនសមត្ថកិច្ចដែលមានលក្ខណៈរឹងមាំ ដើម្បីធ្វើកិច្ចការកុំឲ្យមានការស្តីបន្ទោស ម្យ៉ាងវិញទៀត ដើម្បីឲ្យរដ្ឋនានាមានឱកាសមើលឃើញនូវសកម្មភាពប្រកបដោយភាពជឿទុកចិត្តបាននិងការទទួលខុសត្រូវ ។

អ្នកអត្ថាធិប្បាយមួយចំនួន ជាពិសេសនៅសហរដ្ឋអាមេរិកបានទាញហេតុផលថា នេះគឺជាដែនសមត្ថកិច្ចបោកប្រាស់ ពីព្រោះថា តុលាការព្រហ្មទណ្ឌអន្តរជាតិអាចនឹងត្រូវបានគិតដល់ថាមានដែនសមត្ថកិច្ចទៅលើជនជាតិនានារបស់រដ្ឋណាមួយដែលមិនមែនជាភាគីនៃលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ក៏ប៉ុន្តែជាការសំខាន់ត្រូវចាំថា ដែនសមត្ថកិច្ចរបៀបនេះកើតឡើងនៅកន្លែងដែលជននោះបានប្រព្រឹត្តបទល្មើសប៉ុណ្ណោះនៅលើទឹកដីរបស់រដ្ឋអធិបតេយ្យដែលបានសុខចិត្តទទួលយកនូវដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមកលើទឹកដីរបស់ខ្លួន ។

សមត្ថកិច្ចដែនដីគឺជាគោលការណ៍ដែនសមត្ថកិច្ចហ្មត់ចត់បំផុតដែលច្បាប់ទទួលស្គាល់ ។ វាក៏ជាផ្នែកមួយដែលមកភ្ជាប់ជាមួយនឹងអធិបតេយ្យភាព ។ មានមតិទូទៅនិយាយថា បុគ្គលណាក៏ដោយ ទោះមានសញ្ជាតិអ្វីក៏ដោយ ដែលឈានជើងជាន់ទឹកដីរបស់រដ្ឋអធិបតេយ្យមួយ ដាច់ខាតត្រូវតែគោរពច្បាប់របស់រដ្ឋនោះ ។ ប្រការនេះរួមបញ្ចូលទាំងច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយរដ្ឋនោះផង ក្នុងនោះមានរបបលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិផង ។

រដ្ឋនានាអាចប្រើសិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមនៅក្នុងតុលាការរបស់ខ្លួន ឬធ្វើរួមគ្នាជាមួយតុលាការអន្តរជាតិ ។ គោលការណ៍នេះត្រូវបានបញ្ជាក់សាជាថ្មីនៅទីក្រុងនូរិមប៊ឺកនិងពេលក្រោយៗមកទៀត ។ នេះគឺជាមូលដ្ឋានសំខាន់នៃដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ដើម្បីអះអាងថា បុគ្គលនៃជនជាតិណាមួយគួរតែត្រូវរួចខ្លួននោះ យកល្អគួរតែត្រឡប់ទៅមើលគោលការណ៍នៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ និងបដិសេធចោលនូវអធិបតេយ្យ-ភាពរបស់រដ្ឋដែលបទល្មើសខាងលើត្រូវបានប្រព្រឹត្ត ។

## ការធានា

ចំណុចចុងក្រោយ ខ្ញុំគួរតែនិយាយពាក្យមួយម៉ាត់អំពីការធានាដ៏ទូលំទូលាយដែលបានបញ្ចូលទៅក្នុងលក្ខន្តិកៈច្បាប់នេះ ក្នុងគោលបំណងទប់ស្កាត់ការកាត់សេចក្តីមិនត្រឹមត្រូវឬប្រើប្រាស់តុលាការនេះដើម្បីបម្រើឲ្យផលប្រយោជន៍នយោបាយ ។

ចំណុចធានាដ៏សំខាន់គឺគោលការណ៍បំពេញគ្នាទៅវិញទៅមកដែលខ្ញុំបានលើកយកមកនិយាយរួចមកហើយ ដែលថារដ្ឋមួយអាចប្រានចោលជាមុននូវសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយបំពេញនូវកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនដើម្បីស៊ើបអង្កេតនិងកាត់សេចក្តីដោយឥតក្លែងនូវបទឧក្រិដ្ឋធ្ងន់ធ្ងរដែលប្រព្រឹត្តដោយប្រជាពលរដ្ឋរបស់ខ្លួន ។

បន្ថែមពីលើនេះទៀត មានតុល្យភាពអំណាច ។ ឧទាហរណ៍ព្រះរាជអាជ្ញាមិនអាចផ្តើមស៊ើបអង្កេតដោយគ្មានទទួលនូវការ

ពិនិត្យនិងអនុម័តិដោយឯករាជ្យពីសំណាក់ក្រុមចៅក្រមបីរូប ដែលធ្វើការឥតលម្អៀងនោះឡើយ ។ រដ្ឋដែលមានការចាប់អារម្មណ៍ អាចប្តឹងទៅសាលាឧទ្ធរណ៍បាន ។ ដូចនេះទឡ្ហីករណ៍ដែលថាព្រះរាជអាជ្ញាមិនទទួលខុសត្រូវ គឺជាការច្បាស់ណាស់ថាវាមិនត្រឹមត្រូវទេ ។

ចំណុចមួយទៀតដែលគួរឲ្យកត់សម្គាល់ដែរគឺថា ចៅក្រមនិងព្រះរាជអាជ្ញាត្រូវតែជ្រើសតាំងឡើងដោយសភារបស់រដ្ឋជាសមាជិក ដោយអនុលោមតាមលក្ខណៈសម្បត្តិដែលមានស្រាប់ទាក់ទងនឹងវិជ្ជាជីវៈនិងបទពិសោធន៍ ។ ប្រតិបត្តិការរបស់តុលាការក៏ត្រូវតែត្រួតពិនិត្យដោយសភារបស់រដ្ឋជាសមាជិកដែរ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់នូវការធានាច្រើនជាងតុលាការប្រភេទផ្សេងទៀត ។ លក្ខន្តិកៈច្បាប់នេះមានៈ ការថ្លឹងអំណាចស្មើគ្នា ការបែងចែកអំណាច និងការធានាឲ្យធ្វើតាមនីតិវិធីត្រឹមត្រូវចម្រាញ់ចេញនូវរាល់ការប៉ុនប៉ងរំលោភច្បាប់ ។ មន្ត្រីដែលមិនទទួលខុសត្រូវ ដែលរំលោភទៅលើអំណាចរបស់ខ្លួន អាចត្រូវបានដកចេញពីតំណែងតាមរយៈសភារបស់រដ្ឋជាសមាជិក ។

លើសពីនេះទៀត លក្ខន្តិកៈច្បាប់នេះធានាបាននូវបទដ្ឋានយុត្តិធម៌ខ្ពស់បំផុត និងការគោរពនូវសិទ្ធិទាំងឡាយរបស់ជនជាប់ចោទដែលទទួលស្គាល់ជាអន្តរជាតិ ។

## ផ្លូវឆ្ពោះទៅមុខ

សរុបមកវិញ តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាស្ថាប័នរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ដោយមានឧបករណ៍ធ្វើកិច្ចការ និងធ្វើឲ្យមានភាពផ្សេងគ្នា ប៉ុន្តែធានាមិនឲ្យមានការរំលោភច្បាប់ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលបាននូវការគាំទ្រដ៏សម្បើមនិងចេះតែកើនឡើង ប៉ុន្តែយើងត្រូវតែប្រយុទ្ធដើម្បីឲ្យមានការគាំទ្រនិងការផ្តល់សច្ចាប័នកាន់តែច្រើនជាងនេះទៅទៀត ដើម្បីការពារនូវជនរងគ្រោះសំខាន់ៗ នៅគ្រប់ទិសទី ។

នៅក្នុងន័យនេះ ការប្រឆាំងជំទាស់របស់សហរដ្ឋអាមេរិកគឺជាប្រការគួរឲ្យសោកស្តាយខ្លាំងណាស់ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិផ្អែកលើតម្លៃនិងគោលការណ៍នានាដែលសហរដ្ឋអាមេរិកបានគាំទ្រតាំងពីយូរយារណាស់មកហើយ រួមទាំងនីតិរដ្ឋ ការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ការកាត់សេចក្តីរួមគ្នាតាមរយៈតុលាការអន្តរជាតិ និងសមភាពនៅចំពោះមុខច្បាប់ ។ តុលាការនេះគឺផ្អែកទៅលើទស្សនាទានរួមមួយទូទាំងពិភពលោកថា មិនត្រូវបណ្តោយឲ្យឧក្រិដ្ឋកម្មដ៏គួរឲ្យព្រឺព្រួចរួចពីការកាត់សេចក្តីសោះឡើយ ។

តាមការស្ទាបស្ទង់មតិសាធារណៈឲ្យដឹងថា មតិភាគច្រើននៃប្រជាពលរដ្ឋអាមេរិកាំងបានគាំទ្រដល់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ជាអកុសល ប្រការនេះមិនទាន់បញ្ជាក់ច្បាស់អំពីជំហរដែលអនុម័តដោយសំឡេងភាគច្រើននៅក្នុងរដ្ឋការនិងសហសភារបស់អាមេរិកទេ ។ ផ្ទុយទៅវិញ យើងមើលឃើញការផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើទស្សនវិស័យថានឹងគ្មានការកាត់ទោសពលរដ្ឋអាមេរិកដោយមិនត្រឹមត្រូវនោះដែរ ។ ប៉ុន្តែការធានាដ៏ទូលំទូលាយមែនទែននៅក្នុងលក្ខន្តិកៈច្បាប់ថា រដ្ឋកាន់លទ្ធិប្រជាធិបតេយ្យដែលមានប្រព័ន្ធតុលាការរឹងមាំ និងប្រពៃណីដែលអនុលោមទៅតាមច្បាប់មនុស្សធម៌ មិនមានអ្វីគួរឲ្យភ័យខ្លាចពីតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ។

រដ្ឋការបច្ចុប្បន្នកំពុងតែខំទទូចឲ្យមានការព្រមព្រៀងទ្វេភាគីជាមួយរដ្ឋទាំងអស់ដែលនឹងមិនប្រគល់ជនជាតិអាមេរិកាំងមកតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ស្ថានភាពបែបនេះបង្ហាញពីការឆ្លុះបញ្ចាំងនិងការពិភាក្សាក្នុងចំណោមរដ្ឋនានា ។

តុលាការព្រហ្មទណ្ឌអន្តរជាតិមាន«ខ»មួយមែនឡើងសម្រាប់ស្ថានភាពជាលក្ខណៈប្រពៃណីនៃកិច្ចព្រមព្រៀងទាក់ទងនឹងកម្លាំងទ័ព ពោលគឺការពារបុគ្គលិកយោធាបច្ចុប្បន្ន ឬបុគ្គលិកស៊ីវិលដែលពាក់ព័ន្ធ ដូច្នេះហើយបានជាមានពាក្យថា"រដ្ឋជាភ្ញៀវ" នៅក្នុងមាត្រានោះ ។ ការប៉ុនប៉ងផ្តល់នូវអញ្ញត្រកម្ម (ឲ្យរួចខ្លួន) ដល់អតីតមន្ត្រី ឬក៏ចំពោះជនជាតិទាំងអស់ គឺមិនមានមែននៅក្នុងប្រការនេះទាល់តែសោះ ហើយបើធ្វើដូច្នេះវានឹងរំលោភទៅលើលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមបាត់ទៅហើយ ។

មិនតែប៉ុណ្ណោះសោត រាល់កិច្ចព្រមព្រៀងទ្វេភាគីដែលខ្វះកាតព្វកិច្ចច្បាស់ជាក់ស្តែងដើម្បីស៊ើបអង្កេតនិងកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ នឹងផ្តល់ជាលទ្ធផលចុងក្រោយនូវការរួចទោសជាមិនខាន ។ ប្រការនេះធ្វើឲ្យអន្តរាយដល់កម្មវត្ថុនិងគោលបំណងរបស់លក្ខន្តិកៈច្បាប់តុលាការអន្តរជាតិ ហើយក៏នឹងរំលោភ

ទៅលើការតព្វកិច្ចអន្តរជាតិជាច្រើនរាប់មិនអស់ដែរ ។

រដ្ឋនានាគួរតែវាយតម្លៃដោយប្រុងប្រយ័ត្ននូវកត្តាដែលត្រូវបញ្ចូលក្នុងការធ្វើវិនិច្ឆ័យផ្សេងៗទៀត មុនពេលប្រញាប់ប្រញាល់ចុះកិច្ចព្រមព្រៀងអំពីភាពរួចទោសដែលមានលក្ខណៈមិនសមរម្យ ។ យើងទាំងអស់គ្នាប្រាថ្នាចង់បន្ធូរការព្រួយបារម្ភរបស់សហរដ្ឋអាមេរិក ប៉ុន្តែយើងត្រូវតែស្វែងរកការឆ្លើយតបមួយដែលមិនធ្វើឲ្យអន្តរាយដល់ច្បាប់អន្តរជាតិ និងការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនដែលមានបំណងដៅមុខសញ្ញាយោធាសហរដ្ឋអាមេរិកឡើយ ហើយយើងត្រូវតែស្វែងរកវិធីនានាដើម្បីធានាដល់សហរដ្ឋអាមេរិកថាតុលាការនេះចាត់ការបានត្រឹមតែឧក្រិដ្ឋកម្មដែលមានជាភ័ស្តុតាងនិងមានលក្ខណៈធ្ងន់ធ្ងរ ហើយរដ្ឋនានាខកខានមិនបានដោះស្រាយប៉ុណ្ណោះ ។ ក៏ប៉ុន្តែយើងក៏ត្រូវរំឭកឡើងវិញថា តាមគោលការណ៍ការផ្តល់នូវការរួចខ្លួនចំពោះអ្នកមានអំណាច នឹងធ្វើឲ្យអន្តរាយដល់បូរណភាពដែនដីក៏ដូចជាសមភាពចំពោះមុខច្បាប់ ។

ចំណុចចុងក្រោយគឺថា ការឆ្លើយតបដ៏ល្អបំផុតទៅនឹងការព្រួយបារម្ភអំពីតុលាការនេះ គឺជាការអនុវត្តជាក់ស្តែង ។ មុខងារដែលគួរឲ្យជឿជាក់បាន និងដែលមានការទទួលខុសត្រូវគឺការឆ្លើយបដិសេធរាល់ថ្ងៃនូវការភ័យខ្លាចតាមការស្រមើស្រមៃ ហើយនឹងបង្ហាញអំពីសារសំខាន់របស់តុលាការផ្ទាល់តែម្តង ។ យើងសង្ឃឹមថាមានថ្ងៃណាមួយប្រហែលជាប៉ុន្មានឆ្នាំ ឬប៉ុន្មានទសវត្សរ៍ទៀត សហរដ្ឋអាមេរិកនឹងចូលរួមជាមួយមិត្តនិងសម្ព័ន្ធមិត្តរបស់ខ្លួនក្នុងកិច្ចប្រឹងប្រែងរបស់យើងក្នុងការនាំយកបុគ្គលដែលប្រព្រឹត្តមនុស្សឃាតដោយទ្រង់ទ្រាយធំ រំលោភ ធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតមកតុលាការ ដើម្បីវិនិច្ឆ័យទោសទៅតាមច្បាប់ ។

បើនិយាយឲ្យកាន់តែទូលាយដល់រូបភាពលើឆាកអន្តរជាតិវិញ ឃើញថាការរីកចម្រើននៃតុលាការព្រហ្មទណ្ឌអន្តរជាតិគឺមានកម្រិតធំដុំក្រៃលែង ។ វិធានការជាក់ស្តែងឥឡូវនេះគឺចង់ប្រែក្លាយរូបរាងរបស់តុលាការដែលនៅជាគំនិតនៅឡើយ ឲ្យក្លាយទៅជាការពិតជាក់ស្តែង ដោយមានរចនាសម្ព័ន្ធនិងបុគ្គលប្រចាំនៅទីក្រុងឡាអេ ។ មន្ត្រីចូលធ្វើការដំបូងមានជារួចស្រេចទៅហើយ ហើយមន្ត្រីមួយចំនួនទៀតកំពុងតែត្រូវបានជ្រើសរើសឲ្យចូលបម្រើការដើម្បីចាប់ផ្តើមប្រតិបត្តិការតុលាការនេះនៅប៉ុន្មានខែខាងមុខនេះ ។ កិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់សច្ចាប័ន និងការអនុវត្តជាក់ស្តែង កំពុងតែដំណើរការនៅប្រទេសជាច្រើនក្នុងល្បឿនមួយលឿនអស្ចារ្យ ។

ការគាំទ្រដល់តុលាការព្រហ្មទណ្ឌចេះតែបន្តឥតឈប់ ។ មានហេតុផលជាច្រើនដែលបណ្តាលឲ្យមានការគាំទ្របែបនេះ ។

ទីមួយៈ លក្ខន្តិកៈច្បាប់របស់តុលាការនេះផ្ទាល់ត្រូវបានគេយល់កាន់តែច្បាស់ និងសរសើរកាន់តែច្រើន ។ រដ្ឋនានាមានឱកាសស្គាល់ការធានាទាំងឡាយដែលមានចែងនៅក្នុងលក្ខន្តិកៈច្បាប់ មានឱកាសដឹងពីរបៀបតុលាការធ្វើការ និងមូលហេតុអ្វីបានជាតុលាការនេះមានសារសំខាន់ ។

ទីពីរៈ តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាមូលដ្ឋាននៃបំណងប្រាថ្នាដ៏ខ្លាំងក្លារបស់ពិភពលោក ក្នុងការបញ្ចប់ភាពរួចទោស ។ ប្រជាជនទូទៅកំពុងតែទាមទារចំណាត់វិធានការ ហើយរដ្ឋាភិបាលកំពុងតែឆ្លើយតប ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំនានាកំពុងតែទទួលស្គាល់នូវផលប្រយោជន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយកំពុងតែចាត់វិធានការក្នុងការផ្តល់សច្ចាប័នដើម្បីធ្វើឲ្យរអាដល់ជនជនទាំងឡាយដែលកំពុងតែគិតចង់ប្រើកម្លាំងបាយដើម្បីសម្រេចនូវគោលបំណងនយោបាយរបស់ខ្លួន ។

ទីបីៈ ប្រទេសជាច្រើនបានទទួលស្គាល់ថាតុលាការព្រហ្មទណ្ឌអន្តរជាតិឥឡូវនេះក្លាយជាការពិតហើយ ហើយគួរឲ្យចង់ក្លាយជាផ្នែកមួយនៃស្ថាប័ននេះឲ្យបានពីដើមទី ។

មិនតែប៉ុណ្ណោះ តាមរយៈការផ្តល់សច្ចាប័ននិងយល់ព្រមតាមលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋាភិបាលនានាដែលមានតំណាងនៅទីនេះនិងថ្ងៃនេះស្រាប់ អាចធានាថាមន្ត្រីនិងចៅក្រមមកពីអាស៊ីភាគអាគ្នេយ៍និងមហាសមុទ្រប៉ាស៊ីហ្វិកគឺជាតំណាងដ៏ពេញលេញក្នុងសមាសភាពតុលាការនេះ ។ ប្រការនេះនឹងជួយធានាថាយើងមានតុលាការចក្រវាឡមួយ ជាតុលាការដែលទទួលនូវការគោរពពីប្រជាជនទាំងអស់នៅលើពិភពលោក ។

សូមអរគុណ ។

# ឆ្លើយតបទៅនឹងអត្ថបទ៖

## ភ្ជាក់ខារផ្តាច់ព្រលឹង (ទស្សនាវដ្តីស្វែងរកការពិតលេខ ៣១)

"ប្រជាជនកម្ពុជាត្រូវបានសម្លាប់ចោលដោយគ្មានមូលហេតុ ឬដោយសារមិនសូវខិតខំធ្វើការ ឬដោយសារខ្លួនចេះដឹងជ្រៅជ្រះ ឬជាជនជាតិ ។ ខ្មែរក្រហមទទួលមេរៀនយ៉ាងចំណាប់ចំណួន ពីពួកណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទីពីរ" ។

សេចក្តីដកស្រង់ខាងលើមកពី ឌិត ប្រ៉ាន នៅមហាវិទ្យាល័យ អាមេរិកាំង នោះគឺជាសេចក្តីលម្អៀងទូទៅមួយ និងជាការយល់ខុសទៅលើប្រវត្តិសាស្ត្រមហាពិឃាត ។ នៅក្នុងខ្លឹមសារនេះ ឌិត ប្រ៉ាន និយាយដូច អាឡិច ហ៊ីនតុន ដែរថា មេរៀននៃមហាពិឃាតគឺបានមកពីពួកណាហ្ស៊ី ។ ប៉ុន្តែសេចក្តីដកស្រង់ខាងក្រោមបានមកពីអតីតក្រុមកុម្មុយនិស្តនិងអ្នកគាំទ្រកុម្មុយនិស្តដែលនិយាយផ្សេងពីនេះ ។ តើណាហ្ស៊ីជាអ្នករៀនពីជនកុម្មុយនិស្ត ឬជនកុម្មុយនិស្តរៀនពីពួកណាហ្ស៊ី? នេះគឺជាសេចក្តីដកស្រង់ចេញពីស្នាដៃនិពន្ធរបស់លោក ស៊ីវហ្វាន គូទ័រ (និពន្ធនាយក) ដែលមានចំណងជើងថា "សៀវភៅខ្មៅកុម្មុយនិស្ត៖ ឧក្រិដ្ឋកម្ម ភេរវកម្ម ការបង្ក្រាបមិនឲ្យងើបមុខរួច" បោះពុម្ពនៅរោងពុម្ពសាកលវិទ្យាល័យ ហារីដ ទីក្រុងខែមប្រ៊ីច ឆ្នាំ១៩៩៧ ទំព័រទី១៥ ។

វិធីសាស្ត្រអនុវត្តដោយ ឡេនីន រួចយកទៅធ្វើឲ្យសុក្រឹតដោយ ស្តាលីន ព្រមទាំងកូនចៅ ធ្វើឲ្យនឹកឃើញដល់វិធីសាស្ត្រប្រើប្រាស់ដោយពួកណាហ្ស៊ី ប៉ុន្តែជាញឹកញយ នេះគឺដោយសារពួកណាហ្ស៊ីប្រើប្រាស់បច្ចេកទេសរបស់ ឡេនីន ។ រូដុល ហេស ដែលទទួលបន្ទុករៀបចំចាត់ចែងជំរំអូស្វីត ហើយក្រោយមកតែងតាំងជាមេបញ្ជាការនៅជំរំនេះតែម្តង គឺជាឧទាហរណ៍ឥតខ្ចោះមួយបញ្ជាក់ពីបញ្ហានេះ ។ "ការិយាល័យសន្តិសុខកណ្តាលនៅរិច បានចេញបញ្ជាទៅមេបញ្ជាការនានាឲ្យប្រមូលរបាយការណ៍ដែលពាក់ព័ន្ធទៅនឹងជំរំប្រមូលផ្តុំរុស្ស៊ី ។ ប្រការទាំងនេះ រៀបរាប់ជាលម្អិតអំពីស្ថានភាពនៅក្នុងជំរំនិងការរៀបចំជំរំ ដូចដែលបានផ្តល់ដោយអតីតអ្នកទោសដែលមានវាសនាបានរួចផុតពីគុក ។ ការផ្តោតសំខាន់គឺទៅលើចំណុចដែលថាជនជាតិរុស្ស៊ីបានកម្ទេចប្រជាជាតិទាំងមូល តាមរយៈការបង្ខំឲ្យធ្វើការធ្ងន់ៗ" ។ ប៉ុន្តែការពិតដែលថាបច្ចេកទេសនៃអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំនិង (ប្រពលភាពអាំងតង់ស៊ីតេ) ដែលមានដើមកំណើតឡើងស្របជាមួយនឹងជនកុម្មុយនិស្ត ហើយបានជាពួកណាហ្ស៊ីត្រូវបានជំរុញដោយជនកុម្មុយនិស្ត បើតាមគំនិតយើងគឺមិនមានន័យថាមនុស្សម្នាក់អាចសន្និដ្ឋានថាជាការពិតបញ្ជាក់ពីទំនាក់ទំនងហេតុនិងបច្ច័យ (រវាងបដិវត្តន៍បុលសេវិក និង ការកើតឡើងនៃណាហ្ស៊ីនិយម ទេ) ។

ខ្ញុំមិនអាចជឿសាសនារ៉ូម៉ាំងកាតូលិក ជាងគណៈនិកាយរ៉ូម៉ាំងកាតូលិកនៃសាសនាគ្រិស្តបានទេ ។ សូមគិតថានេះជាអត្ថបទមួយដែល ឆាំង យុ បានស្នើឲ្យខ្ញុំសរសេរ (រិះគន់) ទៅលើអត្ថបទរបស់ អាឡិច ហ៊ីនតុន ដែលមានចំណងជើងថា "ភ្ជាក់ងារផ្តាច់ព្រលឹង" ។ សូមទទួលការគោរពដ៏កក់ក្តៅអំពីខ្ញុំ ។

**ឌិត ណាវ៉ាន់ គីរី**

**សាកលវិទ្យាល័យ ចន ហប់គីន**

## ពន្យល់ពាក្យខ្មែរក្រហម

- **អប់រំមនុស្ស៖** គឺការអប់រំកសាងសង្គមនិយម ។
- **ហិរញ្ញវត្ថុ៖** គឺខ្លួនឧបត្ថម្ភខ្លួនឯករាជ្យម្ចាស់ការហិរញ្ញវត្ថុបានមកពីកសិកម្មហើយត្រូវសន្សំសំចៃជាអតិបរមា ។

(កំណត់ហេតុលេខ ២០៩)

- **កម្មាជីវូបនីយកម្ម៖** គឺរស់នៅក្នុងការងារ ។
- **អត្តនោម័តិ៖** អនុម័តខ្លួនឯង ។
- **ឥទ្ធិពល៖** កម្លាំងដ៏ខ្លាំងក្លាឬមោះមុត ។

(កំណត់ហេតុ TSL N-97, N-11 លេខ ១០)

# អតីតកាលដែលកប់បាត់នៅក្នុងពេលវេលា


អឿ រតនា

នាងខ្ញុំកើតក្នុងឆ្នាំ១៩៨០ នៅទីក្រុងភ្នំពេញ ។ ទសវត្សរ៍ឆ្នាំ១៩៨០គឺសម័យកាលដែលប្រទេសកម្ពុជាបានរួចចាកផុតពីរបបខ្មែរក្រហមទៅហើយ ដូច្នេះខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែក និងមិនបានរស់នៅឆ្លងកាត់ការលំបាកវេទនាដូចដែលក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនកម្ពុជាទាំងអស់បានជួបប្រទះអស់រយៈពេលបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនោះទេ ។ ក្នុងចំណោមសមាជិកគ្រួសារខ្ញុំទាំងអស់ដែលមានគ្នាប្រាំនាក់មានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលមិនបានឆ្លងកាត់ការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាខ្ញុំមិនបានរស់នៅក្នុងរបបខ្មែរក្រហមក៏ពិតមែន ប៉ុន្តែតាមរយៈការនិទានជាញឹកញាប់របស់ឪពុកម្តាយនិងបងប្រុសរបស់ខ្ញុំ ធ្វើឲ្យខ្ញុំអាចដឹងនិងចងចាំនូវរឿងរ៉ាវដែលទាក់ទងនឹងរបបនេះបានខ្លះៗ ជាពិសេសគឺរឿងរ៉ាវរបស់គ្រួសារខ្ញុំផ្ទាល់ ។

មិនត្រឹមតែតាមរយៈក្រុមគ្រួសាររបស់ខ្ញុំប៉ុណ្ណោះទេ សូម្បីតែនៅសាលារៀនក៏ខ្ញុំបានសិក្សាអំពីរបបខ្មែរក្រហមដែរ ។ ពេលខ្ញុំរៀននៅថ្នាក់ទី៥ នៃសាលាបឋមសិក្សា ខ្ញុំបានសិក្សាមេរៀនអំពីរបបប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី, ខៀវ សំផន ។ ខ្លឹមសារមេរៀនរៀបរាប់អំពីការជម្លៀសប្រជាជនចេញពីលំនៅឋាន ឲ្យទៅរស់នៅរួមគ្នាតាមទីជនបទ បង្ខំឲ្យធ្វើការហួសកម្លាំង មិនឲ្យរបបអាហារបរិភោគគ្រប់គ្រាន់ រួមទាំងការសម្លាប់រង្គាល និងការធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃគ្រប់បែបយ៉ាង ។ មិនតែប៉ុណ្ណោះ មេរៀនក៏បង្ហាញរូបគំនូរអំពីសកម្មភាពទាំងនេះដែរ ។ ខ្ញុំអាចមើលស្គាល់ភ្លាមថារូបមួយណាជាកងទ័ពខ្មែរក្រហម កាលណាខ្ញុំឃើញរូបកងទ័ពស្លៀកពាក់ខោអាវពណ៌ខ្មៅ មានបង់កក្រមា ពាក់ស្បែកជើងកង់ឡានពណ៌ខ្មៅ មានទឹកមុខកាចសាហាវ ខុសពីប្រជាជនធម្មតាដែលមានសម្លៀកបំពាក់ពណ៌ខ្មៅដែរ ប៉ុន្តែជាសម្លៀកបំពាក់កញ្ចាស់និងរហែក ហើយមានទឹកមុខភ័យខ្លាចនិងរាងកាយស្គមស្គាំង ។ ពេលនោះខ្ញុំមិនមានការឈឺចាប់ឬចងគំនុំឡើយ ។ ខ្ញុំគ្រាន់តែគិតថា វាគឺជារឿងរ៉ាវដែលបានកន្លងហួសទៅហើយ គេគ្រាន់តែលើកយកមកបង្រៀនឲ្យយើងបានដឹងតែប៉ុណ្ណោះ ។

នាយប់មួយកាលពីខ្ញុំអាយុ១៥ឆ្នាំ ក្រុមគ្រួសារខ្ញុំជួបជុំគ្នាមើលខ្សែភាពយន្តរឿង «វាលពិឃាត» ដែលបញ្ចាំងតាមកញ្ចក់ទូរទស្សន៍ ។ «វាលពិឃាត» គឺជាខ្សែភាពយន្តដែលឆ្លុះបញ្ចាំងអំពីសោកនាដកម្មនៃសង្គមខ្មែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដំណើររឿងវាលពិឃាតបាននាំឲ្យឪពុកម្តាយខ្ញុំរំឭកឡើងវិញនូវដំណើររឿងនៃការជម្លៀសក្រុមគ្រួសាររបស់ខ្ញុំ ។

...មុនឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្បែរផ្សារពោធិ៍ចិនតុង ។ នៅដើមឆ្នាំ១៩៧៥ ដោយសារតែមានគ្រាប់ផ្លោងចូលព្រលានយន្តហោះច្រើនពេក ក្រុមគ្រួសារខ្ញុំនិងបងប្អូនខាងម្តាយខ្ញុំប្រាំមួយនាក់ទៀតដែលបានរត់មកពីខេត្តកំពង់ចាម នាំគ្នារត់មកស្នាក់នៅផ្ទះអ៊ំប្រុសខាងម្តាយខ្ញុំឋិតនៅក្បែរសាលារៀនសន្ធរម៉ុក ។ ស្ថានភាពក្នុងទីក្រុងភ្នំពេញនាពេលនោះមានភាពជ្រួលច្របល់ ឮតែសូរកាំភ្លើងនិងគ្រាប់ផ្លោងមិនដាច់សូរ ។

ព្រឹកថ្ងៃទី១៧ ខែមេសា តាំងពីមេឃមិនទាន់ភ្លឺច្បាស់ម៉្លេះ ស្នូរបាញ់ផ្លោងដាក់គ្នាទៅវិញទៅមករវាងកងទ័ពខ្មែរក្រហមនិងទាហាន លន់ ណុល លាន់ឮកាន់តែខ្លាំងឡើងៗនិងជិតឡើងៗ ។ ប្រជាជនដែលរស់នៅជាយក្រុងនិងក្នុងក្រុងជ្រួលច្របល់នាំគ្នារៀបចំអីវ៉ាន់គេចចេញពីផ្ទះ ទៅរកកន្លែងដែលមានសុវត្ថិភាព ។ ទាហាន លន់ ណុល រត់ប្រសេចប្រសាចមកពីទិសខាងលិចលាយឡំជាមួយនឹងហ្វូងមនុស្សដែលកំពុងតែរត់ឆ្វេឆ្វាទៅមកៗតាមដងផ្លូវ មានទាំងអីវ៉ាន់សំពីងសំពោងជាប់មកជាមួយផង ។



អឿ រតនា និងក្រុមគ្រួសារ ក្នុងឆ្នាំ១៩៨៣

ឃើញហេតុការណ៍ដូច្នោះ និងដោយភ័យខ្លាចគ្រាប់ផ្លោងធ្លាក់ចំផង ឪពុកម្តាយរបស់ខ្ញុំក៏សម្រេចចិត្តរៀបចំអីវ៉ាន់ ភៀសខ្លួនមកស្នាក់នៅផ្ទះអ៊ំប្រុសរបស់ប៉ាខ្ញុំដែលនៅក្បែរវាលមេរុ ព្រោះគិតថានៅទីនោះមានសុវត្ថិភាពជាងនេះ ហើយបានជួបជុំបងប្អូនផង ។ នៅតាមផ្លូវ មនុស្សជាច្រើនកំពុងរត់គេចពីកន្លែងគ្រោះថ្នាក់ដូចជាយើងដែរ ។ ចរាចរណ៍កកស្ទះស្ទើរតែគ្រប់ទីកន្លែង ។ ផ្លូវជាច្រើនត្រូវបានបិទចរាចរណ៍ អ្នកធ្វើដំណើរទាំងអស់ត្រូវវាងទៅតាមផ្លូវផ្សេងទៀតដែលអាចទៅរួច ។ ទម្រាំតែទៅដល់វាលមេរុ ក្រុមគ្រួសាររបស់ខ្ញុំត្រូវចំណាយពេលអស់ជាច្រើនម៉ោង ។ នៅតាមផ្លូវមានសាកសពប្រជាជននិងទាហានដេកស្លាប់នៅកន្លែងនេះខ្លះកន្លែងនោះខ្លះ ។

មកដល់ផ្ទះនៅវាលមេរុបានបន្តិច ក៏មានសេចក្តីប្រកាសតាមវិទ្យុថា "ឥឡូវនេះសង្គ្រាមបានចប់ហើយ សូមបងប្អូនរក្សាភាពស្ងៀមស្ងាត់ ពេលនេះយើងមានសន្តិភាពហើយ កងទ័ពរំដោះនិងទាហាន លន់ ណុល បានចូលមកចាប់ដៃគ្នាហើយ..." ។

បន្ទាប់ពីនោះ ប្រព័ន្ធផ្សព្វផ្សាយនិងប្រព័ន្ធទូរស័ព្ទត្រូវបានកាត់ផ្តាច់ ។ ឪពុករបស់ខ្ញុំបានយកក្រណាត់សមកចងនៅពីមុខរថយន្ត រួចហើយគាត់និងលោកតារបស់ខ្ញុំបានបើករថយន្តទៅផ្ទះមិត្តភក្តិរបស់គាត់នៅម្តុំចំការមន ក្នុងគោលបំណងសួរពីសភាពការណ៍ ។ ឪពុកខ្ញុំបានប្រាប់ថា នៅតាមផ្លូវមិនឃើញទាហាន លន់ ណុល រត់ប្រសេចប្រសាចដូចមុនទៀតទេ គាត់ឃើញតែកងទ័ពខ្មែរក្រហមដែលមានសម្លៀកបំពាក់ពណ៌ខ្មៅ និងមានស្ពាយកាំភ្លើងវែងនៅលើស្មា កំពុងដើរព្រោងព្រាត ។ កងទ័ពខ្លះកាន់កាំភ្លើងភ្ជង់ប្រជាជនឲ្យធ្វើដំណើរទៅតាមផ្លូវដែលគេប្រាប់ ។ នៅតាមផ្លូវ កងទ័ពខ្មែរក្រហមបានដណ្តើមយកឡានម៉ូតូរបស់ប្រជាជនស្រេចតែអំពើចិត្ត ។ ឪពុកខ្ញុំនិងលោកតាត្រូវកងទ័ពខ្មែរក្រហមពីរបីនាក់ភ្ជង់កាំភ្លើងគំរាមមិនឲ្យបត់រថយន្តចូលផ្ទះមិត្តរបស់គាត់ទេ ហើយបញ្ជាឲ្យបើកសំដៅទៅក្បាលថ្នល់វិញ ទោះបីជាឪពុកខ្ញុំសុំត្រឡប់មកផ្ទះវិញដើម្បីយកក្រុមគ្រួសារទៅជាមួយ ក៏ខ្មែរក្រហមមិនយល់ព្រមដែរ ។ សំណាងល្អពេលបើករថយន្តទៅមុខបានបន្តិច ឪពុករបស់ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមពីរបីនាក់ទៀតដែលកំពុងត្រូវការសាំងដើម្បីចាក់

រថយន្ត ។ ដោយចង់ត្រឡប់មកផ្ទះវិញ ឪពុកខ្ញុំបានប្រាប់កងទ័ពខ្មែរក្រហមថា «បើបងៗត្រូវការសាំង សូមទៅយកនៅផ្ទះខ្ញុំចុះ ខ្ញុំមានសាំងច្រើនទុកនៅផ្ទះ» ។ ឮដូច្នោះ ខ្មែរក្រហមពីរនាក់បានឡើងមកជិះលើដំបូលរថយន្តរបស់គាត់ ដើម្បីតាមមកយកសាំងនៅផ្ទះ ដូច្នេះឪពុកខ្ញុំក៏បានត្រឡប់មកផ្ទះវិញ ។ ពេលដែលយកសាំងបានហើយ ស្រាប់តែខ្មែរក្រហមពីរនាក់នោះបានបង្ខំឲ្យអ្នកនៅក្នុងផ្ទះទាំងអស់រៀបចំអីវ៉ាន់ចាកចេញពីផ្ទះដោយប្រាប់ថា «ពេលនេះកងទ័ពយើងត្រូវការបោសសម្អាតខ្មាំងដែលលាក់ខ្លួនក្នុងទីក្រុង ដូច្នេះបងប្អូនត្រូវចាកចេញពីទីក្រុងពីរ-បីថ្ងៃសិន ហើយមិនចាំបាច់យកអីវ៉ាន់អីទៅច្រើនទេ ព្រោះបងប្អូនចេញទៅតែពីរបីថ្ងៃប៉ុណ្ណោះ» ។ ឪពុកខ្ញុំប្រាប់ថា គ្មាននរណាម្នាក់ហ៊ានប្រកែកនឹងបញ្ហានេះទេ ព្រោះកងទ័ពអាវខ្មៅទាំងនោះមើលទៅគួរឲ្យខ្លាចណាស់ ។ ម្យ៉ាងគាត់គិតថា ប្រហែលជាកងទ័ពរំដោះត្រូវការរុករកខ្មាំងពិតមែន ពេលណាដែលគេបោសសម្អាតខ្មាំងរួច យើងគង់តែបានត្រឡប់មកផ្ទះវិញមិនខាន ។ លោកយាយប្រាប់ថា «មិនចាំបាច់រៀបចំអីវ៉ាន់អីច្រើនទេ ព្រោះយើងនឹងទៅនៅផ្ទះមួយទៀតដែលនៅក្បែរចំការមន ។ នៅទីនោះប្រហែលជាមិនអីទេ គេប្រហែលជាបោសសម្អាតតែនៅក្បែរៗវាំងហ្នឹង» ។ ក្រុមគ្រួសារយើងដែលមានសមាជិកដប់ប្រាំពីរនាក់ក៏ចេញដំណើរទៅជាមួយរថយន្តពីរគ្រឿង ចំណែកកងទ័ពខ្មែរក្រហមដែលមកយកសាំងនោះ បានឡើងទៅជិះលើដំបូលរថយន្តទៅជាមួយដែរ ដើម្បីត្រឡប់ទៅគោលដៅចាស់វិញ ។

ក្រុមគ្រួសារខ្ញុំចេញពីផ្ទះមកដល់ផ្លូវនរោត្តម ម៉ោងប្រមាណប្រាំពីរយប់ទៅហើយ ប៉ុន្តែចរាចរណ៍កាន់តែស្ទះខ្លាំងឡើងៗ ។ មនុស្សធ្វើដំណើរបន្តកន្ទុយគ្នាចេញមកពីគ្រប់ទិសទី ។ អ្នកខ្លះមានយានជំនិះសម្រាប់ជិះនិងដឹកអីវ៉ាន់ ចំណែកអ្នកដែលគ្មានយានជំនិះ ត្រូវដើរដោយមានកាន់អីវ៉ាន់សំពីង សំពោង ខ្លះយួរ ខ្លះរែក ខ្លះលី ខ្លះសែង ខ្លះទូល ខ្លះដាក់រទេះអូស ចំណែកគ្រួសារខ្លះដែលមានអ្នកជំងឺឬមនុស្សចាស់រួមដំណើរមកជាមួយត្រូវបានបងប្អូនដាក់រទេះរុញឬអៀវ ឬជួយគ្រាហ៍ ដោយផ្លាស់ប្តូរគ្នាម្តងម្នាក់ៗ ។

មកដល់ចំការមន កងទ័ពខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងចូលក្នុងផ្ទះដូចដែលលោកយាយបានគិតទុកទេ គឺឲ្យយើងធ្វើដំណើរទៅមុខទៀតតម្រង់ទៅក្បាលថ្នល់ ។ មកដល់ក្បាលថ្នល់ កងទ័ពខ្មែរក្រហមបានប្រកាសតាមមេក្រូឲ្យប្រជាជនចូលទៅយកអង្ករនៅក្នុងឃ្លាំងអង្ករមួយដែលនៅក្បែរនោះ ។ ឪពុកនិងពូរបស់ខ្ញុំបានចូលទៅយកអង្ករបានពីរការ៉ុង ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងអស់ឆ្លងស្ពានមុនីវង្សឆ្ពោះទៅផ្លូវជាតិលេខ១វិញ ព្រោះតាមផ្លូវទៅតាខ្មៅមានមនុស្សទៅច្រើនពេក ចរាចរស្ទះណែនទៅហើយ ។ ឪពុកម្តាយខ្ញុំមិនចង់ឆ្លងស្ពានទេ ព្រោះនៅត្រើយម្ខាងភ្លើងកំពុងតែឆាបឆេះផ្ទះថ្មមួយជួរយ៉ាងសន្ធោសន្ធៅ ។ នៅលើស្ពាន មនុស្សដើរប្រជ្រៀតគ្នាយ៉ាងណែនណាន់តាន់តាប់ ។ ម្តាយខ្ញុំនិយាយថា ពេលនោះមិនចាំបាច់ដើរទេ គ្រាន់តែរុញគ្នាទៅវិញទៅមកក៏រំកិលទៅមុខដោយខ្លួនឯងដែរ ។ ដោយសារតែមានមនុស្សធ្វើដំណើរច្រើនពេក ទម្រាំតែឆ្លងស្ពានរួចយើងត្រូវចំណាយពេលអស់រាប់ម៉ោង ។

ម៉ោងប្រមាណ១១យប់ទៅហើយទើបយើងឆ្លងផុតស្ពានព្រះមុនីវង្ស ។ ប្រជាជនដែលត្រូវជម្លៀសចេញពីក្រុងភ្នំពេញនិងពីតំបន់ផ្សេងៗទៀត បានមកដល់ច្បារអំពៅកាន់តែច្រើនឡើងៗ អ្នកខ្លះឈប់សម្រាកនៅទីនេះ អ្នកខ្លះទៀតក៏បន្តដំណើរទៅមុខទៀត ។ ក្រុមគ្រួសាររបស់ខ្ញុំសម្រេចចិត្តថាមិនធ្វើដំណើរទៅមុខទៀតទេ សុខចិត្តទ្រាំសម្រាកនៅច្បារអំពៅរង់ចាំការហៅត្រឡប់ចូលក្រុងវិញ ។ ក្រុមគ្រួសារខ្ញុំសម្រាកក្នុងផ្ទះទំនេរមួយដែលម្ចាស់ផ្ទះត្រូវកងទ័ពខ្មែរក្រហមជម្លៀសចេញទៅតាំងពីមុនពេលដែលយើងមកដល់ទីនេះម្ល៉េះ ។

ម្នាក់ៗនៅតែសង្ឃឹមថានឹងអាចចូលភ្នំពេញវិញក្នុងពេលឆាប់ៗខាងមុខ ។ ពេលនោះក្រដាសប្រាក់នៅតែចាយនៅឡើយ ប៉ុន្តែវាមិនសូវមានតម្លៃប៉ុន្មានទេ ។ របស់របរឡើងថ្លៃទាំងអស់ ជាពិសេសគឺម្ហូបអាហារ ។

ស្នាក់នៅច្បារអំពៅបានបីថ្ងៃ បងប្អូនរបស់លោកតាខ្ញុំដែលរស់នៅដីឥដ្ឋបានមកទទួលលោកតាខ្ញុំឲ្យទៅរស់នៅជាមួយ ព្រោះនៅទីនោះមានកន្លែងរស់នៅសមរម្យ និងងាយស្រួលរក

ម្ហូបអាហារជាងនៅទីនេះ ។ ទាំងអស់គ្នាក៏សម្រេចចិត្តទៅរស់នៅជីឥដ្ឋតាមលោកតាខ្ញុំដែរ ។

ពេលមកដល់ជីឥដ្ឋ គ្រួសារខ្ញុំនិងគ្រួសារលោកតាខ្ញុំបានរស់នៅផ្ទះផ្សេងៗគ្នា តាមដែលបងប្អូនលោកតារៀបចំឲ្យ ។ មួយថ្ងៃៗ ម្នាក់ៗនាំគ្នាចេញទៅរកម្ហូបអាហារ រកអុស រកទឹករៀងៗខ្លួន អ្នកណាមានសមត្ថភាពរកបានអីទៅរកហ្នឹង ហើយឆ្លៀតដើរសុើបសួរពីសភាពការណ៍ និងរកមើលក្រែងបានជួបនឹងបងប្អូនឬអ្នកដែលធ្លាប់ស្គាល់គ្នា ។ ការចាយប្រាក់កាន់តែមានការលំបាក ព្រោះវាកាន់តែថោកទៅៗ ។ ពេលនេះម្នាក់ៗលែងចង់បានប្រាក់ទៀតហើយ គ្រប់គ្នាចង់បានតែរបស់របរចាំបាច់ប៉ុណ្ណោះ ដូចជាខោអាវ អង្ករ អំបិល ។ ក្រោយពីនោះបន្តិច ការចាយប្រាក់ត្រូវបានបញ្ឈប់ ។ នៅជីឥដ្ឋ ខ្មែរក្រហមបានបើកអង្ករឲ្យប្រជាជនបន្តិចបន្តួចដែរ ។ កងទ័ពខ្មែរក្រហមបានដើរប្រកាសប្រាប់តាមមេក្រូឲ្យអ្នកដែលធ្លាប់ធ្វើជាទាហានពីមុនៗ សូមឲ្យទៅចុះឈ្មោះនៅវត្តជីឥដ្ឋដើម្បីចូលធ្វើការវិញ ។ ឪពុកខ្ញុំបានប្រាប់ថា នេះគ្រាន់តែជាលេសរបស់ខ្មែរក្រហមដើម្បីចាប់ទាហាន លន់ ណុល និងអ្នកដែលធ្វើការធំៗ យកទៅសម្លាប់ចោលតែប៉ុណ្ណោះ ។ នៅផ្ទះរបស់ឪពុកម្តាយខ្ញុំតែងមានកងទ័ពខ្មែរក្រហមចុះមកសាកសួរអំពីបញ្ហាមួយចំនួនដែរ ភាគច្រើនសួរពីឈ្មោះ មុខរបរ និងប្រាក់ខែ ប៉ុន្តែឪពុកខ្ញុំបានប្រាប់មនុស្សក្នុងផ្ទះថា ពេលដែលគេមកសួរអីកុំឆ្លើយឲ្យសោះ ចាំគាត់ត្រឡប់មកវិញសឹមគាត់ជាអ្នកឆ្លើយ ។

រស់នៅជីឥដ្ឋបានប្រមាណមួយខែ ដោយគិតថាប្រហែលមិនអាចត្រឡប់មកទីក្រុងភ្នំពេញវិញបាន ក្រុមគ្រួសារខ្ញុំក៏សម្រេចចិត្តទៅរស់នៅឯស្រុកកំណើតវិញ ។ ឪពុកម្តាយខ្ញុំដែលមានគ្នា៩នាក់ បានធ្វើដំណើរទៅខេត្តកំពង់ចាម ហើយគ្រួសារអ៊ំប្រុសរបស់ឪពុកខ្ញុំដែលមានគ្នា៨នាក់ ធ្វើដំណើរទៅខេត្តបាត់ដំបង ។

ឪពុកម្តាយខ្ញុំចង់ចេញដំណើរឲ្យបានឆាប់បំផុត ព្រោះគាត់ដឹងថា មិនយូរមិនឆាប់ ខ្មែរក្រហមនឹងចាប់បញ្ជូនមនុស្សទៅដាក់នៅកន្លែងណាដែលគេចង់ឲ្យយើងទៅ មិនមែនអនុញ្ញាតឲ្យយើងទៅតាមចិត្ត ដែលយើងចង់ទៅដូចពេលនេះទេ ។ ក្រុមគ្រួសារខ្ញុំរួមទាំងបងប្អូនខាងម្តាយខ្ញុំទាំងអស់ត្រូវដើរត្រឡប់មកជិះកាណូតនៅជ្រោយអំពិល ដើម្បីធ្វើដំណើរទៅខេត្តកំពង់ចាម ។ ធ្វើដំណើរទៅដល់ទន្លេបិទ ខ្មែរក្រហមមិនបានអនុញ្ញាតឲ្យក្រុមគ្រួសារខ្ញុំបន្តដំណើរទៅភូមិដែលយើងចង់ទៅទេ ផ្ទុយទៅវិញ កងទ័ពខ្មែរក្រហមបានដឹកយើងយកទៅដាក់ឲ្យរស់នៅក្នុងភូមិគោកស្រឡៅ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។ រស់នៅទីនោះបានប្រមាណពីរបីខែ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំឲ្យទៅនៅភូមិត្រពាំងជ្រៃវិញ ព្រោះនៅភូមិគោកស្រឡៅនេះ ប្រជាជនថ្មីជាច្រើននាក់ស្លាប់ដោយសារជំងឺឆ្លង ។

ក្រុមគ្រួសាររបស់ខ្ញុំត្រូវបន្តរស់នៅក្នុងសភាពលំបាកលំបិនអស់រយៈពេលជាងបីឆ្នាំទៀត ដោយត្រូវជម្លៀសពីភូមិមួយទៅភូមិមួយជាបន្តបន្ទាប់ ។ ពេលថ្ងៃត្រូវទៅធ្វើការនៅវាលស្រែឬចម្ការឬនៅក្នុងព្រៃឆ្ងាយៗបែកពីគ្រួសារ ដោយទទួលបានរបបហូបចុកមិនគ្រប់គ្រាន់ ។ ពេលយប់ត្រូវដេកទាំងភាពភ័យខ្លាច ព្រោះខ្មែរក្រហមច្រើនតែមកហៅមនុស្សយកទៅសម្លាប់នៅពេលយប់ ។...

ក្រោយពីឆ្លងកាត់របប ប៉ុល ពត បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំដែលចេញពីភ្នំពេញទៅជាមួយគ្នាទាំង៩នាក់ មានសំណាងនៅរស់ទាំងអស់គ្នា ហើយថែមទាំងទទួលបានសមាជិកម្នាក់ទៀត គឺបងប្រុសរបស់ខ្ញុំដែលកើតនៅឆ្នាំ១៩៧៧ នៅក្នុងភូមិត្រពាំងជ្រៃ ឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។ ចំណែកគ្រួសារអ៊ំប្រុសរបស់ឪពុកខ្ញុំដែលមានគ្នា៨នាក់នោះ នៅរស់តែបួននាក់ប៉ុណ្ណោះ ។ លោកតានិងកូនប្រុសរបស់គាត់បីនាក់ទៀតត្រូវស្លាប់បន្តបន្ទាប់គ្នា ដោយសារកងទ័ពខ្មែរក្រហមយកទៅសម្លាប់ ដោយសារជំងឺ និងដោយសារការអត់ឃ្លាន ។

ទោះបីជារបប ប៉ុល ពត មិនបានសម្លាប់សមាជិកក្នុងគ្រួសារខ្ញុំនិងបងប្អូនដែលបានចេញទៅជាមួយគ្នាក៏ដោយ ក៏ប៉ុន្តែមានបងប្អូនបង្កើត បងប្អូនជីដូនមួយ ជីទួតមួយ ទាំងខាងឪពុកទាំងខាងម្តាយ ជាច្រើននាក់ បានស្លាប់នៅក្នុងរបបនេះ ។

ឥឡូវនេះខ្ញុំមានការយល់ដឹងកាន់តែច្រើនអំពីរបបខ្មែរក្រហមតាមរយៈការអានឯកសារនិងការផ្សាយប្រចាំថ្ងៃរបស់ខ្ញុំ ។ ខ្ញុំបានដឹងអំពីដំណើរជីវិតរបស់ក្រុមគ្រួសារផ្សេងៗទៀត ដែលបានឆ្លងកាត់របបខ្មែរក្រហមដែរ ដូចជាដំណើរជីវិតក្រុមគ្រួសាររបស់ លឿង អ៊ឹង ដែលត្រូវបានចងក្រងជាសៀវភៅមានចំណងជើងថាៈ «ដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ» ដែលឆ្លុះបញ្ចាំងឲ្យឃើញពីភាពវេទនានិងការបាត់បង់សមាជិកគ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត តាមរយៈការអានសៀវភៅកំណត់ហេតុរបស់ក្មេងស្រីជនជាតិជ្វីហ្វម្នាក់ឈ្មោះ «អាន់ ហ្វ្រែង» ធ្វើឲ្យខ្ញុំបានដឹងថា អំពើប្រល័យពូជសាសន៍មិនមែនកើតមានតែនៅលើទឹកដីកម្ពុជាប៉ុណ្ណោះទេ គឺវាបានកើតឡើងនៅកន្លែងផ្សេងៗទៀតនៅលើពិភពលោកយើងនេះ ។

រហូតមកដល់ពេលនេះ ខ្ញុំមិនសូវបានឮឪពុកម្តាយរបស់ខ្ញុំនិយាយពីរឿងខ្មែរក្រហមទៀតទេ ។ ខ្ញុំគិតថា នេះប្រហែលមកពីពេលវេលាចេះតែរំកិលទៅមុខកាន់តែយូរទៅៗ ដែលធ្វើឲ្យគាត់គិតថាវាច្រំដែលពេកក្នុងការនិយាយរឿងរ៉ាវនេះឡើងវិញជាច្រើនលើកច្រើនសា ។ ម្យ៉ាងទៀត ដោយសារសង្គមបច្ចុប្បន្នមិនមានការយកចិត្តទុកដាក់នឹងរឿងនេះ ក៏ដូចជាមិនទាន់ឃើញមានការធ្វើអ្វីមួយដែលទាក់ទងនឹងរបបខ្មែរក្រហម ដូចជាការដាក់ខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើមកលើប្រជាជនខ្មែរជាដើម ទើបមិនសូវមានការរំឭកពីរឿងនេះឡើងវិញ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ខ្ញុំជឿជាក់ថា ការឈឺចាប់និងរឿងរ៉ាវទាំងឡាយដែលប្រជាជនខ្មែរបានជួបប្រទះដោយផ្ទាល់កាលពីសម័យនោះ ពិតជាមិនអាចបំភ្លេចបានឡើយ ។ ទោះជាពេលនេះគាត់មិននិយាយចេញមកក៏ដោយ ប៉ុន្តែប្រសិនបើដល់ពេលណាមួយនោះដែលគាត់ត្រូវនិយាយ ដូចជានៅពេលដែលការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គាត់ពិតជាអាចរៀបរាប់បានទាំងអស់នូវអ្វីដែលបានកប់ទុកនៅក្នុងចិត្តរបស់គាត់អស់រយៈពេលជាងម្ភៃឆ្នាំមកហើយ ។

**អឿ រតនា**

# សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

**ការសរសេរអត្ថបទនេះមានសារសំខាន់៥យ៉ាងគឺ**

◆ ចូលរួមជាចំណែកមួយនៃប្រវត្តិសាស្ត្រ ទុកសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជួយដល់ក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យនោះ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ ដោយយកសេចក្តីទុក្ខការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រ ដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពីប្រល័យពូជសាសន៍កើតឡើងបានជាថ្មីម្តងទៀតក្នុងសង្គមមនុស្ស ។

◆ ជួយលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស (សិទ្ធិរស់រានមានជីវិត) នៅក្នុងពេលបច្ចុប្បន្ននិងថ្ងៃអនាគត ។

មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចុះផ្សាយអត្ថបទទាំងនោះនៅលើទំព័រទស្សនាវដ្តី ឬបោះពុម្ពជាសៀវភៅ ក្នុងករណីបានទទួលការអនុញ្ញាតពីសាមីខ្លួន ។

សូមអរគុណ ។

# ម្ដាយខ្ញុំប្រាប់អំពីការពិត

នៅពេលទំនេរ ឬនៅពេលមានពិធីបុណ្យទានផ្សេងៗ ក្រុមគ្រួសាររបស់ខ្ញុំតែងតែជួបជុំគ្នានិយាយរឿងផ្សេងៗពីអតីតកាល ។ ពេលដែលខ្ញុំធំដឹងក្ដីឡើង ខ្ញុំចាំសម្ដីដែលម៉ាក់ធ្លាប់និយាយមកកាន់ខ្ញុំជារឿយៗថា «កូនឯងសំណាងណាស់ ពីព្រោះមិនបានឆ្លងកាត់របបខ្មែរក្រហម» ។

ឆ្នាំ១៩៨០ ជាឆ្នាំដែលខ្ញុំ បានចាប់កំណើត បន្ទាប់ពីប៉ាម៉ាក់របស់ខ្ញុំនិងក្រុមគ្រួសារបានធ្វើដំណើរដោយថ្មើរជើងកាត់ព្រៃភ្នំអស់រយៈពេលពីរសប្ដាហ៍ចេញពីខេត្តព្រះវិហារត្រឡប់មកទីក្រុងភ្នំពេញវិញ ។ នៅក្នុងអំឡុងពេលនៃការធ្វើដំណើរនោះ ម៉ាក់របស់ខ្ញុំកំពុងតែមានគភ៌ ។

ប៉ាម៉ាក់របស់ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៧៨ តាមបែបបទរបស់បដិវត្តន៍ខ្មែរក្រហម ដែលមានអង្គការជាឪពុកម្ដាយ ។ កាលនោះ ប្រធានភូមិម្នាក់ឈ្មោះ ង៉ុយ បានប្រាប់ប៉ារបស់ខ្ញុំឲ្យស្នើនារីម្នាក់ដើម្បីរៀបការ ។ នៅព្រលប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៨ ប៉ាម៉ាក់របស់ខ្ញុំបានចូលរួមពិធីរៀបការ ។ មុនពេលពិធីចាប់ផ្ដើម ប៉ាបានសួរប្រធានភូមិថា «តើគេឲ្យអង្គុយផ្ទឹមឬក៏អត់?» ។ ប្រធានភូមិរូបនោះឆ្លើយថា«អត់ផ្ទឹមទេ ឥឡូវគេកាត់អស់ហើយ អ្នកណាចង់អង្គុយត្រង់ណាក៏ស្រេចតែចិត្ត» ។ ប៉ាម៉ាក់របស់ខ្ញុំពុំធ្លាប់ស្គាល់គ្នាពីមុនមកទេ ។ ពិធីរៀបការនោះចូលរួមដោយយុវជន-យុវនារីចំនួន៨គូ ប្រធានភូមិនិងប្រធានសេដ្ឋកិច្ច ។ ប៉ាម៉ាក់របស់ខ្ញុំស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅដែលសហករណ៍បានបើកឲ្យកាលពីមួយឆ្នាំមុនៗ មានតែចង្កៀងប្រេងកាតមួយប៉ុណ្ណោះដែលអុជបំភ្លឺក្នុងពិធីទាំងមូល ។ ពិធីបានចាប់ផ្ដើម សមមិត្ត សុង ប្រធានសង្កាត់នៅភូមិរស្មីរំដោះ ស្រុកតាំងគោក ខេត្តកំពង់ធំ បានឡើងមានមតិថា «បដិវត្តន៍យើងមិនដូចពីដើមទេ កាលពីជំនាន់ដើម ពេលរៀបការត្រូវតុបតែងខ្លួនស្អាត ពេលរៀបការរួចមានអ្នកខ្លះជំពាក់គេក៏មាន» ។ បន្ទាប់មកមានតំណាងយុវជនម្នាក់បានឡើងប្ដេជ្ញា រួចហើយប្រធានភូមិឈ្មោះ ង៉ុយ បានហៅប៉ាម៉ាក់របស់ខ្ញុំឡើងប្ដេជ្ញាថា «ព្រមទទួលយកគ្នាជាប្ដីប្រពន្ធ និងរស់នៅជាមួយគ្នាជារៀងរហូត» ។ ក្រោយពីរៀបការរួច ខ្មែរក្រហមមិនអនុញ្ញាតប៉ាម៉ាក់របស់ខ្ញុំរស់នៅ


ប៉ាំង ពីរីន ជាមួយឪពុកម្ដាយនិងជីដូន ក្នុងឆ្នាំ១៩៨២

ជាមួយគ្នាទេ ។ ប្រធានសហករណ៍តម្រូវឲ្យប៉ារបស់ខ្ញុំទៅធ្វើចម្ការឆ្ងាយពីភូមិ ។ ចំណែកឯម៉ាក់របស់ខ្ញុំធ្វើស្រែនៅក្នុងភូមិ ។ ១០ថ្ងៃម្តង ទើបប៉ាបានមកលេងផ្ទះចំនួនមួយថ្ងៃ ។ ពេលខ្លះប៉ាមិនបានមកទេ ពីព្រោះចម្ការនៅឆ្ងាយពេក ។

មានពេលមួយ តាំងពីមុនពេលដែលម៉ាក់រៀបការជាមួយប៉ា ឈ្លបបានមកហៅម៉ាក់និងមីងទៅរៀនសូត្រ ។ ពេលនោះមីងរបស់ខ្ញុំដេកឈឺនៅមន្ទីរពេទ្យភូមិ មិនអាចទៅបាន ឈ្លបសម្លុតមីងខ្ញុំថា «ទោះបីឈឺក៏យកអង្រឹងមកសែងដែរ» ។ ដោយយាយរបស់ខ្ញុំអង្វរករខ្លាំង ទើបឈ្លបមិនយកមីងរបស់ខ្ញុំទៅវិញ ហើយយកតែម៉ាក់ទៅតែម្នាក់ឯង ។ ឈ្លបចោទប្រកាន់ម៉ាក់ខ្ញុំថា «ធ្លាប់ធ្វើការនៅស្ថានទូតរបស់បារាំង» ចំណែកមីងរបស់ខ្ញុំ ឈ្លបចោទប្រកាន់គាត់ថា«ជាបញ្ញវន្ត» ។ តាមការពិតម៉ាក់របស់ខ្ញុំមិនបានធ្វើការនៅស្ថានទូតបារាំងទេ ។ ម៉ាក់ភ័យខ្លាចខ្លាំងណាស់ ។ គាត់ដឹងថាគាត់ពិតជាមិនមានជីវិតរស់ឡើយ ដោយសារមានអ្នកនៅក្នុងក្រុមរបស់គាត់ត្រូវឈ្លបយកទៅសម្លាប់ចោលដោយប្រាប់ថាយកទៅរៀនសូត្រ ។ ម៉ាក់របស់ខ្ញុំមិនស្លាប់ទេ ព្រោះនៅថ្ងៃនោះ ឈ្លបទើបតែហៅឈ្មោះចប់ស្រាប់តែមាននីរសាម្នាក់យកសំបុត្រមួយមកប្រាប់ថា «ផែនការត្រូវផ្អាកសិន» ។ ម៉ាក់របស់ខ្ញុំក៏បានរួចជីវិតតាំងពីពេលនោះមករហូតដល់សព្វថ្ងៃ ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាពលរដ្ឋខ្មែរបានវិលត្រឡប់មកកាន់លំនៅឋានរៀងៗខ្លួន ។ ក្រុមគ្រួសាររបស់ខ្ញុំបានធ្វើដំណើរពីខេត្តកំពង់ធំទៅកាន់ខេត្តព្រះវិហារដើម្បីស្វែងរកជីតា អ៊ំនិងពូរបស់ខ្ញុំ ដែលបានបែកគ្នាតាំងពីឆ្នាំ១៩៧០មកម្ល៉េះ ដោយសារតែគាត់បានរត់គៀសខ្លួនពីសង្គ្រាម ។ ពេលទៅដល់ខេត្តព្រះវិហារ ប៉ាម៉ាក់របស់ខ្ញុំបានជួបតែអ៊ំនិងពូរបស់ខ្ញុំម្នាក់តែប៉ុណ្ណោះ ។ ចំណែកឯជីតានិងពូរបស់ខ្ញុំម្នាក់ទៀតបានស្លាប់បាត់បង់ជីវិតក្នុងឆ្នាំ១៩៧៦ ។ ពូរបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្មានថ្នាំសង្កូវព្យាបាល ។ រីឯជីតារបស់ខ្ញុំបានស្លាប់ដោយសារការខូចចិត្តនិងការនឹករឭកប្រពន្ធកូនដែលបានបែកគ្នាមិនដឹងថាស្លាប់ឬរស់ ។

ក្រោយពេលបានជួបជុំគ្នាហើយ ក្រុមគ្រួសាររបស់ខ្ញុំបានសម្រេចចិត្តវិលត្រឡប់មកទីក្រុងភ្នំពេញវិញ ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៨០ ម៉ាក់របស់ខ្ញុំសម្រាលបានកូនស្រីម្នាក់គឺជារូបខ្ញុំ ។

ខ្ញុំបានឮរឿងរ៉ាវគ្រួសាររបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមតាំងពីខ្ញុំមានអាយុជាង១០ឆ្នាំមកម្ល៉េះ ។ លោកយាយនិងប៉ាម៉ាក់របស់ខ្ញុំ តែងតែនិយាយជារឿយៗអំពីរឿងរ៉ាវទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមប្រាប់ដល់កូនចៅស្តាប់ដើម្បីជាការគិតនិងចងចាំនូវភាពខ្លោចផ្សាដែលក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនទូទាំងប្រទេសបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។

ដើមឡើយ ខ្ញុំមិនសូវជឿជាក់នូវរឿងរ៉ាវទុក្ខសោកហួសពីការស្មានទាំងឡាយដែលប៉ាម៉ាក់របស់ខ្ញុំបាននិយាយប្រាប់ទេ ។ ប៉ុន្តែនៅពេលដែលខ្ញុំបានធ្វើការងារសិក្សាស្រាវជ្រាវអំពីស្ត្រីនៅក្នុងរបបខ្មែរក្រហម ព្រមទាំងបានជួបជាមួយមនុស្សកាន់តែច្រើនដែលនៅទីកន្លែងផ្សេងៗគ្នា ហើយមានសាច់រឿងប្រហាក់ប្រហែលនឹងគ្រួសាររបស់ខ្ញុំដែរ ទើបឲ្យខ្ញុំជឿជាក់ថាអ្វីដែលប៉ាម៉ាក់ខ្ញុំប្រាប់គឺជាការពិត ។

ខ្មែរក្រហមមិនបានសម្លាប់ជីតានិងសាច់ញាតិរបស់ខ្ញុំដោយផ្ទាល់ដៃទេ ប៉ុន្តែខ្មែរក្រហមបានសម្លាប់ជីតារបស់ខ្ញុំដោយការផ្តាច់មនោសញ្ចេតនាគ្រួសារ មិនផ្តល់ថ្នាំព្យាបាលនៅពេលមានជំងឺ និងមិនផ្តល់អាហារឲ្យបរិភោគ ។ ខ្មែរក្រហមបានផ្សំផ្គុំប៉ាម៉ាក់របស់ខ្ញុំជាប្តីប្រពន្ធដោយគ្មានមេបាទាំងសងខាងចូលរួមដឹងឮ ។ តើរឿងរ៉ាវខ្មែរក្រហមនឹងត្រូវអូសបន្លាយដល់ពេលណាទៀត?

**ប៉ាង ពីរីន**


ប៉ាង ពីរីន

# គោរពជូន
## នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកបណ្ឌិត ឆាំង យុ ជាទីរាប់អានបំផុត

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកបណ្ឌិត ដែលបានផ្តល់ទស្សនាវដ្តី «ស្វែងរកការពិត» រៀងរាល់លេខដល់នាងខ្ញុំ ជាពិសេសសៀវភៅ «មុនដំបូងខ្មែរក្រហមសម្លាប់ប៉ាំរបស់ខ្ញុំ» ចំនួនមួយក្បាល ទុកតម្កល់ជាឯកសារស្តីពីប្រវត្តិរបស់ក្មេងស្រីម្នាក់ដែលរងនូវទារុណកម្មក្នុងរបបខ្មែរក្រហម ដូចក្មេងស្រី-ប្រុសដទៃទៀត ឬក្រុមគ្រួសារដទៃ ដែលសុទ្ធតែរងនូវអំពើព្រៃផ្សៃឥតត្រាប្រណីក្នុងរបបដឹកនាំរបស់ ប៉ុល ពត, អៀង សារី, ខៀវ សំផន ពិសេសអ្នកដែលប្រព្រឹត្តផ្ទាល់ដៃនូវការកាប់សម្លាប់ឥតក្តីមេត្តាក្នុងរបបនោះ ។

បើនិយាយពីសាច់រឿងមានការរងទុក្ខដូចគ្នា គ្រាន់តែភាពរងទុក្ខខុសគ្នាបន្តិចៗ ដូចរូបនាងខ្ញុំផ្ទាល់ ក្រុមគ្រួសារផ្ទាល់ និយាយពីសាច់បង្កើតរងការស្លាប់អស់ដប់មួយនាក់ (១១) ក្នុងនោះមាន ឪពុក ម្តាយ ជីដូន បង ប្អូនៗ កូនស្រី ។ បើនិយាយពីឪពុកម្តាយមីង បងប្អូនជីដូនមួយវិញ ច្រើននាក់ណាស់ រាប់មិនអស់ទេ ជាហេតុធ្វើឲ្យអារម្មណ៍របស់នាងខ្ញុំពុំដែលស្ងប់មួយវេលាណាឡើយ ។ បើអ្នករស់នៅមិនស្ងប់ទៅហើយ ចុះអ្នកដែលស្លាប់ទៅ តើស្ងប់បានទេ?

ដូច្នេះ ក្នុងនាមជាជនរងគ្រោះម្នាក់ដែលរងនូវអំពើគ្រប់បែបយ៉ាងក្នុងរបបនោះ នាងខ្ញុំសូមលោកបណ្ឌិតមេត្តាធ្វើយ៉ាងណាឲ្យតុលាការអន្តរជាតិកើតមានឡើងឲ្យបានឆាប់ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះកុំឲ្យរួចខ្លួនឲ្យសោះ ពិសេសប្រពន្ធរបស់ អៀង សារី ដែលជាស្ត្រីដ៏ឆ្នើមក្នុងរបបប្រល័យពូជសាសន៍ខ្មែរគ្នាឯងនោះផង (ជាស្ត្រីដែលមានចិត្តនិន្ទា ពោរពេញទៅដោយការព្យាបាទព្រោះវង្វេងក្នុងអំណាច ដោយមិនបានគិតពីសុខទុក្ខស្ត្រីដូចគ្នា ធ្វើឲ្យស្ត្រីកម្ពុជាទាំងអស់រងទុក្ខលំបាក ខ្វះមុខ ខ្វះក្រោយ រងជំងឺ រងការអត់ឃ្លាន រងការកាប់សម្លាប់ ។ល ។និង ។ល ។) ។

នាងខ្ញុំនៅតែមានសង្ឃឹមថា ការខិតខំរបស់លោកបណ្ឌិតពិតជាបានទទួលជោគជ័យក្នុងពេលឆាប់ៗខាងមុខនេះ ហើយនាងខ្ញុំក៏សង្ឃឹមថា ពិភពលោកនេះពិតជាផ្តល់ភាពយុត្តិធម៌មួយដ៏សមស្របដល់ប្រជាជនខ្មែរទាំងអស់ដែលរស់នៅសព្វថ្ងៃនេះ និងប្រជាជនខ្មែរដែលបានស្លាប់ទៅអស់ជាច្រើនលាននាក់ដែរ ។

យុត្តិធម៌ត្រូវតែមាន! យុត្តិធម៌ត្រូវតែឈ្នះ!

ជនណាប្រព្រឹត្តត្រូវទទួលកំហុស! ដូចពុទ្ធដីកាព្រះសម្តែងទុក «ជនណាប្រព្រឹត្តអំពើអកុសល ត្រូវទទួលបាបកម្ម» ។

សូមលោកបណ្ឌិតទទួលនូវការរាប់អានយ៉ាងជ្រាលជ្រៅនិងកក់ក្តៅបំផុតអំពីនាងខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣

**លឹម ស្រីផល្លា**

# ទស្សនាវដ្ដី ស្វែងរកការពិត ឆ្នាំ២០០២















*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្ដីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 38, February 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands and USA.**